សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Deoit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រាក់ឈ្នួលកម្មករនិយោជិត

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ឯល ម៉ុនឆា**
កញ្ញា **ខ៉ា ស្រីលាក់**

សាស្ត្រាចារ្យណែនាំ
**សាស្ត្រាចារ្យ ម៉ួយ ធីតា**

សម្រាប់ថ្នាក់**បរិញ្ញាបត្រនីតិសាស្ត្រ**
ជំនាន់ទី២០
ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Deoit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ប្រាក់ឈ្នួលកម្មករនិយោជិត

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ឯល ម៉ុនធា**
កញ្ញា **ខាំ ស្រីលាក់**

សាស្ត្រាចារ្យណែនាំ
សាស្ត្រាចារ្យ **ម៉ុយ ធីតា**

សម្រាប់ថ្នាក់**បរិញ្ញាបត្រនីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា២០១៦
ឆ្នាំសរសេរសារណា២០២០

# សេចក្ដីថ្លែងអំណរគុណ

៙៙📖៙៙

យើងខ្ញុំឈ្មោះ **ឯល ម៉ុនធា** ភេទ ប្រុស ថ្នាក់L4A1 និង **ទ៉ា ស្រីលាក់** ភេទ ស្រី ថ្នាក់L4C2ជានិស្សិតបរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី២០ ឆ្នាំសិក្សា២០១៩-២០២០ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

## សូមសំដែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក **ស្រាក់ ចាន់ធឿន** និងអ្នកម្ដាយ **ឆន ចាន់ថា**

លោកឪពុក **ទ៉ា ញ៉ឹម** និងអ្នកម្ដាយ **ហែម ទ៉ាន់**

អ្នកមានគុណបានផ្ដល់កំណើតចិញ្ចឹមបីបាច់ និងផ្ដល់កម្លាំងចិត្តសេចក្ដីស្រឡាញ់ការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហាធម៌ ផ្ដល់លទ្ធភាពឱ្យកូនបន្តការសិក្សារហូតដល់ថ្នាក់ឧត្ដមសិក្សាដោយលោកបានលះបង់គ្រប់បែបយ៉ាងដើម្បីឱ្យកូនទទួលបានការអប់រំមានចំណេះដឹង។ កូនៗនឹងចងចាំគុណលោកទុកក្នុងចិត្តកូនជានិច្ច និងធ្វើជាកូនប្រកបដោយកត្តញ្ញូកតវេទីតាធម៌។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** និងសាកលវិទ្យាធិការរង ព្រមទាំងសាស្រ្តាចារ្យ បុគ្គលិក នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំបង្រៀន ផ្ដល់ចំណេះដឹង និងបង្កបរិយាកាសងាយស្រួលនានា ដើម្បីឱ្យយើងខ្ញុំទទួលយកចំណេះដឹង រហូតបញ្ចប់ការសិក្សាបានដោយជោគជ័យ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរអរគុណនិងសូមដឹងគុណជានិច្ចចំពោះលោកស្រីសាស្រ្តាចារ្យ **ម៉ួយ ធីតា** ដែលជាព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្រ្ត ព្រមទាំងជាសាស្រ្តាចារ្យណែនាំការសរសេរសារណានេះ ដោយបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់កម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ ដើម្បីជួយណែនាំ និងជំរុញការសរសេរស្នាដៃនេះ តាំងពីដើមរហូតដល់បញ្ចប់ជាស្ថាពរ។

ចុងក្រោយយើងខ្ញុំសូមបួងសួងដល់ទេវតា និងវត្ថុសក្ដិសិទ្ធសូមលោកប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ ជូនលោកអ្នកមានគុណទាំងពីរ ឯកឧត្ដមសកលវិទ្យាធិការ វិទ្យាធិការរង សាស្រ្តាចារ្យណែនាំ និងសាស្រ្តចារ្យទាំងអស់ឱ្យជួបតែប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សារយៈពេល៤ឆ្នាំកន្លងមកនេះក្នុងការសិក្សាលើមុខជំនាញបរិញ្ញាបត្រនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់អស់ពីកម្លាំកាយចិត្តរបស់សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងការស្រាវជ្រាវបន្ថែម យើងខ្ញុំបានយល់ដឹងជាច្រើនអំពីមុខជំនាញនេះ។ ក្នុងកំឡុងពេលសិក្សាកន្លងមកនេះ យើងខ្ញុំបានសង្កេតឃើញថាវិស័យច្បាប់នេះមានការវិវឌ្ឍទៅមុខជានិច្ច ក្នុងនោះច្បាប់ការងារក៏មានការវិវឌ្ឍថ្មីផងដែរទើបយើងខ្ញុំជ្រើសរើសយកប្រធានបទ «ប្រាក់ឈ្នួលកម្មករនិយោជិតឆ្នាំ២០២០» ធ្វើជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែប្រាក់ឈ្នួលកម្មករនិយោជិតមានការវិវឌ្ឍច្រើន ហើយពិសេសក្នុងស្ថានភាពមួយដែលពិភពលោកកំពុងតែជួបនូវវិបត្តិជម្ងឺសកល កូវីត១៩ រួមទាំងប្រទេសកម្ពុជាផង ក៏បានធ្វើឱ្យមានការប៉ះពាល់ផងដែរដល់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ក្នុងនោះក៏មានវិធានការដោះស្រាយផងដែរ។

ការចងក្រងនេះកើតចេញពីការខិតខំប្រឹងប្រែង ដោយយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវយមតាងចំណេះដឹងដែលបានមកពីការសិក្សា និងសុំមតិយោបល់ពីលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់កន្លងមក។ ការស្រាវជ្រាវនេះគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះនៃច្បាប់ការងារ ក្នុងគោលបំណងបង្ហាញពីប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវទទួលបាន ការវិវឌ្ឍថ្មីៗនៃប្រាក់ឈ្នួល និងសូមរួមចំណែកជាពុទ្ធិក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៅមុនទៀតសម្រាប់អ្នកសិក្សាស្រាវជ្រាវគ្រប់រូប ក៏ដូចជានិស្សិតផងដែរ។ យើងខ្ញុំសង្ឃឹមថាសារណានេះ នឹងអាចជួយជាឯកសារជំនួយស្មារតីដល់ជនគ្រប់រូបក្នុងការស្វែងយល់ពីប្រាក់ឈ្នួលកម្មករនិយោជិតឱ្យកាន់តែច្បាស់ និងស៊ីជម្រៅបន្ថែមទៀតព្រោះការប្រាក់ឈ្នួលតែងតែមាការវិវឌ្ឍជានិច្ច។

ទោះបីជាការស្រាវជ្រាវនេះបានរៀបរៀងឡើយដោយយកចិត្តទុកដាក់ និងសម្រិតសម្រាំងអស់ពីសមត្ថភាព រួមទាំងចំណេះដឹងស្តួចស្តើងរបស់យើងខ្ញុំនេះពិតជាជៀសមិនផុតពីការខ្វះខាតដូចជា ការប្រើពាក្យពេចន៍ ការបកស្រាយ និងអត្ថន័យក្នុងសារណានេះឡើយ។ យើងខ្ញុំបាទសូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយ និងសូមទទួលយកការិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវទាំងអស់

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម**..................................................... ១

**ជំពូកទី១៖ សញ្ញាណទូទៅនៃប្រាក់ឈ្នួល**

**ផ្នែកទី១៖ ប្រភេទផ្សេងៗនៃប្រាក់ឈ្នួលទូទៅ**..................................................... ៣

**១.១ ប្រាក់ឈ្នួលសុទ្ធសាធ**..................................................... ៣

**១.១.១ ប្រាក់ឈ្នួលប្រចាំខែ**..................................................... ៤

ក.ប្រាក់ឈ្នួលប្រចាំខែសម្រាប់ការងារពេលថ្ងៃ..................................................... ៤

ខ. ការងារពេលយប់..................................................... ៥

**១.១.២ ប្រាក់ឈ្នួលប្រចាំអឌ្ឍមាស**..................................................... ៥

**១.១.៣ ប្រាក់ឈ្នួលប្រចាំសប្តាហ៍**..................................................... ៥

**១.១.៤ ប្រាក់ឈ្នួលប្រចាំថ្ងៃ**..................................................... ៦

**១.១.៥ ប្រាក់ឈ្នួលប្រចាំម៉ោង**..................................................... ៦

**១.១.៦ ប្រាក់ឈ្នួលសម្រាប់ការងារតាមបរិមាណផលិតផល ឬការងារដេរស៊ីចុង**..................................................... ៦

**១.១.៧ ប្រាក់ឈ្នួលគោលសម្រាប់ការងារទទួលបានកម្រៃជើងសារ**..................................................... ៦

**១.២ ប្រាក់ឈ្នួលបន្ទាប់បន្សំ**..................................................... ៦

**១.២.១ ប្រាក់បន្ថែមម៉ោង**..................................................... ៧

ក. ការបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ..................................................... ៧

ខ. ប្រាក់បន្ថែមម៉ោងសម្រាប់ការងារពេលយប់..................................................... ៩

គ. ប្រាក់បន្ថែមម៉ោងសម្រាប់ថ្ងៃសម្រាកប្រចាំសប្តាហ៍ ឬថ្ងៃបុណ្យ..................................................... ៩

**១.២.២ ប្រាក់កម្រៃជើងសាដែលបន្ថែមលើប្រាក់ឈ្នួល**..................................................... ១០

**១.២.៣ ប្រាក់បុព្វលាភ និងប្រាក់បំណាច់**..................................................... ១០

ក. ប្រាក់បំណាច់អតីតភាពការងារ..................................................... ១០

ខ.ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា..................................................... ១៣

គ. ប្រាក់ទូទាត់ចំពោះការជូនដំណឹង ........ ១៣
**១.២.៤ ប្រាក់សោហ៊ុយជម្ងឺចិត្ត** ........ ១៤
ក.ប្រាក់សោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាកាងារមានថិរវេលាកំណត់ ........ ១៤
ខ.ប្រាក់សោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាការងារមិនមានពេលកំណត់ ........ ១៥
**១.២.៥ ភាគកម្មក្នុងប្រាក់ចំណេញ** ........ ១៥
**១.២.៦ ប្រាក់ដែលបើកជាប្រាក់ខ្ទាន់** ........ ១៦
**១.២.៧ តម្លៃអត្ថប្រយោជន៍ជាវត្ថុ** ........ ១៧
**១.២.៨ ប្រាក់ទទួលបានក្នុងពេលលំហែមាតុភាព** ........ ១៧
## ១.៣ ប្រាក់វិភាជន៍ ........ ១៨
**១.៣.១ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់** ........ ១៨
**១.៣.២ ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក ឬប្រាក់បំណាច់ទូទាត់ការឈប់សម្រាក** ........ ១៨
ក.ការឈប់សម្រាកថ្ងៃបុណ្យដែលត្រូវទទួលបានប្រាក់ឈ្នួល ........ ១៨
ខ.ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ........ ១៩
គ.ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល ........ ២១
## ផ្នែកទី២៖ ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បបរមា ........ ២១
**២.១.១ ការព្យាបាលសុខភាព** ........ ២១
**២.១.២ វិភាជន៍សម្រាប់គ្រួសារ** ........ ២២
**២.១.៣ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ** ........ ២២
**២.១.៤ ប្រាក់ធនានុគ្រោះ** ........ ២២
**២.១.៥. អត្ថប្រយោជន៍សម្រាប់សម្រួលការងារដល់កម្មករនិយោជិត** ........ ២៣
## ២.២ ប្រាក់ឈ្នួលអប្បបរមា ........ ២៣
**២.២.១ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា** ........ ២៣
ក.ការងារសាកល្បង ........ ២៣
ខ.កូនជាង ........ ២៥
គ.កម្មករពេញសិទ្ធិ ........ ២៦

ឃ.ការងារម៉ៅការ ឬតាមវិមាណផលិតផល(ដេរស៊ីបុង)........................................................................២៦

**២.២.២ ការកំណត់ប្រាក់ឈ្នួលអប្បបរមា**........................................................................២៧

ក.ប្រវត្តិសមត្ថកិច្ចកំណត់ប្រាក់ឈ្នួលអប្បបរមា........................................................................២៧

ខ.បទដ្ឋានគតិយុត្តនៃការវិវឌ្ឍន៍ប្រាក់ឈ្នួលអប្បបរមា........................................................................៣០

## ជំពូកទី២៖ សិទ្ធិ និងភាតព្វកិច្ចពាក់ព័ន្ធនិងប្រាក់ឈ្នួល

**ផ្នែកទី១៖ វិធាននៃការបើកប្រាក់ឈ្នួល**........................................................................៣៣

**១.១ ការជូនដំណឹងដល់កម្មករនិយោជិតអំពីប្រាក់ឈ្នួល**........................................................................៣៣

**១.២ វិធីបើកប្រាក់ឈ្នួល**........................................................................៣៣

**១ .៣ ពេលវេលាបើកប្រាក់ឈ្នួល**........................................................................៣៤

**១.៤ ទីកន្លែងបើកប្រាក់ឈ្នួល**........................................................................៣៤

**១.៥ វិធាននៃការបើកប្រាក់ឈ្នួល**........................................................................៣៤

**១.៥.១ ការមិនបាត់បង់សិទ្ធិចំពោះការតវ៉ាបើកប្រាក់ឈ្នួលកម្មករនិយោជិត**........................................................................៣៥

**១.៥.២ អាជ្ញាយុកាលនៃសិទ្ធិប្ដឹងសុំបើកប្រាក់ឈ្នួល**........................................................................៣៥

**ផ្នែកទី២៖ ការធានាសិទ្ធិនៃប្រាក់ឈ្នួលចំពោះកម្មករនិយោជិត**........................................................................៣៥

**២.១ ឯកសិទ្ធិនៃប្រាក់ឈ្នួលកម្មករនិយោជិត**........................................................................៣៦

**២.២ ការកាត់ប្រាក់ឈ្នួលដោយនិយោជក**........................................................................៣៦

**២.២.១ ការកាត់ប្រាក់ឈ្នួលដែលជំពាក់**........................................................................៣៦

**២.២.២ ការកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសមាជីព**........................................................................៣៧

**២.៣ ការរឹបអូសឃាត់ទុកប្រាក់ឈ្នួល**........................................................................៣៨

**២.៤ ការគិតប្រាក់ដែលអាចរឹបអូសបាន**........................................................................៣៨

**ផ្នែកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធនិងប្រាក់ឈ្នួល**........................................................................៣៩

**៣.១ បញ្ហាប្រឈមទូទៅ**........................................................................៣៩

**៣.២ បញ្ហាប្រឈមដោយខ្សែកក្នុងឆ្នាំ២០២០**........................................................................៤០

**៣.៣ ការបាត់បង់ការងាររបស់កម្មករនិយោជិតក្នុងអំឡុងពេលវិបត្តិកូវីត១៩**........................................................................៤០

៣ ៤.ដំណោះស្រាយជួយដល់វិស័យឯកជន និងកម្មករនិយោជិតដែលទទួលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ១៩ ......................................................................................................៤១

៣.៤.១ វិធានជួយរក្សាលំនឹងអាជីវកម្ម និងជីវភាពកម្មករនិយោជិត..........................................៤១

៣.៤.២ វិធានការផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្ម ......................................................................៤២

៣.៤.៣ ការបង្កើនហិរញ្ញប្បទានបន្ថែមដើម្បីស្តារ និងជំរុញកំណើនក្រោយវិបត្តិកូវីដ-១៩ ............ ៤៣

៣.៤.៤ វិធានការជំនួយសង្គម ..........................................................................................................៤៤

៣.៤.៥ ការដាក់ឱ្យអនុវត្តចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច ...............................................................៤៤

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៤៦

**អនុសាសន៍**........................................................................................................................ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ឈឈ✵ឈឈ

ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍មួយដែលមានសេដ្ឋកិច្ចលូតលាស់គួរឱ្យកត់សម្គាល់ ដែលធ្វើឱ្យមានវិនិយោគិនជាច្រើនចូលមកធ្វើការវិនិយោនៅក្នុងប្រទេសកម្ពុជាទាំងក្នុង និងក្រៅប្រទេសលើគ្រប់វិស័យ ជាពិសេសវិស័យវាយនភណ្ឌកាត់ដេរដែលបានផ្តល់ការងារជាច្រើនជូនប្រជាជនកម្ពុជា។ ការអភិវឌ្ឍន៍រីកចម្រើនទៅបានយ៉ាងរលូនបែបនេះ ច្បាប់ការងារ បានដើរតួរយ៉ាងសំខាន់ក្នុងការធានានូវការងារមួយដែលស្របច្បាប់ កុំឱ្យមានកេងប្រវ័ញ្ចលើកម្លាំងពលកម្មកម្មករនិយោជិត ធានាឱ្យបាននូវសេចក្តីថ្លៃថ្នូរដល់កម្មករនិយោជិត។

សញ្ញាណនៃច្បាប់ការងារត្រូវបានលេចឡើងគិតចាប់តាំងពីឆ្នាំ១៩៥៣ ប៉ុន្តែត្រូវបានបាត់បង់ទៅវិញនៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩នៅពេលដែលប្រទេសកម្ពុជាស្ថិតក្នុងរបបប្រល័យពូជសាសន៍។ បន្ទាប់ពីប្រទេសកម្ពុជាបានរួចចាកផុតពីសង្គ្រាមរហូតមកដល់ឆ្នាំ១៩៩២ រដ្ឋាភិបាលបានរៀបចំច្បាប់ការងារឡើងវិញ។ ក្រោយប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញ១៩៩៣ និងមករហូតដល់ឆ្នាំ១៩៩៤ប្រទេសកម្ពុជាបានរៀបចំបង្កើតច្បាប់ការងារថ្មីដោយយកឯកសារស្តីពីការងារចាស់ ច្បាប់ការងារឆ្នាំ១៩៩២ធ្វើជាមូលដ្ឋានកែលម្អឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ១៩៩៣ ដោយមានការជួយឧបត្ថមពីអង្គការការងារអន្តរជាតិ (ILO) រួមទាំងជំនាញការក្រសួងការងារបារាំង និងវិទ្យាស្ថានការងារសេរីអាស៊ីអាមេរិច (AAFIL) ទើបប្រសូត្របានច្បាប់ការងារថ្មីមួយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។ ប៉ុន្តែច្បាប់ការងារមិននៅត្រឹងគ្មានការវិវឌ្ឍនោះទេរហូតមកដល់ឆ្នាំ២០២០នេះច្បាប់ការងារបានត្រូវធ្វើវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តថ្មីជាច្រើនបានលេចឡើងដើម្បីបំពេញបន្ថែមចំណុចដែលខ្វះខាតនៃច្បាប់ការងារ១៩៩៧ ឱ្យស្របទៅតាមការអភិវឌ្ឍន៍ប្រទេស។ ដោយប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ជាលំដាប់ធ្វើឱ្យប្រជាជនសម្បូរការងារធ្វើ និងទទួលបានប្រាក់ឈ្នួលសមរម្យសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រាក់ឈ្នួលគឺ គឺជាឈ្នួល ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ដែលកម្រិតដោយការព្រមព្រៀងរវាងកម្មករនិយោជិត និងនិយោជក ឬដោយច្បាប់ជាតិ ដែលនិយោជកត្រូវបើកជូនកម្មករនិយោជិតតាមកិច្ចសន្យាការងា តាមប្រភេទការងារ តាមរយៈពេលនៃអតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗទៀត។ ប៉ុន្មានឆ្នាំចុងក្រោយនេះប្រាក់ឈ្នួលមានវិវត្តន៍ជាលំដាប់លើគ្រប់វិស័យ ជាពិសេសវិស័យវាយនភណ្ឌកាត់ដេរ ដែលក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានកំណត់ជារៀងរាល់ឆ្នាំ។ ការកំណត់បែបនេះគឺដើម្បីធានាដល់សេចក្តីថ្លៃថ្នូរ ឱ្យសមនិងកម្លាំងក្នុងការបំពេញការងារជាមួយប្រាក់ឈ្នួលដែលទទួលបាន ធ្វើកម្មករនិយោជិតមានជីវភាពធូធារ ប្រទេសមានការអភិវឌ្ឍន៍ទៅមុខ និងការប្រកួតប្រជែងទីផ្សារការងារ និងសេដ្ឋកិច្ចលើឆាកអន្តរជាតិ ។ ប្រាក់ឈ្នួលដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិតត្រូវគោរពតាមច្បាប់ការងារ និងច្បាប់ផ្សេងទៀតដែលទាក់ទងនិងប្រាក់ឈ្នួល រួមបញ្ចូលទាំងបទដ្ឋានគតិយុត្តនានាស្តីពីប្រាក់ឈ្នួល។

តើអ្វីទៅជាប្រាក់ឈ្នួល? តើប្រភេទប្រាក់ឈ្នួលមានប៉ុន្មាន? អ្វីទៅជាប្រាក់ឈ្នួលអប្បបរមា? តើនិយោជក និងកម្មករនិយោជិតមានសិទ្ធិ និងកាតព្វកិច្ចលើប្រាក់ប្រាក់ឈ្នួលអ្វីខ្លះចំពោះគ្នា? មានបញ្ហាប្រឈមអ្វីខ្លះចំពោះនិយោជក និងកម្មករនិយោជិតលើប្រាក់ឈ្នួល?

ដើម្បីឆ្លើយតបនិងសំណួរខាងលើនេះ ក្នុងសារណានេះបានបែងចែកជាពីរជំពូកធំៗ និងត្រូវបានសិក្សាយ៉ាងស៊ីជម្រៅដោយ ជំពូកទី១ សញ្ញាណទូទៅនៃប្រាក់ឈ្នួល ដែលបែងចែកជាផ្នែក១ប្រភេទទូទៅនៃប្រាក់ឈ្នួល ផ្តោតសំខាន់លើប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ឈ្នួលបន្ទាប់បន្សំ ប្រាក់វិភាជន៍ និងផ្នែក២ការមិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បបរមា ផ្តោតសំខាន់លើប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល ប្រាក់ឈ្នួលអប្បរមា។ ជំពូក២ សិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធនិងប្រាក់ឈ្នួលព្រមទាំបញ្ហាប្រឈម ដែលបានបែងចែកជាផ្នែក១ វិធាននៃការបើប្រាក់ឈ្នួល ផ្តោតសំខាន់ទៅលើការជូនដំណឹងដល់កម្មករនិយោជិតអំពីប្រាក់ឈ្នួល វិធីបើកប្រាក់ឈ្នួល ពេលវេលាបើកប្រាក់ឈ្នួល ទីកន្លែងបើកប្រាក់ឈ្នួល វិវាទនៃការបើកប្រាក់ឈ្នួល និងដំណោះស្រាយនៃការបើកប្រាក់ឈ្នួល ផ្នែក២ផ្តោតសំខាន់ទៅលើការធានាសិទ្ធិនៃប្រាក់ឈ្នួលចំពោះកម្មករនិយោជិត ឯកសិទ្ធិនៃប្រាក់ឈ្នួលរបស់កម្មករនិយោជិត ការកាត់ប្រាក់ឈ្នួលដោយនិយោជក បញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធនិងប្រាក់ឈ្នួលក្នុងឆ្នាំ២០២០ផងដែរ។

# ជំពូកទី១៖ សញ្ញាណទូទៅនៃប្រាក់ឈ្នួល

ប្រាក់ឈ្នួល គឺជាប្រាក់កម្រៃដែលកម្មករនិយោជិតទទួលបាន បន្ទាប់ពីបានបំពេញការងារទៅឱ្យនិយោជកដែលនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលនេះជូនកម្មករនិយោជិត។ ប្រាក់ឈ្នួលដែលត្រូវបានកំណត់និយមន័យដោយច្បាប់ស្តីពីការងារកម្ពុជា១៩៩៧បានឱ្យនិយមន័យថា ឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកម្រិតបានដោយការព្រមព្រៀង ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឱ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើ ឬដែលត្រូវធ្វើក្តី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី[1]។ ចំពោះសញ្ញាណទូទៅនៃប្រាក់ឈ្នួលគឺត្រូវសិក្សាលើចំណុចលម្អិតបន្ថែមទៀត **ផ្នែក១ ប្រភេទទូទៅនៃប្រាក់ឈ្នួល ផ្នែក២ ប្រាក់ដែលមិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលដែលត្រូវធានា។**

## ផ្នែកទី១៖ ប្រភេទផ្សេងៗនៃប្រាក់ឈ្នួលទូទៅ

ប្រាក់ឈ្នួលមានច្រើនប្រភេទសម្រាប់កម្មករនិយោជិតដែលត្រូវទទួលបានក្រោយពីបានបំពេញការងារឱ្យ និយោជក និងត្រូវបានបែងចែកដាច់ៗពីគ្នា ការទទួលបានប្រាក់ឈ្នួលនោះក៏ខុសៗគ្នាផងដែរ ទៅតាមការបំពេញការងារនោះ។ ចំពោះប្រភេទប្រាក់ឈ្នួលដែលត្រូវសិក្សានៅក្នុងផ្នែកនេះគឺ ១.១ ប្រាក់ឈ្នួលសុទ្ធសាធ ១.២ ប្រាក់ឈ្នួលបន្ទាប់បន្សំ ១.៣ ប្រាក់វិភាជន៍។

### ១.១ ប្រាក់ឈ្នួលសុទ្ធសាធ

ប្រាក់ឈ្នួលសុទ្ធសាធ ឬប្រាក់ខែគោលគឺ សំដៅដល់ប្រាក់ដែលកម្មករនិយោជិតទទួលបាន ឬ ជាកម្រៃដែលកម្មករនិយោជិតទទួលបានពីម្ចាស់គ្រឹះស្ថាន ម្ចាស់សហគ្រាស រោងចក្រ ដែលកម្មករនិយោជិតបានបំពេញការងារនោះទៅតាមកិច្ចសន្យាការងារដែលខ្លួនបានព្រមព្រៀងជាមួយ ម្ចាស់គ្រឹះស្ថាន ម្ចាស់សហគ្រាស រោងចក្រ ដោយផ្អែកលើកិច្ចសន្យានរវាងម្ចាស់គ្រឹះស្ថាន ម្ចាស់សហគ្រាស រោងចក្រ និងកម្មករនិយោជិតបែបនេះធ្វើឱ្យមានសកម្មភាពបំពេញការងារផ្សេងៗដែលម្មករនិយោជិតត្រូវបំពេញដើម្បីទទួលបានប្រាក់ឈ្នួល ដែលអាចជា ប្រាក់ប្រចាំខែ ប្រាក់ប្រចាំអឌ្ឍមាស ប្រាក់ប្រចាំសប្តាហ៍ ប្រាក់ប្រចាំថ្ងៃ ប្រាក់ប្រចាំម៉ោង ប្រាក់សម្រាប់ការងារម៉ៅការ ឬការងារតាមបរិមាណផលិតផល(ដេស៊ីបុង) និងប្រាក់ឈ្នួលសម្រាប់ការងារទទួលបានកម្រៃជើងសារ។ គ្រប់ប្រាក់ឈ្នួលផ្សេងៗខាងលើ ទោះបីជាមានប្រភេទខុសៗគ្នាក៏ដោយក៏ប្រាក់ឈ្នួលនោះ យ៉ាងតិចណាស់ត្រូវស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាពោលគឺដើម្បីរ៉ាប់រងឱ្យកម្មករនិយោជិតគ្រប់រូបមានកម្ពស់ជីវភាពសមរម្យ

[1] មាត្រា១០២, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

ទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស[២]។ ហើយចិរវេលាការងារក៏មិនត្រូវខុសពីច្បាប់ការងារដែល គឺចិរវេលាធ្វើការងារ ៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ ឬ៤៨(សែសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍[៣]។

### ១.១.១ ប្រាក់ឈ្នួលប្រចាំខែ

នៅពេលដែលកម្មករនិយោជិតបានសម្រេចការងារជូននិយោជកក្នុងរយៈពេលមួយខែហើយនោះ និយោជកត្រូវបើកប្រាក់ឈ្នួលប្រចាំខែជូនកម្មករនិយោជិតតាមអត្រាប្រាក់ឈ្នួលដែលច្បាប់កំណត់។ ដោយយោងតាមប្រកាសលេខ ៣៩៩/១៩ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា
កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតផលស្បែកជើងសម្រាប់ឆ្នាំ២០២០ បានកំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតផលស្បែកជើងនៅទឹកប្រាក់១៩០(មួយរយកៅសិប)ដុល្លាររក្នុងមួយខែ។ មានន័យថានិយោជកត្រូវបើកប្រាក់ឈ្នួល១៩០(មួយរយកៅសិបដុល្លារ)យ៉ាងតិចបំផុត គឺមិនអាចក្រោម១៩០(មួយរយកៅសិបដុល្លារ) ក្នុងមួយខែបានទេ ប៉ុន្តែនិយោជកអាចបើកប្រាក់លើសពី ១៩០(មួយរយកៅសិប) ដុល្លាររក្នុងមួយខែដល់កម្មករនិយោជិតបានសម្រាប់ជាប្រាក់ឈ្នួលសុទ្ធសាធ ឬ ប្រាក់ឈ្នួលគោល។ ប្រាក់ឈ្នួលប្រចាំខែនេះមានពីរប្រភេទដែលមានលក្ខណៈខុសគ្នា គឺប្រាក់ឈ្នួលប្រចាំខែសម្រាប់ការងារពេលថ្ងៃ និងប្រាក់ឈ្នួលប្រចាំខែសម្រាប់ការងារពេលយប់។

#### ក.ប្រាក់ឈ្នួលប្រចាំខែសម្រាប់ការងារពេលថ្ងៃ

ការងារពេលថ្ងៃសម្រាប់កម្មករនិយោជិត គឺកម្មករនិយោជិតធ្វើក្នុងរយៈពេលមិនត្រូវឱ្យលើសពី ៨(ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ ឬ ៤៨(សែសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍បានឡើយ[៤]។ មានន័យថារយៈពេលការងាររបស់កម្មករនិយោជិតត្រូវធ្វើការងារតាមពេលវេលាខាងលើ ហើយនិយោជិតមិនអាចកំណត់ពេលការងារលើសពីនេះបានឡើយ តែនិយោជិតអាចកំណត់ពេលធ្វើការតិចជាងនេះបាន ហើយប្រាក់ឈ្នួលប្រចាំខែនៅដដែល។ ឧទាហរណ៍ក្រុមហ៊ុនមួយ បានកំណត់ពេលចូលធ្វើការ សម្រាប់ថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ដោយមិនគិតថ្ងៃសម្រាកសម្រាប់ថ្ងៃបុណ្យ គឺពេលព្រឹកម៉ោង៨(ប្រាំបី) ដល់ម៉ោង១១(ដប់មួយ) និងរសៀល ម៉ោង ១(មួយ) ដល់ម៉ោង ៥(ប្រាំ)ល្ងាច។

[២]មាត្រា១០៤, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។
[៣]មាត្រា១៣៧, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។
[៤]មាត្រា១៣៧, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

**ខ. ការងារពេលយប់**

ការងារពេលយប់ ឬការងារវេនយប់គឺជាការងារដែលកម្មករនិយោជិតធ្វើចន្លោះម៉ោង២២(ម្ភៃពី) ដល់ម៉ោង ៥(ប្រាំ)ក្តី ទោះធ្វើការងារផ្លាស់ប្តូរគ្នាក្តី ឬ ធ្វើជាអចិន្ត្រៃយ៍ក្តី ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់ការងារពេលយប់គឺ ១៣០%(មួយរយសាមសិបភាគរយ)នៃប្រាក់ឈ្នួលការងារពេលថ្ងៃ[៥]។ ចំពោះគ្រឹះស្ថាន សហគ្រាស រោងចក្រដែលមានដែលមានកម្មករនិយោជិតធ្វើការងារពេលយប់នោះម្ចាស់ត្រូវផ្តល់កន្លែងដំណេកឱ្យបានសមរម្យដល់កម្មករនិយោជិត និងមធ្យោបាយធ្វើដំណើរសម្រាប់ការធ្វើដំណើរចេញពីធ្វើការពេលយប់ជូនកម្មករនិយោជិតទៅដល់លំនៅឋានដោយសុវត្ថិភាព។ ឧទាហរណ៍ ប្រាក់ឈ្នួលនៃកម្មករម្នាក់ធ្វើការពេលថ្ងៃក្នុងសហគ្រាសមួយទទួលបាន១៩០(មួយរយកៅសិប)ដុល្លារក្នុងមួយខែសម្រាប់ការងារពេលថ្ងៃ។ ហើយកម្មករម្នាក់ទៀតធ្វើការងារពេលយប់ក្នុងសហគ្រាសនោះដែរ នោះប្រាក់ឈ្នួលដែលគាត់ទទួលបានប្រចាំខែគឺ ១៣០% នៃ១៩០ដុល្លារ ស្មើនឹង ២៤៧(ពីរយសែសិបប្រាំពី)ដុល្លារ។

**១.១.២ ប្រាក់ឈ្នួលប្រចាំអឌ្ឍមាស**

ប្រាក់ឈ្នួលអឌ្ឍមាស គឺប្រាក់ឈ្នួលដែលនិយោជកនៃ សហគ្រាស រោងចក្រ គ្រឹះស្ថាន បើកជូនកម្មករនិយោជិតនៅពាក់កណ្តាលខែបើកម្តងៗ។ ប្រាក់ឈ្នួលនេះបើកសម្រាប់ការងារដែលកម្មករនិយោជិតបានសម្រេចការងារជូននិយោជកត្រឹមពាក់កណ្តាលខែម្តងប៉ុណ្ណោះ មិនមែនប្រាក់ឈ្នួលប្រចាំខែដែលកម្មករបើកពីដងនោះទេ។ ឧទាហរណ៍ កញ្ញា ធ្វើការនៅសហគ្រាសមួយកន្លែងដែលម្ចាស់សហគ្រាសនោះបានកំណត់ថាការបើកប្រាក់ឈ្នួល នៅពាក់កណ្តាលខែម្តង ៩៨ដុល្លារ ។ នៅពេលដល់ថ្ងៃទី១៥ នៃខែនោះកញ្ញាក៏បានទទួលប្រាក់ឈ្នួលនោះ។

**១.១.៣ ប្រាក់ឈ្នួលប្រចាំសប្តាហ៍**

តាមការព្រមព្រៀងរវាងកម្មករ និងនិយោជកអាចឃើញមានប្រភេទប្រាក់ឈ្នួលមួយប្រភេទទៀតគឺប្រាក់ឈ្នួលប្រចាំសប្តាហ៍ ដែលកម្មករត្រូវធ្វើការជូននិយោជកឱ្យបានមួយសប្តាហ៍នោះនិយោជកនឹងបើកប្រាក់នោះដល់កម្មករសម្រាប់ការងារមួយសប្តាហ៍នោះ ហើយកម្មករ បន្តធ្វើនៅសប្តាហ៍ថ្មីទៀតលុះបានបញ្ចប់សប្តាហ៍ថ្មីនោះទៀត និយោជកបើកប្រាក់ឈ្នួលសម្រាប់កាងារមួយសប្តាហ៍នោះទៀត ហើយកម្មករ និងនិយោជកធ្វើរបៀបនេះជាបន្តបន្ទាប់។

[៥] សារាចរណ៍ស្តីពីប្រាក់ឈ្នួលនៃការងារពេលយប់,លេខ១៨៥/កប រ.ស ,១៤ សីហា ២០០៧។

**១.១.៤ ប្រាក់ឈ្នួលប្រចាំថ្ងៃ**

ប្រភេទប្រាក់ឈ្នួលមួយប្រភេទដែលកម្មករ និងនិយោជកតែងព្រមព្រៀងគ្នាធ្វើឡើងនោះ គឺប្រាក់ឈ្នួលប្រចាំថ្ងៃដែលភាគច្រើនមានក្នុង វិស័យសំណង់ និងវិស័យកសិកម្ម ដែលកម្មករត្រូវបំពេញការងារឱ្យនិយោជិតបានមួយថ្ងៃហើយនិយោជកបើកប្រាក់ឈ្នួសម្រាប់ការងារមួយថ្ងៃនោះ ដែលជាទូទៅបើនៅពេលល្ងាចនៃថ្ងៃបញ្ចប់ការងារនោះតែម្តង។

**១.១.៥ ប្រាក់ឈ្នួលប្រចាំម៉ោង**

ប្រាក់ឈ្នួលប្រចាំម៉ោងអាចហៅម្យ៉ាងទៀតថាប្រាក់ឈ្នួលសម្រាប់កាងារក្រៅម៉ោង ដែលសម្រាប់ការងារ ១ម៉ោង ឬ២ម៉ោង ឬ៣ម៉ោង ឬ៤ម៉ោងជាដើម។ ចិរវេលាជាម៉ោង និងប្រាក់ឈ្នួលធ្វើការនេះគឺតាមការព្រមព្រៀងរវាងកម្មករនិយោជក និងនិយោជិតផ្ទាល់។ និយោជកត្រូវបើកប្រាក់ឈ្នួលនេះជូនកម្មករនិយោជិតនៅពេលដែលគេបានបញ្ចប់ម៉ោងការងាររបស់ខ្លួន។ ការងារប្រភេទនេះគឺបានជួយសម្រួលដល់ការស្វែងរកការងារបន្ថែម ដែលការងារមានដូចជាតាមហាងកាហ្វេ ម៉ាត និងភោជនីយដ្ឋានជាដើម។

**១.១.៦ ប្រាក់ឈ្នួលសម្រាប់ការងារតាមបរិមាណផលិផល ឬការងារដេរស៊ីបុង**

ការងារតាមបរិមាណផលិផល ឬការងារដេស៊ីបុង គឺកម្មករនិយោជិតនឹងទទួលបានប្រាក់ឈ្នួលទៅតាមបរិមាណទិន្នផលដែលខ្លួនបានសម្រេច ។ បើទិន្នផលដែលខ្លួនមានសម្រេចលើសពីប្រាក់ឈ្នួលដែលជាប្រាក់ឈ្នួលអប្បបរមាដែលកំណត់គឺត្រូវទទួលបានតមានទិន្នផលនោះ តែបើទាបជាងនោះនិយោជិតត្រូវបង្គ្រប់ឱ្យស្មើប្រាក់ឈ្នួលអប្បបរមាដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យការងារ។

**១.១.៧ ប្រាក់ឈ្នួលគោលសម្រាប់ការងារទទួលបានកម្រៃជើងសារ**

កម្មករនិយោជិត បានសម្រេចការលក់ ឬ បានបញ្ចប់ការងារជូននិយោជកនោះប្រាក់កម្រៃជើងសារទទួលបានគឺប្រាក់កម្រៃជើសារទៅលើផលិតផលដែលគេបានសម្រេចការលក់បាននោះ។ ការទទួលបានកម្រៃជើងសារតាមការលក់ ឬការបញ្ចប់ការងារនោះ គឺតាមការព្រមព្រៀងរវាងកម្មករនិយោជិត និងនិយោជក អាចគិតជា% (ភាគរយ)នៃតម្លៃផលិតផលនោះ។ ចំនួនភាគរយនេះគឺជាប្រាក់ឈ្នួលរបស់កម្មករនិយោជិតនោះតែម្តង ដែលនាពេលបច្ចុប្បន្នគេសង្កេតឃើញមាននៅក្នុងការលក់ដូរ និងវិស័យអចនទ្រព្យ។

**១.២ ប្រាក់ឈ្នួលបន្ទាប់បន្សំ**

ប្រាក់ដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសផ្តល់ជូនកម្មករនិយោជិតបន្ថែមលើប្រាក់ឈ្នួលសុទ្ធសាធជាប្រចាំខែនោះហៅថា ប្រាក់ឈ្នួលបន្ទាប់បន្សំ។ «*ប្រាក់បន្ទាប់បន្សំនេះ មានដូចជា ប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់ ប្រាក់បំណាច់ សោហ៊ុយជម្ងឺចិត្ត ភាគបម្រុងលើប្រាក់ចំណេញ ប្រាក់បុព្វលាភ តម្លៃអត្ថ*

*ប្រយោជន៍ជាវត្ថុ ប្រាក់វិភាជន៍សម្រាប់គ្រួសារ ប្រាក់ឈប់សម្រាកថ្ងៃបុណ្យ ប្រាក់បាត់បង់សមត្ថភាពពលកម្ម និង ប្រាក់ទទួលបានក្នុងពេលលំហែលមាតុភាព*[៦]» ។

### ១.២.១ ប្រាក់បន្ថែមម៉ោង

ប្រាក់ដែលកម្មករនិយោជិត ទទួលបានបន្ថែមលើប្រាក់ឈ្នួលគោលបន្ទាប់ពីបានធ្វើការបន្ថែមម៉ោងលើម៉ោងធ្វើការធម្មតា ៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ ឬ៤៨(សែសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍នោះហៅថា ប្រាក់បន្ថែមម៉ោង ឬ ប្រាក់ថែមម៉ោង។ បានជាត្រូវធ្វើការថែមម៉ោងដូច្នេះគឺដោយសារគ្រឹះស្ថាន សហគ្រាស រោងចក្រមានការប្រញាប់ការងារដែលមកពីការបញ្ជាទិញពីដៃគូជំនួញរបស់គ្រឹះស្ថាន សហគ្រាស រោងចក្រលើសពីធម្មតាទើបតម្រូវឱ្យកម្មករនិយោជិតធ្វើការងារបន្ថែមម៉ោងដើម្បីសម្រេចទៅតាមការចង់បាននោះ។

ការឱ្យកម្មករនិយោជិតថែមម៉ោងដូច្នេះគឺនិយោជកមិនអាចធ្វើតាមចិត្តបានទេព្រោះប៉ះពាល់ទៅដល់ម៉ោងសម្រាកកម្មករនិយោជិតបន្ទាប់ពីការងារ ដូចនេះការថែមម៉ោងនេះត្រូវគោរពតាមការកំណត់របស់ក្រសួការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគឺៈ

- និយោជកត្រូវទទួលការអនុញ្ញាតពីក្រសួងការងារមុនពេលផ្តល់ការងារបន្ថែមម៉ោងឱ្យកម្មករនិយោជិតលុះត្រាតែមានការអនុញ្ញាតពីក្រសួងការងារជាមុនសិនទើបនិយោជកអាចឱ្យកម្មករនិយោជិតថែមម៉ោងបាន។
- ថេរវេលាថែមម៉ោងមិនឱ្យលើសពីម៉ោងក្នុងមួយថ្ងៃទេ
- ការបន្ថែមម៉ោងនេះត្រូគោរពតាមគោលការណ៍ស្ម័គ្រចិត្តពីកម្មករនិយោជិត[៧]។

ការធ្វើការងារថែមម៉ោងគឺត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិតមិនត្រូវមានការបង្ខិតបង្ខំ ឬ ពិន័យអ្វីឡើយពីសំណាក់ម្ចាស់គ្រឹះស្ថាន សហគ្រាស រោងចក្រទេនៅពេលដែលកម្មករនិយោជិតមិនធ្វើការបន្ថែម៉ោង។ ការងារបន្ថែមម៉ោងមានដូចជា ការងារបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ ការបន្ថែមម៉ោងសម្រាប់ការងារពេលយប់ និងការបន្ថែមម៉ោងសម្រាប់ការងារនៅថ្ងៃសម្រាក និងថ្ងៃបុណ្យ។

#### ក. ការបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ

នៅពេលកម្មករនិយោជិតបានបញ្ចប់ម៉ោងការងារពេលថ្ងៃរបស់ខ្លួន ហើយកម្មករនិយោជិតមានបន្តធ្វើការបន្ថែមម៉ោងនោះកម្មករនិយោជិតនឹងទទួលបានប្រាក់ឈ្នួលបន្ថែមគឺ ប្រាក់ឈ្នួលបន្ថែមសម្រាប់ការងារពេល

[៦] មាត្រា១០៣, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៧] សេចក្តីជូនដំណឹងស្តីពីការការងារបន្ថែមលេខ ០៣០/១៥ កប/ស.ជ.ណ,ចុះថ្ងៃ២៧ កុម្ភៈ ២០១៥។

ថ្ងៃ។ ការបន្ថែមម៉ោងជាការស្ម័គ្រចិត្តរបស់កម្មករនិយោជិត មិនមានការបង្ខិតបង្ខំទេ រយៈពេលនៃការបន្ថែមម៉ោងគឺ មិនលើសពីពីរម៉ោងក្នុងមួយថ្ងៃទេ។ ចន្លោះពេលនៃការថែមម៉ោងនេះគឺអាច ធ្វើនៅចន្លោះពីម៉ោង ៤ រសៀល រហូតដល់ម៉ោង ២១យប់ មិនអាចដល់ម៉ោង២២យប់បានទេ ព្រោះបើថែមចាប់ពីចន្លោះម៉ោង ២២ដល់ម៉ោង៥ភ្លឺនោះជាការបន្ថែមម៉ោងការងារពេលយប់។ ការបន្ថែបម៉ោងសម្រាប់ការងារពេលថ្ងៃ  កម្មករនិយោជិតនឹងទទួលបានប្រាក់បន្ថែម៥០%(ហាសិបភាគរយ)បន្ថែមលើប្រាក់ឈ្នួលប្រាក់ឈ្នួលធម្មតាត្រូវជា១៥០%(មួយរយហាសិបភាគរយ)[៩]។  ការងារបន្ថែមម៉ោងនេះមិនមែនមានន័យថាត្រូវបន្ថែមលើប្រាក់ខែ៥០%លើប្រាក់ខែសុទ្ធនោះទេ  គឺបន្ថែម១៥០% លើប្រាក់ម៉ោងនៃប្រាក់ខែគោលនោះ គឺការបន្ថែមម៉ោង១៥០% នេះថែ្លមលើប្រាក់ដែលកម្មករបន្ថែមម៉ោងនោះ កាលណាកម្មករនិយោជិតធ្វើការបន្ថែមម៉ោងកាន់តែច្រើនម៉ោង (ប៉ុន្តែបានត្រឹមពីរម៉ោងក្នុងមួយថ្ងៃ) នោះកម្មករនិយោជិតនឹងទទួលបានប្រាក់បូកបន្ថែមលើប្រាក់ខែគោលរបស់គេកាន់តែច្រើនដែរ ។

សម្រាប់រូមន្តអនុវត្តសម្រាប់ប្រាក់បន្ថែមម៉ោងគឺៈ

ប្រាក់បន្ថែមម៉ោង = អត្រាប្រាក់ប្រចាំម៉ោង x ចំនួនម៉ោងដែលបានមន្ថែម x អត្រាប្រាក់បន្ថែមម៉ោង

$$\text{អត្រាប្រាក់ប្រចាំម៉ោង} = \frac{\text{ប្រាក់ខែគោលប្រចាំខែ}}{\text{២៦(ថ្ងៃ)}} \times \text{៨ (ម៉ោង)}$$

ឧទាហរណ៍ៈ កញ្ញា សុភា បានធ្វើការនៅរោងចក្រកាត់ដេរមួយដែលទទួលបានប្រាក់ឈ្នួលគោល១៩០ដុល្លារក្នុងមួយខែ ខែបន្ទាប់ សុភា បានធ្វើការបន្ថែមម៉ោង២ម៉ោងក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃច័ន្ទ ដល់សៅរ៍រយៈពេល១ខែពេញ។

ម៉ោងដែលសុភាបានបន្ថែមរយៈពេលមួយខែនោះគឺ = ២៦(ថ្ងៃ)  x ២ម៉ោង =៥៦ម៉ោង

$$\text{អត្រាប្រាក់ប្រចាំម៉ោង} = \frac{\text{១៩០ដុល្លារ}}{\text{២៦(ថ្ងៃ)}} \times \text{៨(ម៉ោង)} = \text{០.៩១៣ដុល្លារក្នុងមួយម៉ោង}$$

[៩] មាត្រា១៣៩ វក្យខណ្ឌ១, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

អត្រាប្រាក់បន្ថែមម៉ោង ១៥០%[៩]

ប្រាក់បន្ថែមម៉ោងរបស់សុភាគឺ = 0.៩១៣ x ៥៦ x ១៥០% = ៧៦.៦៩២ដុល្លារ

ប្រាក់ខែដែលសុភាទទួលបានដោយបូកបន្ថែមជាមួយប្រាក់បន្ថែមម៉ោងរបស់ សុភា គឺ ២៦៦.៦៩២ដុល្លារ។

**ខ. ប្រាក់បន្ថែមម៉ោងសម្រាប់ការងារពេលយប់**

ចំពោះកម្មករនិយោជិតដែលបន្ថែមម៉ោងនៅចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ភ្លឺ នោះនិយោជកត្រូវផ្តល់ប្រាក់បន្ថែមម៉ោងនោះ ១០០%(មួយរយភាគរយ)[១០] ពីលើប្រាក់ឈ្នួលធម្មតា ដែលត្រូវជា ២០០%(ពីរយភាគរយ) នៃប្រាក់ឈ្នួលធម្មតា។ ការបន្ថែមម៉ោងនេះត្រូវគោរពតាមវិធានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាដាច់ខាត ។ ម្ចាស់គ្រឹះស្ថាន សហគ្រាស រោងចក្រ ក៏ត្រូវមានការធានាជូននូវកន្លែងដំណេក និងមធ្យោបាយធ្វើដំណើរជូនកម្មករនិយោជិតទៅដល់លំនៅឋានដោយសុវត្ថិភាព។

**គ. ប្រាក់បន្ថែមម៉ោងសម្រាប់ថ្ងៃសម្រាកប្រចាំសប្តាហ៍ ឬថ្ងៃបុណ្យ**

នៅពេលដែលដល់ថ្ងៃឈប់សម្រាក ឬថ្ងៃបុណ្យដែលត្រូវសម្រាកពីការងារដែលថ្ងៃបុណ្យនោះត្រូវកំណត់ដោយរាជរដ្ឋាភិបាលនោះជាពេលដែលកម្មករនិយោជិតសម្រាកពីការងារតែដោយសារភាពប្រញាប់បន្ទាន់នៃការងាររបស់គ្រឹះស្ថាន សហគ្រាស រោងចក្រនោះក៏ត្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ឬថ្ងៃបុណ្យនោះ តាមការជូនដំណឹងរបស់និយោជក និងតាមការស្ម័គ្រចិត្តរបស់កម្មករនិយោជិតដោយគ្មានការបង្ខិតបង្ខំឡើយ។ ការបន្ថែមម៉ោងនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ឬថ្ងៃបុណ្យកម្មករនិយោជិតនិងទទួលបានប្រាក់បន្ថែម១០០%(មួយរយភាគរយ)លើប្រាក់ថ្ងៃធម្មតា។

រាល់ការបន្ថែមម៉ោង ទោះបីជាការបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ ការបន្ថែមម៉ោងសម្រាប់ការងារពេលយប់ និងការបន្ថែមម៉ោងនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ឬនៅថ្ងៃបុណ្យនិយោជកត្រូវគោរពតាមវិធានការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅពេលដែលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងដោយស្ម័គ្រចិត្តតាមការសំណូមពររបស់និយោជកនោះនឹងត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០(ពីពាន់)រៀលក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយមិនគិតថ្លៃ[១១]។

[៩] មាត្រា១៣៩, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[១០] មាត្រា១៣៩ វាក្យខណ្ឌ២ ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[១១] សេចក្តីជូនដំណឹងលេខ០៤១/១១កប/ស.ជ.ណ,ចុះថ្ងៃទី ០៧ មីនា ឆ្នាំ២០១១។

### ១.២.២ ប្រាក់កម្រៃជើងសារដែលបន្ថែមលើប្រាក់ឈ្នួល

ប្រាក់កម្រៃជើងសារដែលបន្ថែមលើប្រាក់ឈ្នួល ជាប្រាក់ដែលទទួលបានបន្ទាប់ពីកម្មករនិយោជិតបានសម្រេចការងារជូននិយោជកតាមការកំណត់ នោះកម្មករនិយោជិតនឹងទទួលបានប្រាក់បន្ថែមតាមការសម្រេចការងារនោះ ដែលជាភាគច្រើសម្រាប់បរិមាណផលិតផល។ នៅពេលដែលកម្មករនិយោជិតលក់បានសម្រេចការលក់បានច្រើននោះប្រាក់បន្ថែមនឹងទទួលបានច្រើនតាមនោះដែរ។ ការគិតកម្រៃជើងសារនេះជាទូទៅគឺគិតភាគរយតាមបរិមាណផលិតផលដែលសម្រេចនោះ។ ការទទួលបានប្រាក់កម្រៃជើងសាលុះត្រាតែកម្មករនិយោជិតមានការព្រមព្រៀងគ្នាជាមួយនិយោជកនៅក្នុងកិច្ចសន្យាការងារ។ ដូចនេះកម្មករនិយោជិតត្រូវខិតខំបំពេញការងារឱ្យបានខ្លាំងជាងមុនដើម្បីទទួលបានប្រាក់កម្រៃជើងសារនេះឱ្យកាន់តែច្រើនបន្ថែមលើប្រាក់ខែគោល។ ឧទាហរណ៍ៈ សុ ផុន មានធ្វើការនៅក្រុមហ៊ុនលក់គ្រឿងអេឡិចត្រូនិចមួយដែលទទួលបានប្រាក់ខែគោល២០០ (ពីររយ)ដុល្លារក្នុងមួយខែ ហើយក្រុមហ៊ុននោះមានការកំណត់មួយបើនិយោជិតណាម្នាក់លក់ម៉ាស៊ីនត្រជាក់បាន ៣០ ក្នុង១ខែនឹងទទួលបានប្រាក់កម្រៃជើងសា១០%នៃម៉ាស៊ីនត្រជាក់៣០គ្រឿងនោះ។ ដូចនេះបើ សុ ផុន បានសម្រេចការងារតាមការកំណត់នោះប្រាក់ឈ្នួលរបស់ សុ ផុន គឺ ប្រាក់ឈ្នួលគោលបូកបន្ថែមជាមួយប្រាក់កម្រៃជើងសារដែល សុ ផុន បានសម្រេចនោះ។

### ១.២.៣ ប្រាក់បុព្វលាភ និងប្រាក់បំណាច់

ប្រាក់បុព្វលាភជាប្រភេទមួយនៃប្រាក់ឈ្នួលដែលមាននៅក្នុងច្បាប់ការងារ[១២]។ ប្រាក់បុព្វលាភគឺប្រាក់ដែលនិយោជកត្រូវបង់ធានារ៉ាប់រងគ្រោះថ្នាក់ផ្សេងៗដែលកើតមានក្នុងម៉ោងការងារនិងការថែទាំសុខភាពដល់កម្មករនិយោជិតដែលបេឡាជាតិរបបសន្តិសុខសង្គមជាអង្គភាពមួយដែលនិយោជិតត្រូវបង់ថ្លៃធានារ៉ាប់រងនេះជូន។

ចំពោះប្រាក់បំណាច់ ជាប្រាក់ដែលនិយោជកត្រូវផ្តល់ដល់កម្មករនិយោជិតសម្រាក់ការបើកប្រាក់ផ្តាច់នៅក្នុងករណីដូចជា ប្រាក់បំណាច់អតីតភាពការងារ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ និងប្រាក់ទូទាត់សម្រាប់ការមិនជូនដំណឹង។

#### ក. ប្រាក់បំណាច់អតីតភាពការងារ

ប្រាក់បំណាច់អតីតភាពកាងារ គឺជាប្រាក់បំណាច់ដែលនិយោជកផ្តល់ជូនកម្មករនិយោជិតតាមរយៈពេលដែលកម្មករនិយោជិតបានបំពេញការងារជូននិយោជក។ ការផ្តល់ប្រាក់ចំណាច់អតីតភាពគឺផ្តល់សម្រាប់កម្មករនិយោជិតដែលមានកិច្ចសន្យាមិនកំណត់ចិរវេលា[១៣]។ ប្រាក់បំណាច់អតីតភាពត្រូវបានអនុវត្តចាប់ពីឆ្នាំ

[១២] មាត្រា១០៣, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[១៣] ប្រកាសលេខស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារលេខ៤៤៣ ក.ប/ប្រ.ក.ខ,ចុះថ្ងៃ២១ ខែកញ្ញា ឆ្នាំ២០១៨។

២០១៩ ដែលនិយោជកត្រូវផ្តល់ជូនកម្មករនិយោជិតដែលកំពុងបំពេញការងារនូវប្រាក់បំណាច់អតីតភាពការងារស្មើនឹងប្រាក់ឈ្នួល រួមទាំងប្រាក់បន្ទាប់បន្សំចំនួន១៥(ដប់ប្រាំ)ថ្ងៃក្នុងមួយឆ្នាំដែលត្រូវបើកជូនកម្មករនិយោជិត៖

- ចំនួន ៧,៥(ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនានៃឆ្នាំនីមួយៗ និង
- ចំនួន ៧,៥(ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូនៃឆ្នាំនីមួយៗ។

ការបើកប្រាក់បំណាច់អតីតភាពពីរដងក្នុងមួយឆ្នាំនេះមិនមែនមានន័យថាកម្មករនិយោជិតទាល់តែធ្វើការបានមួយឆ្នាំទើបទទួលបានប្រាក់បំណាច់អតីតភាពនោះទេ។ កម្មករនិយោជិតដែលបានធ្វើការជាប់ជានិច្ចនៅក្នុងឆ្នាំដំបូងចាប់ពី ១(មួយ)ខែ រហូតទៅដល់៦(ប្រាំមួយ)ខែ និយោជកត្រូវផ្តល់ជូនប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥(ប្រាំពីរកន្លះ)ថ្ងៃ។

កម្មករនិយោជិតដែលបានបំពេញការងារមុនឆ្នាំ២០១៩ ហើយកំពុងបម្រើការងារនៅក្នុងគ្រឹះស្ថាន សហគ្រាស រោងចក្រនិយោជកត្រូវបើក **រំលឹកប្រាក់បំណាច់អតីតភាព** សម្រាប់កម្មករនិយោជិតតាមវិធី៖

ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និយោជកត្រូវបើករំលឹកចំនួន៣០(សាមសិប)ថ្ងៃនៃប្រាក់បំណាច់អតីតភាពការងារសរុប រៀងរាល់មួយឆ្នាំម្តងដោយ៖

- ចំនួន ១៥(ដប់ប្រាំ)ថ្ងៃ នៅក្នុងខែមិថុនានៃឆ្នាំនីមួយៗ និង
- ចំនួន ១៥(ដប់ប្រាំ)ថ្ងៃ នៅក្នុងខែធ្នូនៃឆ្នាំនីមួយៗ។

ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកផ្សេងទៀតក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងស្បែកជើង និយោជកត្រូបើករំលឹកចំនួន ១៥(ដប់ប្រាំ)ថ្ងៃនៃប្រាកបំណាច់អតីតភាពសរុបរៀងរាល់មួយឆ្នាំម្តងដោយ៖

- ចំនួន ៧,៥(ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនានៃឆ្នាំនីមួយៗ និង
- ចំនួន ៧,៥(ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូនៃឆ្នាំនីមួយៗ។

ប្រាក់បំណាច់អតីតភាពដែលត្រូវបើករំឭក អតិបរមាមិនត្រូវឱ្យលើស៦(ប្រាំមួយ)ខែនៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗដែលត្រូវរំលឹក។ បើកម្មករនិយោជិតបានបំពេញការងារជាប់ជានិច្ចចាប់ពី១(មួយ)ខែ ទៅដល់៦(ប្រាំមួយ)ខែមុនឆ្នាំ២០១៩ និយោជកត្រូវបើករំលឹកឱ្យកម្មករនិយោជិតនោះនូវប្រាក់បំណាច់អតីតភាពចំនួន ៧,៥(ប្រាំពីរកន្លះ)ថ្ងៃ។ បើចិរវេលាដែលកម្មករនិយោជិតបានធ្វើការលើសពី៦(ប្រាំមួយ)ខែ ត្រូវគិតស្មើនឹង១(មួយ)ឆ្នាំពេញ ហើយនិយោជកត្រូវបើករំលឹកឱ្យកម្មករនិយោជិតនូវប្រាក់បំណាចអតីតភាពចំនួន១៥(ដប់ប្រាំ)ថ្ងៃ។

ដូចនេះកម្មករនិយោជិតដែលធ្វើការងារក្នុងគ្រឹះស្ថាន សហគ្រាស រោងចក្រមុនឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន និងកំពុងបំពេញការងារក្នុងគ្រឹះស្ថាន សហគ្រាសនោះដដែលនឹងទទួលបានប្រាក់បំណាច់អតីតភាពពីរផ្សេងគ្នាគឺ ប្រាក់រំឭកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពក្នុងឆ្នាំនីមួយៗដែលកំពុងធ្វើការនោះ[១៤]។ ប៉ុន្តែកម្មករនិយោជិតណាដែលបានលាឈប់ពីការងារ នឹងមិនទទួលបានប្រាក់រំលឹកអតីតភាពការងារដែលនៅសល់នោះទេ។

❖ ការគណនាប្រាក់បំណាច់អតីតភាពការងារកម្មករនិយោជិតត្រូវគណនាដូចខាងក្រោម[១៥]៖

ជំហានទី១ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមធ្យមក្នុង១ខែ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមធ្យមក្នុងឆមាស}}{\text{៦ខែ ឬតាមតាមចំនួនខែដែលបានធ្វើការជាក់ស្តែង}}$$

ជំហានទី២ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមធ្យមក្នុង១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមធ្យមក្នុង១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$$

(តាមថ្ងៃធ្វើការរបស់គ្រឹះស្ថាន សហគ្រាសនីមួយៗ)

ដូចនេះប្រាក់បំណាច់អតីតភាពការងារដែលទទួលបានក្នុងឆមាសនីមួយៗគឺ

ប្រាក់បំណាច់អតីតភាពក្នុងឆមាសនីមួយៗ=ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមធ្យមក្នុង១ថ្ងៃ x ៧,៥

ចំពោះរយៈពេលដែលត្រូវគិតរាប់ គឺត្រូវគិតចាប់ពីបានចុះកិច្ចសន្យាការងារជាកម្មករនិយោជិតពេញសិទ្ធិ ដោយមិនរាប់បញ្ចូលការងារសាកល្បងទេ ហើយចិរវេលាសម្រាកលំហែមាតុភាព គ្រោះថ្នាក់ការងារ និងឈប់

[១៤] ប្រកាសលេខស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារលេខ៤៤៣ ក.ប/ប្រ.ក.ខ,ចុះថ្ងៃ២១ ខែកញ្ញា ឆ្នាំ២០១៨។

[១៥] សេចក្តីណែនាំស្តីពីការទូទាត់ប្រាក់បំណាចអតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩លេខ០៥៨/១៩ ក.ប/ស.ណ.ន.ខ.ល, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

សម្រាកដោយជម្ងឺក៏ត្រូវរាប់បញ្ចូលជាអតីតភាពការងារដើម្បីគិតប្រាក់បំណាច់អតីតភាពកាងារផងដែរ។ ប៉ុន្តែប្រាក់បន្ទាប់បន្សំ ដែលមានដូចជាតាវកាលិកហានិភ័យការងារ និងតាវការលិកថៃទាំសុខភាពដែលទទួលបានអំឡុងពេលឈប់សម្រាកលំហែមាតុភាព គ្រោះថ្នាក់ការងារ និងឈប់សម្រាកដោយជម្ងឺមិនត្រូវរាប់បញ្ចូលក្នុងការគណនាប្រាក់បំណាច់អតីតភាពការងារទេ។

**ខ.ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា**

នៅពេលដែលកិច្ចសន្យាបានដល់ចិរវេលាត្រូវបញ្ចប់ (សម្រាប់កិច្ចសន្យាកំការងារមានចិរវេលាកំណត់) និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាកបំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនិងប្រាក់ឈ្នួលផង សមាមាត្រនឹងចិរវេលានៃកិច្ចសន្យាការងារផងហើយដែលចំនួនទឹកប្រាក់បំណាច់នេះមានកំណត់ក្នុងអនុសញ្ញារួមបើគ្មានកំណត់ក្នុងអនុសញ្ញារួមទេប្រាក់បំណាច់នេះត្រូវស្មើ៥%(ប្រាំភាគរយ)នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបើកក្នុងរយៈពេលកិច្ចសន្យាការងារនោះ[១៦]។

**គ. ប្រាក់ទូទាត់ចំពោះការជូនដំណឹង**

កិច្ចសន្យាការងារមានចិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន។ ការរំលាយកិច្ចសន្យានេះត្រូវអនុវត្តតាមរបៀបជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាឱ្យ ទៅភាគីម្ខាងទៀត និយោជកអាចរំលាយកិច្ចសន្យាមិនកំណត់បាន លុះត្រាមានហេតុផលសមរម្យដែលពាក់ព័ន្ធទៅនឹងជំនាញ អាកប្បកិរិយារបស់កម្មករនិយោជិត[១៧]។ ចិរវេលាដែលត្រូវជូនដំណឹងជាមុនគឺអាចអនុវត្តបានទាំងកិច្ចសន្យាមានចិរវេលាកំណត់ និងកិច្ចសន្យាមានចិរវេលាមិនកំណត់កាលណានិយោជកបានរំលាយកិច្ចសន្យាការងារទាំងពីរនោះដោយមិនផ្តល់ដំណឹងជាមុន។ ចំពោះចិរវេលាដែលត្រូវជូនដំណឹងគឺៈ

| រយៈពេលការងារ | រយៈពេលជូនដំណឹង |
|---|---|
| តិចជា៦(ប្រាំមួយ)ខែ | ៧(ប្រាំពីរ)ថ្ងៃ |
| ៦(ប្រាំមួយ)ខែ រហូតដល់២(ពី)ឆ្នាំ | ១៥(ដប់ប្រាំ)ថ្ងៃ |
| ២(ពីរ)ឆ្នាំ រហូតដល់៥(ប្រាំ)ឆ្នាំ | ១(មួយ)ខែ |
| លើស៥(ប្រាំ)ឆ្នាំ រហូតដល់១០(ដប់)ឆ្នាំ | ២(ពីរ)ខែ |
| ១០(ដប់)ឆ្នាំឡើងទៅ | ៣(បី)ខែ |

[១៦] មាត្រា៧៣ កថាខណ្ឌ៦ និងវាក្យខណ្ឌ១, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[១៧] មាត្រា៧៤, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

នៅពេលដែលនិយោជកបានបញ្ចប់កិច្ចសន្យាការងារគ្មានចិរវេលាមិនកំណត់ និងកិច្ចសន្យាកាងារមានចិរវេលាកំណត់ដោយមិនបានជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរនិយោជកត្រូវទូទាត់ប្រាក់បំណាច់តាមការអនុវត្តរូបមន្តៈ

| |
|---|
| ប្រាក់ទូទាត់ចំពោះការមិនជូនដំណឹង= (ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ + ប្រាក់អត្ថប្រយោជន៍ក្នុងមួយថ្ងៃ) x ចិរវេលាត្រូវជូនដំណឹងតាមរយៈពេលការងារ |

### ១.២.៤ ប្រាក់សោហ៊ុយជម្ងឺចិត្ត

ប្រាក់សោហ៊ុយជម្ងឺចិត្ត គឺជាប្រាក់ដែលទទួលបានការធ្វើឱ្យខូចប្រយោជន៍ការងារដោយភាគីណាមួយនៅក្នុងកិច្ចសន្យាកការងារដែលភាគីនោះអាចជាកម្មករនិយោជិត និងនិយោជកដែលបណ្តាលមកពីការរំលាយកិច្ចសន្យាការងារ។ ការរំលាយកិច្ចសន្យាការងារតាមភាគីណាមួយដែលគ្មានហេតុផលត្រឹមត្រូវនោះអាចបើកសិទ្ធិឱ្យភាគីម្ខាងទៀតទាមទារសងសោហ៊ុយជម្ងឺចិត្តបាន[១៨]។ សោហ៊ុយជម្ងឺចិត្តមិនត្រូវច្រឡំគ្នាជាមួយប្រាក់បំណាច់ជួសឱ្យការជូនដំណឹងមុន ឬ ជាមួយប្រាក់បំណាច់អតីតភាពទេ។ សោហ៊ុយជម្ងឺចិត្តមានពីរប្រភេទគឺសោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាការងារដែលមានចិរវេលាកំណត់ និងសោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាការងារដែលមិនមានចិរវេលាកំណត់ ។

#### ក.ប្រាក់សោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាការងារមានចិរវេលាកំណត់

ការរំលាយកិច្ចសន្យាការងារដែលមានចិរវេលាកំណត់ដោយនិយោជកមុនការកំណត់កម្មករនិយោជិតមានសិទ្ធិទទួលបានសោហ៊ុយជម្ងឺចិត្តពីនិយោជកដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវបានទទួលរហូតដល់ពេលបញ្ចប់កិច្ចសន្យាការងារ[១៩]។ ការរំលាយកិច្ចសន្យាការដែលធ្វើដោយកម្មករនិយោជកសម្រាប់កិច្ចសន្យាការងារមានចិរវេលាកំណត់តែឯកឯង និយោជកមានសិទ្ធិទទួលប្រាក់សោហ៊ុយជម្ងឺចិត្ត និងការខូចខាតដែលខ្លួនបានផ្តល់ឱ្យកម្មករនិយោជិត[២០]។

[១៨] ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ចំណងជើងចំណុច(គ) ផ្នែកទី៣នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា ១១០ មាត្រា១២០ និងមាត្រា១២២នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧ /០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ លេខ នស/រកម/០៦១៨/០១០,ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[១៩] មាត្រា៧៣ កថាខណ្ឌ៣, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[២០] មាត្រា៧៣ កថាខណ្ឌ៤, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

**ខ.ប្រាក់សោហ៊ុយជម្ងឺចិត្តសម្រាប់កិច្ចសន្យាការងារមិនមានពេលកំណត់**

កិច្ចសន្យាការងារដែលមិនមានថិរវេលាកំណត់ដែលត្រូវបានរំលាយដោយឆន្ទៈនិយោជកតែម្ខាង កម្មករនិយោជិតអាចទាមទារបើកផ្ដាច់ប្រាក់បំណាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់អតីតភាពដែលបាន និងត្រូវទទួលបានកំឡុងពេលនៃកិច្ចសន្យាការងារ[២១]។

សម្គាល់ៈ រាល់ការបញ្ឈប់កម្មករនិយោជិតដោយមិនមានហេតុផលត្រឹមត្រូវ កម្មករនិយោជិតត្រូវទទួលបាន៖

- ប្រាក់ឈ្នួលដែលមិនទាន់បានបើក។
- ប្រាក់បំណាច់ជួសការជូនដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមការកំណត់របស់ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។
- ប្រាក់បំណាច់ជួសផលការឈប់សម្រាកដែលនៅសល់កាលបើកម្មករនិយោជិតមិនបានឈប់សម្រាកដោយយោងតាមច្បាប់ការងារ១៩៩៧មាត្រា១៦៦។
- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ពីការងារស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ៧ថ្ងៃ បើកម្មករនិយោជិតនៅសល់អតីតភាពការងារចាប់ពី១ខែ ដល់ក្រោម៦ខែ។
- ប្រាក់បំណាច់អតីតភាពមុនឆ្នាំ២០១៩សរុប ដែលនិយោជកមិនទាន់បើកផ្ដល់។

ក្រៅពីចំណុចខាងលើកម្មករនិយោជិតក៏អាចទាមទារសោហ៊ុយជម្ងឺចិត្តដែលស្មើនឹងប្រាក់បំណាច់អតីតភាពការងារ ដែលកម្មករនិយោជិតត្រូវទទួលបាន ប៉ុន្តែមិនត្រូវលើសប្រាក់ឈ្នួល និងប្រាក់ឈ្នួលបន្ទាប់បន្សំចំនួន៦ខែនោះឡើយ[២២]។

**១.២.៥ ភាគកម្មក្នុងប្រាក់ចំណេញ**

នៅពេលដែលគ្រឹះស្ថាន សហកគ្រាស រោងចក្រណាទទួលបានប្រាក់ចំណេញប្រចាំឆ្នាំហើយបានបែងចែកមួយភាគជូនកម្មករនិយោជិតបន្ថែមលើប្រាក់ឈ្នួលនោះគឺជាភាគកម្មដែលគ្រឹះស្ថាន សហគ្រាស រោងចក្រផ្ដល់

[២១] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា៨៧ចំណងជើងចំណុច(គ) ផ្នែកទី៣នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២នៃច្បាប់ស្ដីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧ /០១,ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ លេខ នស/រកម/០៦១៨/០១០,ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨,កថាខណ្ឌ ៣។

[២២] សេចក្ដីណែនាំស្ដីពីការទូទាត់ប្រាក់បំណាចអតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩លេខ០៥៨/១៩ ក.ប/ស.ណ.ន.ខ.ល, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

ជូនកម្មករនិយោជិតដែលហៅថាប្រាក់ភាគកម្មប្រាក់ចំនេញដែលផ្តល់ជូនកម្មករករនិយោជិត។ ជាទូទៅនិយោជក ម្ចាស់គ្រឹះស្ថាន សហគ្រាស រោងចក្រផ្តល់ប្រាក់ចំណេញនេះជាភាគរយដល់កម្មករនិយោជិត។

### ១.២.៦ ប្រាក់ដែលបើកជាប្រាក់រង្វាន់

ប្រាក់ដែលបើកជាប្រាក់រង្វាន់ ជាប្រភេទប្រាក់ឈ្នួលបន្ទាប់បន្សំមួយដែលនិយោជក ម្ចាស់សហគ្រាស រោងចក្រផ្តល់ជូនកម្មករនិយោជិតបន្ថែមលើប្រាក់ឈ្នួលដើម្បីជាការលើកទឹកចិត្តដល់ការខំប្រឹងប្រែងធ្វើការងាររបស់កម្មករនិយោជិត។ គេសង្កេតឃើញថាប្រាក់ដែលបើកជាប្រាក់រង្វាន់មានពីរប្រភេទគឺប្រាក់សម្រាប់ការងារទៀងទាត់ប្រចាំខែ និងប្រាក់អតីតភាពប្រចាំឆ្នាំ។

នៅពេលដែលកម្មករនិយោជិតវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងបានធ្វើការងារទៀងទាត់គ្មានអវត្តមាន ប្រាក់ដែលបើកជារង្វាន់និយោជក ម្ចាស់គ្រឹះស្ថាន រោងចក្រ ត្រូវផ្តល់យ៉ាងតិច១០(ដប់)ដុល្លារក្នុងមួយខែ។ ការកំណត់នេះនិយោជកអាចពិភាក្សាក្នុងក្រុមហ៊ុនរបស់ខ្លួនផងដែរពីការកំណត់ប្រាក់រង្វាន់ប្រចាំខែនេះ តែមិនត្រូវទាបជាង១០(ដប់)ដុល្លារឡើយ។ បើក្រុមហ៊ុនណាដែលបានកំណត់លើសពី១០(ដុល្លារ)សម្រាប់ប្រាក់រង្វាន់ប្រចាំខែនេះមុនថ្ងៃ ០២ មករា ២០១៤ត្រូវរក្សាទុកប្រាក់រង្វាន់ប្រចាំខែនេះទុកនៅដដែល[២៣]។

សម្រាប់ប្រាក់រង្វាន់អតីតភាពការងារវិញគឺនិយោជកត្រូវផ្តល់ជូនកម្មករនិយោជិតតាមរយៈពេលដែលបានបំពេញការងារក្នុងលើសពីមួយឆ្នាំ ដែលប្រាក់រង្វាន់អតីតភាពការងារនេះមានដូចក្នុងតារាងខាងក្រោម[២៤]៖

| អតីតភាពការងារគិតជាឆ្នាំ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | ០៩ | ១០ | ១១ |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនទឹកប្រាក់ដែលទទួលបាន ក្នុងមួយខែគិតជាដុល្លារ | 0$ | ២$ | ៣$ | ៤$ | ៥$ | ៦$ | ៧$ | ៨$ | ៩$ | ១0$ | ១១$ |

[២៣] សេចក្តីនែនាំស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និអត្ថប្រយោជន៍ផ្សេងៗលេខ០០១/១៤ ក.ប/ស.ជ.ណ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤។

[២៤] សេចក្តីនែនាំស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និអត្ថប្រយោជន៍ផ្សេងៗលេខ០០១/១៤ ក.ប/ស.ជ.ណ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤។

### ១.២.៧ តម្លៃអត្ថប្រយោជន៍ជាវត្ថុ

តម្លៃអត្ថប្រយោជន៍ជាវត្ថុជាប្រភេទមួយនៃប្រាក់ឈ្នួល ដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិតជាវត្ថុសម្រាប់ប្រើប្រាស់នៅក្នុងគ្រឹះស្ថាន សហគ្រាស រោងចក្រដែលកម្មករនិយោជិតធ្វើការឱ្យខ្លួនព្រោះជាតម្រូវការសម្រាប់កម្មករនិយោជិតក្នុងការបំពេញការងារ និងដើម្បីជាប្រយោជន៍សម្រាប់និយោជកផងដែរ។ នៅពេលដែលនិយោជកបានផ្តល់វត្ថុនេះជូនកម្មករនិយោជិត កម្មករនិយោជិតក៏អាចយកវត្ថុនេះទៅប្រើប្រាស់ក្នុងការងាររបស់ខ្លួនផងដែរ។

ឧទាហរណ៍ៈ កម្មករសំណង់ ត្រូវទទួលបានសម្លៀកបំពាក់ការពារ មួក អាវ ស្បែកជើងជាដើមក្នុងពេលបំពេញការងារ ។

### ១.២.៨ ប្រាក់ទទួលបានក្នុងពេលលំហែមាតុភាព

ប្រាក់ដែលទទួលបានក្នុងពេលលំហែមាតុភាពគឺ ត្រូវផ្តល់ជូនកម្មកករនិយោជិតដែលជាស្ត្រីក្នុងរយៈពេលដែលខ្លួនត្រូវឈប់សម្រាកដើម្បីសម្រាលកូន។ ការសម្រាកលំហែមាតុភាពនេះគឺសម្រាកមុន និងក្រោយពេលសម្រាលបុត្រ និងមានរយៈពេល៩០(កៅសិប)ថ្ងៃ។ នៅពេលដែលកម្មករនិយោជិតជាស្ត្រីសម្រាកលំហែមាតុភាពនេះគឺជាការសម្រាកដែលទទួលប្រាក់ឈ្នួល។ ប្រាក់សម្រាកលំហែមាតុភាពនេះគឺមានពីរប្រភេទគឺ មួយទទួលបានត្រូវផ្តល់និយោជក ឬម្ចាស់គ្រឹះស្ថាន សហគ្រាស រោងចក្រផ្តល់ជូនចំនួន ៥០%(ហាសិបភាគរយ) នៃប្រាក់ឈ្នួលសុទ្ធសាធ គិតទាំងប្រាក់ឈ្នួលបន្ទាប់បន្សំ សម្រាប់កម្មករនិយោជិតជាស្ត្រីដែលបានធ្វើការក្នុង គ្រឹះស្ថាន សហគ្រាស រោងចក្រនោះរយៈពេលយ៉ាងតិច ១ឆ្នាំ[២៥]។ ទទួលបានប្រាក់ចំនួន៧០%(ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម។ ការទទួលបានប្រាក់លំហែមាតុភាពពីបេឡាជាតិរបបសន្តិសុខសង្គមនេះគឺសម្រាប់កម្មករនិយោជិតជាស្ត្រីដែលបានបង់ភាគទានចំនួន ៩(ប្រាំបួន)ខែជាប់គ្នាជូនបេឡាជាតិរបបសន្តិសុខសង្គម[២៦]។ ដូចនេះកម្មករនិយោជិតជាស្ត្រីអាចទទួលបានប្រាក់សម្រាកលំហែមាតុភាពចំនួនពីរប្រសិនបើត្រឹមត្រូវតាមលក្ខខណ្ឌទាំងពីរខាលើនេះដែលស្មើនឹង១២០%(មួយរយម្ភៃភាគរយ) ដែល៥០%(ហាសិភាគរយ)បានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន សហគ្រាស រោចក្រ និង៧០%(ចិតសិបភាគរយ)ទទួលបានពីបេឡាជាតិរបបសន្តិសុខសង្គម។

មួយវិញទៀតកម្មករនិយោជិតជាស្ត្រីដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)ដែលបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈត្រូវទទួលបានប្រាក់ឧបត្ថមបន្ថែមទៀតដូចខាងក្រោមៈ

[២៥] មាត្រា១៨៣, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[២៦] ប្រកាសស្តីពី គាវកាលិថៃទាសុភាព,លេខ១០៩ ក.ប/ប្រ.ក,ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧,ប្រការ៦ និងប្រការ៧។

- សម្រាលកូនទោល (មួយ) ទទួលបានប្រាក់ ៤០០ ០០០(បួនសែន)រៀល។
- សម្រាលកូនភ្លោះ (ពីរ) ទទួលបានប្រាក់ ៨០០ ០០០(ប្រាំបីសែនរៀល។
- សម្រាលកូនភ្លោះ (បី) ទទួលបានប្រាក់១ ២០០ ០០០(មួយលានពីរសែនរៀល។

ប្រាក់ឧបត្ថមនេះ ត្រូវផ្តល់ជូនដោយ ប.ស.ស ក្រោយសម្រាលកូនទោះបីជាទារករស់ ឬក៏ស្លាប់ក៏ដោយ[៣៤]។

### ១.៣ ប្រាក់វិភាជន៍

ប្រាក់វិភាជន៍ក៏ជាប្រភេទមួយនៃប្រាក់ឈ្នួលដែលស្ថិតនៅក្នុងច្បាប់ការងារ១៩៩៧ មាត្រា១០៣ដែរ ។ ប្រាក់វិភាជន៍ ជាប្រាក់បន្ថែមលើប្រាក់ឈ្នួលកម្មករនិយោជិតផ្តល់ដោយនិយោជក ដែលប្រាក់វិភាជន៍មានពីរ គឺ ប្រាក់គ្រួសារសម្រាប់ភាគដែលលើកទឹកចិត្តត្រឹមត្រូវតាមច្បាប់ និងប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក ឬ បំណាច់ទូទាត់ការឈប់សម្រាក។

#### ១.៣.១ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់

ប្រាក់វិភាជន៍គ្រួសារនេះគឺជាប្រាក់ដែលកម្មករនិយោជិតផ្តល់ឱ្យកម្មករនិយោជិតជាប្រាក់លើកទឹកចិត្តឬហៅម្យ៉ាងទៀតជាប្រាក់ឧបត្ថមដល់ក្រុមគ្រួសារកម្មករនិយោជិត។ ថ្វីត្បិតតែមានចែងនៅក្នុងច្បាប់ការងារក៏ដោយ តែគ្រាន់តែជាចំណុចមួយប៉ុណ្ណោះមិនមានបទបញ្ញត្តិណាចែងឱ្យច្បាស់លាស់នោះទេថាប្រាក់វិភាជន៍គ្រួសារនេះត្រូវកំណត់ឱ្យនិយោជកផ្តល់ជូនកម្មករនិយោជិតប៉ុន្មាន? និងត្រូវគោរពតាមលក្ខខណ្ឌអ្វីខ្លះ? គឺមានតែការអនុវត្តតាមគ្រឹះស្ថាន សហគ្រាស ឆាងចក្រមួយចំនួនហើយត្រូវបានកំណត់ដោយនិយោជក ឬ ម្ចាស់សហគ្រាសនិងកម្មករនិយោជិតដែលមានកំណត់ក្នុងកិច្ចសន្យាការងារ។ ឧទាហរណ៍៖ ធនាគា អេស៊ីលីដា ភីអិលស៊ី (ACELEDA Bank Plc) បានផ្តល់ប្រាក់វិភាជន៍គ្រួសារជូន និយោជិតរបស់ខ្លួននូវប្រាក់ឧបត្ថមដល់កូនក្នុងបន្ទុកច្រើនបំផុត៤(បួន)នាក់ សម្រាប់កម្មករពេញសិទ្ធិ។

#### ១.៣.២ ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក ឬប្រាក់បំណាច់ទូទាត់ការឈប់សម្រាក

ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក ឬ ប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាកគឺប្រាក់ដែលកម្មករនិយោជិតទទួលបាននៅពេលដែលខ្លួនបានឈប់សម្រាកតាមច្បាប់ការងារកំណត់ពីនិយោជក ដែលថ្ងៃឈប់សម្រាកតាមច្បាប់នោះមានបីប្រភេទគឺ ការឈប់សម្រាកថ្ងៃបុណ្យដែលត្រូវទទួលបានប្រាក់ឈ្នួល ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល និងការឈប់សម្រាកពិសេស។

##### ក.ការឈប់សម្រាកថ្ងៃបុណ្យដែលត្រូវទទួលបានប្រាក់ឈ្នួល

ការឈប់សម្រាកថ្ងៃបុណ្យដែលទទួលបានប្រាក់ឈ្នួលគឺ ជាការឈប់សម្រាកដែលត្រូវបានកំណត់ជារៀងរាល់ឆ្នាំដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) សម្រាប់កម្ម

ករនិយោជិតនៃសហគ្រាសទាំងអស់[២៧]។ ហើយការឈប់សម្រាកពីមួយឆ្នាំទៅមួយឆ្នាំមិនដូចគ្នាទេទៅតាមកាលៈទេសៈសង្គមជាក់ស្តែង យ៉ាងណាមិញដូចជានៅឆ្នាំ២០១៧ថ្ងៃឈប់សម្រាកសរុបមានចំនួន២៧(ម្ភៃប្រាំពីរ) ថ្ងៃ នៅក្នុងឆ្នាំ២០១៨ថ្ងៃសម្រាកសរុបចំនួន២៨(ម្ភៃប្រាំបី)ថ្ងៃ នៅក្នុងឆ្នាំ២០១៩ថ្ងៃឈប់សម្រាកសរុបចំនួន២៨(ម្ភៃប្រាំបី)ថ្ងៃ ដោយឡែកនៅក្នុងឆ្នាំ២០២០នេះការឈប់សម្រាកសរុបនោះគឺមានតែ២២(ម្ភៃពីរ)ថ្ងៃ[២៨]ប៉ុណ្ណោះ ប៉ុន្តែការឈប់នៅពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ ឆ្នាំជូត ទោស័កនៅក្នុងឆ្នាំ២០២០ត្រូវបានលើកពេលឈប់សម្រាកដោយរដ្ឋាភិបាលកម្ពុជាផ្អាកក្នុងគោលបំណងដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីត១៩ ព្រោះជាកាលៈទេសៈសង្គមដែលត្រូវធានាឱ្យបាននូវសុខមាលភាពប្រជាជនទូទាំងប្រទេស រួមទាំងកម្មករនិយោជិតផងដែរ។ ការលើកពេលឈប់សម្រាកនេះនឹងត្រូវសងជូនកម្មករនិយោជិតវិញនៅពេលសមស្របណាមួយចំនួន៥(ប្រាំ)ថ្ងៃ[២៩]។ ដូចនេះការឈប់សម្រាកនៅក្នុងឆ្នាំ២០២០សរុបគឺ២៣(ម្ភៃបី)ថ្ងៃ ដែលការឈប់សម្រាកនេះជាការឈប់សម្រាកមានប្រាក់ឈ្នួល។

ចំពោះថ្ងៃឈប់ម្រាកបុណ្យទាំងឡាយណាដែលត្រូវនឹងថ្ងៃអាទិត្យនោះកម្មករនិយោជិតត្រូវឈប់សម្រាកមួយថ្ងៃបន្តទៀត។ ថ្ងៃឈប់សម្រាកទាំងឡាយនេះ មិនផ្តាច់ចិរវេលាធ្វើការដែលត្រូវគិតដើម្បីឱ្យឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលទេ ហើយក៏មិនត្រូវកាត់បន្ថយថ្ងៃឈប់សម្រាកប្រចាំឆ្នាំនោះដែរ[៣០] មួយវិញទៀតសម្រាប់កម្មករនិយោជិតដែលធ្វើការតាមម៉ោង ប្រចាំថ្ងៃ ឬតាមបរិមាណផលិតផលត្រូវមានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលខាតបង់មកពីការឈប់ថ្ងៃបុណ្យដែលកំណត់រាល់ឆ្នាំដោយក្រសួងទទួលបន្ទុកវិស័យការងារនោះ ហើយប្រាក់បំណាច់នេះជាបន្ទុករបស់និយោជក[៣១]។

### ខ.ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល

កម្មករនិយោជិតដែលធ្វើការងារជាប់លាប់ត្រូវទទួលបានការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល។ ការងារជាប់លាប់នេះសំដៅទៅលើការងារដែលប្រព្រឹត្តទៅទោះជាមិនទៀងទាត់យ៉ាងតិចក្នុងរយៈពេល២១(ម្ភៃមួយ)ថ្ងៃក្នុងមួយ១ខែរយៈពេលមួយឆ្នាំពេញនោះជាការងារទៀងទាត់។ ការឈប់សម្រាកដែលមានប្រាក់ឈ្នួលនេះ

[២៧] មាត្រា១៦១, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[២៨] ប្រកាសស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០២០,លេខ៣៩៩/១៩ ក.ប/ប្រ.ក.អ.ធ.ក,ចុះថ្ងៃទី០៤ ខែតុលាឆ្នាំ ២០១៩។

[២៩] សេចក្តីជូនដំណឹងស្តីពីការលើកថ្ងៃឈប់សម្រាកក្នុងបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០,លេខ០១២/២០ ក.ប/ស.ជ.ណ.ខ.ល, ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។

[៣០] មាត្រា១៦១, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៣១] មាត្រា១៦៣, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

និយោជកត្រូវផ្តល់ជូនកម្មករនិយោជិតចំនួន១,៥ថ្ងៃ(មួយថ្ងៃកន្លះ) ដែលស្មើនឹង១៨ថ្ងៃក្នុងមួយឆ្នាំ។ ចិរវេលានេះនឹងត្រូវបន្ថែមមួយថ្ងៃឱ្យកម្មករនិយោជិតដែលមានអតីតភាពការងារ៣(បី)ឆ្នាំ ដូចនេះសម្រាប់កម្មករនិយោជិតដែលធ្វើការបាន៣(បី)ឆ្នាំនឹងទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួលប្រចាំឆ្នាំចំនួន១៩(ដប់ប្រាំបួន) ថ្ងៃ ដែលត្រូវគិតរាល់បីឆ្នាំម្តង។ កម្មករនិយោជិតដែលមិនបានធ្វើការងារចំនួន២(ពីរ)ខែបន្តបន្ទាប់ទេ មានសិទ្ធិទទួលបាននៅពេលផ្តាច់កិច្ចសន្យាការងារ ដែលទទួលបានប្រាក់បំណាច់ឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលដោយគិតជាមសមាត្រនឹងពេលវេលាដែលបានធ្វើការនៅក្នុងសហគ្រាស។ ថ្ងៃបុណ្យតាមច្បាប់ដែលត្រូវឈប់សម្រាកដោយមានប្រាក់ឈ្នួល និងការអាក់ខានធ្វើការដោយហេតុមានជម្ងឺ មិនត្រូវរាប់បញ្ចូលជាថ្ងៃឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលនោះទេ ហើយចំពោះលក្ខខណ្ឌដែលត្រូវទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួលនេះគឺកម្មករនិយោជិត្រូវធ្វើការគ្រប់មួយឆ្នាំទើបមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ។ និយោជកក៏អាចពន្យាការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនេះបានដែលការពន្យានេះមិនអាចលើសពី៣(បី)ឆ្នាំនោះទេ ហើយអាចអនុវត្តបានតែចំពោះភាគនៃកាឈប់សម្រាកណាដែលហួសពី១២(ដប់ពី)ថ្ងៃ ដែលជាថ្ងៃធ្វើការក្នុងមួយឆ្នាំ។ ក្នុងករណីដែលមានការផ្តាច់ ឬ ចប់កិច្ចសន្យាមុន ដែលកម្មករនិយោជិតទទួលបានសិទ្ធិឈប់សម្រាកនោះ ត្រូវសងប្រាក់បំណាច់ទៅកម្មករនិយជិតតាមសមមាត្រខាងលើ។ អនុសញ្ញារួមណាដែលមានគ្រោងឱ្យប្រាក់បំណាច់ដោយទូទាត់សម្រាប់ជួសការឈប់សម្រាកព្រមទាំងការព្រមព្រៀងដែលស្តីពីការបោះបង់ ឬមិនព្រមបម្រើសិទ្ធិឈប់សម្រាកប្រចាំឆ្នាំត្រូវចាត់ទុកជាមោឃៈ ហើយគ្មានហេតុផល កម្មករនិយោជិតដែលព្រមសុខចិត្តលើសិទ្ធិឈប់សម្រាកខ្លះ ឬ ទាំងមូលទៅប្រើនៅពេលចប់កិច្ចសន្យា មិនត្រូវទុកជាការលះបង់សិទ្ធិទេ[៣២]។ តាមគោលការណ៍ការឈប់សម្រាកប្រចាំឆ្នាំ ត្រូវអនុវត្តនៅពេលបុណ្យចូលឆ្នាំខ្មែរ លើកលែងតែមានកិច្ចព្រមព្រៀងលើពេលណាមួយទៀត រវាងនិយោជក និងកម្មករនិយោជិត។ ក្នុងករណីនេះ និយោជកត្រូវតែជូនដំណឹងជាមុនទៅអធិការងារដែលបានស្រុះស្រួលគ្នានោះ។ ក្នុងករណីដែលការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលមានចិរវេលាច្រើនជាង១៥(ដប់ប្រាំ)ថ្ងៃនោះ និយោជកមានសិទ្ធិទុកថ្ងៃឈប់សម្រាកដែលនៅសល់ប៉ុន្មានឱ្យឈប់ក្នុងពេលណាមួយផ្សេងទៀតក្នុងឆ្នាំនោះ លើកលែងតែចំពោះការឈប់សម្រាកនៃការងារក្មេងៗ និងកូនជាងដែលមានអាយុតិចជាង ១៨(ដប់ប្រាំបីឆ្នាំ)[៣៣]។

---

[៣២] មាត្រា១៦៦ និងមាត្រា១៦៧, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៣៣] មាត្រា១៧០, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

### គ.ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល

ការឈប់សម្រាកពិសេសគឺជាការឈប់សម្រាកដែលនិយោជកមានសិទ្ធិអនុញ្ញាតឱ្យកម្មករនិយោជិតខ្លួន ឈប់សម្រាកជាពិសេសក្នុងពេលមានព្រឹត្តិការណ៍ដែលប៉ះពាល់ដល់ក្រុមគ្រួសាររបស់ខ្លួនដូចជា ការរៀបពាពាហ៍ពិពាហ៍ខ្លួនផ្ទាល់ ប្រពន្ធសម្រាលកូន រៀបអាពាហ៍ពិពាហ៍កូន ឬ ប្ដី ប្រពន្ធ កូន ឪពុក ម្ដាយមានជម្ងឺ ឬ មរណភាព និយោជកអាចឱ្យកម្មករនិយោជិតឈប់សម្រាកដោយមានប្រាក់ឈ្នួលចំនួន៧(ប្រាំពីរ)ថ្ងៃក្នុងមួយឆ្នាំ។ និយោជកអាចធ្វើការកាត់កងការឈប់សម្រាកពិសេសនេះ ពិការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត បើកម្មករនិយោជិតមិនទាន់អនុវត្តការឈប់សម្រាកប្រចាំឆ្នាំរបស់ខ្លួនអស់ទេ ឬ អាចតម្រូវឱ្យកម្មរនិយោជិតធ្វើការសងវិញ បើកម្មករនិយោជិតនោះបានអនុវត្តការឈប់សម្រាកប្រចាំឆ្នាំរបស់ខ្លួនអស់ហើយ[៣៤]។ ចំពោះការធ្វើការសងវិញនេះអាចអនុវត្តបានតែក្នុងរយៈពេល៩០ថ្ងៃក្រោយថ្ងៃឈប់សម្រាកពិសេស។ ការធ្វើការសងត្រូវអនុវត្តក្នុងថ្ងៃធ្វើការធម្មតា និងក្នុងលក្ខខណ្ឌដែលថិរវេលាធ្វើការសរុបមិនលើសពី១០(ដប់)ម៉ោងក្នុងមួយថ្ងៃ ឬ ៥៤(ហាសិបបួន)ម៉ោងក្នុងមួយសប្ដាហ៍។ មានន័យថាកម្មករនិយោជិតធ្វើការសងបានត្រឹមតែ ៦(ប្រាំមួយ)ម៉ោងប៉ុណ្ណោះក្នុងមួយសប្ដាហ៍ នឹងត្រូវទទួលបានប្រាក់ឈ្នួលតាមអត្រាប្រាក់ឈ្នួលម៉ោងការងារធម្មតា។ ប្រសិនបើការងារលើសពី ៥៤(ហាសិបបួន)ម៉ោងក្នុងមួយសប្ដាហ៍ថិរវេលាដែលលើសនោះ និយោជកត្រូវផ្ដល់អត្រាដំឡើងដែលកំណត់ដោយច្បាប់ការងារ[៣៥]។

## ផ្នែកទី២៖ ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បបរមា

ក្រៅពីប្រាក់ឈ្នួលសុទ្ធសាធ និងប្រាក់ឈ្នួលបន្ទាប់បន្សំមានប្រាក់ពីប្រភេទទៀតដែលមានកម្មករនិយោជិតត្រូវទទួលបានគឺប្រាក់ដែលមិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បរមាដែលត្រូវធានា ។

### ២.១ ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល

ប្រាក់ដែលមិនរាប់បញ្ចូលជាប្រាក់ឈ្នួលកម្មករនិយោជិតបានដូចជា ការព្យាបាលសុខភាព វិភាជន៍គ្រួសារតាមច្បាប់ សោហ៊ុយធ្វើដំណើរ អត្ថប្រយោជន៍ដែលផ្ដល់ឱ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសម្រួលការបំពេញការងារ និងប្រាក់ធនានុគ្រោះ។

#### ២.១.១ ការព្យាបាលសុខភាព

ប្រាក់សម្រាប់ការព្យាបាលសុខភាព ឬប្រាក់ឧបត្ថមថែទាំសុខភាពត្រូវបានផ្ដល់ជូនកម្មករនិយោជិត

[៣៤] ប្រកាសស្ដីពីការឈប់សម្រាកពិសេស,លេខ២៦៧ សកបយ,ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១។

[៣៥] សេចក្ដីណែនាំស្ដីពីការអនុវត្តការសងការឈប់សម្រាកពិសេស,លេខ០១០/២០ ក.ប/ស.ណ.ន.ខ.ល,ចុះថ្ងៃ២១ ខែកុម្ភៈ ឆ្នាំ២០២០។

វាយកណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន៥$(ប្រាំដុល្លារ)ក្នុងមួយខែ។ ហើយសម្រាប់កម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមនឹងទទួលបានសេវាថែទាំសុខភាព ដោយឥតគិតថ្លៃរាល់ពេលដែលកម្មករនិយោជិតប្រើសេវាថែទាំសុខភាពនៅបណ្តាមន្ទីរពេទ្យ និងមន្ទីរពហុព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។

**២.១.២ វិភាជន៍សម្រាប់គ្រួសារ**

វិភាជន៍សម្រាប់គ្រួសារ មិនត្រូវបានរាប់បញ្ចូលជាប្រាក់ឈ្នួលកម្មករនិយោជិតទេ។ វិភាជន៍គ្រួសារនេះជាក់ស្តែងមិនទាន់បានអនុវត្តឱ្យទូលំទូលាយទេ មានតែសហគ្រាស គ្រឹះស្ថានខ្លះតែប៉ុណ្ណោះ។

**២.១.៣ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ**

សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅគឺ និយោជកជាអ្នកផ្តល់ជូនកម្មករនិយោជិតដែលប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅមិនត្រូវរាប់បញ្ចូលជាប្រាក់ឈ្នួលកម្មករនិយោជិតទេ។ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនិយោជកត្រូវផ្តល់ជូនកម្មករនិយោជិតក្នុងចំនួនទឹកប្រាក់៧(ប្រាំពីរ)ដុល្លារក្នុងមួយខែ[៣៦] ការផ្តល់នេះគឺសម្រាប់តែសហគ្រាស រោងចក្រណាដែលមិនបានផ្តល់មធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតតែប៉ុណ្ណោះ។ តែបើក្នុងកិច្ចសន្យាការងាររវាងកម្មករនិយោជិត និងនិយោជកតែផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅប្រសើរជាងនេះត្រូវរក្សាទុកនៅដដែរ។

**២.១.៤ ប្រាក់ធនានុគ្រោះ**

ប្រាក់ធនានុគ្រោះ គឺជាកម្រៃដែលអតិថិជនឱ្យទៅបុគ្គលិក សហគ្រាសខ្លះដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់កាហ្វេ ហាងភេសជ្ជៈ ហាងកាត់សក់ជាដើមហើយដែលនិយោជកបានទទួលជាភាគរយដែលត្រូវបន្ថែមលើកំណត់ទាប្រាក់ពីអតិថិជនក្រោមចំណារសម្គាល់ថា «សម្រាប់សេវា» ។ ប្រាក់ធនានុគ្រោះនេះមិនកំណត់ទេគឺអតិថិជនឱ្យតាមទឹកចិត្ត។ នៅពេលដែលនិយោជកប្រមូលពីបានកម្មករនិយោជិតហើយត្រូបើឱ្យកម្មករនិយោជិតវិញទាំងអស់[៣៧]។ ប្រាក់ធនានុគ្រោះនេះមិនមែនជាប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ ព្រោះមិនមែនជាឈ្នួលការងារ ឬ ឈ្នួលសេវាអ្វីនោះទេ ហើយក៏មិនស្ថិតក្រោមនិយមន័យប្រាក់ឈ្នួលក្នុងមាត្រា១០២ នៃច្បាប់ការងារនោះដែរ។

[៣៦] សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រក,ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣,ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ,លេខ០០១/១៤ ក.ប/ស.ណ.ន,ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤។

[៣៧] មាត្រា១៣៤, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

### ២.១.៥. អត្ថប្រយោជន៍សម្រាប់សម្រួលការងារដល់កម្មករនិយោជិត

អត្ថប្រយោជន៍សម្រាប់សម្រួលការងារកម្មករនិយោជិត គឺជាប្រាក់ដែលនិយោជកផ្តល់ជូនកម្មករនិយោជិតក្នុងការផ្តល់ភាពងាយស្រួលក្នុងការបំពេញការងាររបស់កម្មករនិយោជិត និងដើម្បីជាប្រយោជន៍របស់និយោជកផងដែរ។ ការផ្តល់នេះគឺមិនត្រូវបានរាប់បញ្ចូលជាប្រាក់ឈ្នួលនោះទេ។ កម្មករនិយោជិតអាចយកអត្ថប្រយោជន៍នេះធ្វើជាប្រយោជន៍ក្នុងការបំពេញការងាររបស់ខ្លួនបាន។ អត្ថប្រយោជន៍សម្រាប់សម្រួលការងារកម្មករនិយោជិតនេះអាចមានដូចជា ប្រេងសាំង ទូរស័ព្ទ កាតទូរស័ព្ទ ប្រាក់ស្នាក់នៅពេលចុះការងារឆ្ងាយជាដើម។ អត្ថប្រយោជន៍នេះមិនដូចគ្នាទេគឺអាស្រ័យតាមប្រភេទការងារ និងមិនត្រូវបានផ្តល់សម្រាប់ការងារទាំងអស់ទេ។

## ២.២ ប្រាក់ឈ្នួលអប្បបរមា

ប្រាក់ឈ្នួលអប្បរមា គឺជាប្រាក់ដែលកម្មករនិយោជិតទទួលបានពីនិយោជកដែលជាប្រាក់ឈ្នួលទាបបំផុតដែលកម្មករនិយោជិតត្រូវទទួល ហើយនិយោជកមិនអាចផ្តល់ប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមានេះទេ តែបើមានការផ្តល់ជូនប្រាក់ឈ្នួយលច្រើនជាងប្រាក់ឈ្នួលអប្បបរមានេះគឺនិយោជកអាចផ្តល់បានព្រោះដើម្បីជាប្រយោជន៍ដល់កម្មករនិយោជិត។ ការកំណត់ប្រាក់ឈ្នួលអប្បបរមាននេះត្រូវកំណត់ដោយក្រសួងការងារបណ្តុះបណ្តាលវិជ្ជជីវៈ ។

### ២.២.១ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា

ប្រាក់ឈ្នួលអប្បបរមាត្រូវធានានេះត្រូវបានធានាជូនតាមឋានានុក្រមនៃការធ្វើការដែលមានដូចជា ការងារសាកល្បង កូនជាង កម្មករពេញសិទ្ធិ និងការងារម៉ៅការ ឬតាមបរិមាណផលិផល(ដេរស៊ីបុង)។

#### ក.ការងារសាកល្បង

មុននឹងក្លាយជាកម្មករនិយោជិតពេញសិទ្ធិ កម្មករនិយោជិតត្រូវឆ្លងកាត់ការសាកល្បងការងារជាមុនសិនដើម្បីដឹងថាបុគ្គលនោះមានសម្ថភាពក្នុងការបំពេញការងារនោះដែរឬទេ។ ការងារសាកល្បងនេះត្រូវធ្វើដោយមានចិរវេលាកំណត់ជាក់លាក់ ដែលចិរវេលាសាកល្បងនោះមាន មិនអាចលើសពី៣(បី)ខែចំពោះនិយោជិត ២(ពីរ)ខែសម្រាប់ការងារឯកទេស និង១(មួយ)ខែសម្រាប់កម្មករធម្មតា[៣៨]។ ការងារសាកល្បងនេះផងដែរ គឺការងារដែលទទួលបានប្រាក់ឈ្នួលដែលប្រាក់ឈ្នួលនេះត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យការងារ។ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងនេះមានការកំណត់មានការវិវឌ្ឍជារៀងរាល់ឆ្នាំផងដែរ ដោយមានការវិវឌ្ឍកើនឡើងជាលំដាប់។ ដែលការវិវឌ្ឍនេះមានដូចខាងក្រោមៈ

[៣៨] មាត្រា៦៨, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

- ឆ្នាំ១៩៩៧ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងនេះកម្មករនិយោជិតទទួលបាន ៤០(សែសិប)ដុល្លារក្នុងមួយខែ[៣៩]។ ប្រាក់ឈ្នួលនេះថេររហូតដល់ឆ្នាំ២០០៦។
- ឆ្នាំ២០០៧ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងនេះកម្មករនិយោជិតទទួលបាន ៤៥(សែសិប្រាំ)ដុល្លារក្នុងមួយខែ[៤០]។ ប្រាក់ឈ្នួលនេះត្រូវបានរក្សាដល់ឆ្នាំ២០០៩។
- ឆ្នាំ២០១០ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងនេះកម្មករនិយោជិតទទួលបាន ៥៦ (ហាសិរប្រាំមួយ)ដុល្លារក្នុងមួយខែ[៤១]។ ប្រាក់ឈ្នួលនេះរក្សារហូតដល់ឆ្នាំ២០១២។
- ឆ្នាំ២០១៣ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងដែលកម្មករនិយោជិតទទួលបាន ៧៥(ចិតសិបប្រាំ)ដុល្លារក្នុងមួយខែ[៤២]។
- ឆ្នាំ២០១៤ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មករនិយោជិតទទួលបាន ៩៥(កៅសិបប្រាំ)ដុល្លារក្នុងមួយខែ[៤៣]។
- ឆ្នាំ២០១៥ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មករនិយោជិតទទួលបាន ១២៣ (មួយរយម្ភៃបី)ដុល្លារក្នុងមួយខែ[៤៤]។
- នៅក្នុងឆ្នាំ២០១៦ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មករនិយោជិតទទួលបាន ១៣៥(មួយរយសាមសិបប្រាំ)ដុល្លារក្នុងមួយខែ[៤៥]។
- ឆ្នាំ២០១៧ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មករនិយោជិតទទួលបាន ១៤៨(មួយរយសែសិបប្រាំបី)ដុល្លារម្មុងមួយខែ[៤៦]។

---

[៣៩] សេចក្តីជូនដំណឹងលេខ០៦ សកអ,ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧។

[៤០] សេចក្តីជូនដំណឹងលេខ៧៤៥ ក.ក.ប.វ,ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

[៤១] សេចក្តីជូនដំណឹងលេខ០៤៩កប/ស.ជ.ណ,ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០។

[៤២] សេចក្តីជូនដំណឹងលេខ១០៣ ក.ប/ស.ជ.ណ,ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣។

[៤៣] សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ ៣១៧ ក.ប/ប្រក,ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣,ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និងស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ,លេខ០០១/១៤ ក.ប/ស.ជ.ណ,ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤។

[៤៤] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមានកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៥, លេខ២៨៣ ក.ប/ប្រ.ក,ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤។

[៤៥] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៦,លេខ៤០៩/១៥ ក.ប/ប្រ.ក,ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥។

[៤៦] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧,លេខ៤១៥ ក.ប/ប្រ.ក,ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦។

- ឆ្នាំ២០១៨ ប្រាក់ឈ្នួលសម្រាំការងារសាកល្បងកម្មករនិយោជិតទទួលបាន ១៦៥(មួយរយហុកសិបប្រាំ)ដុល្លារក្នុងមួយខែ[៤៧]។
- ឆ្នា២០១៩ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មករនិយោជិតទទួលបាន១៧៧(មួយរយចិតសិបប្រាំពីរ)ដុល្លារក្នុងមួយខែ[៤៨]។
- ឆ្នាំ២០២០ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងកម្មកនោយោជិតទទួលបាន១៨៥ (មួយរយប៉ែតសិបប្រាំ)ដុល្លារក្នុមួយខែ[៤៩]។

ដូចនេះការងារសាកល្បងជាការងារដែលមានចិរវេលាកំណត់ក្នុងការសាកល្បងហើយត្រូវទទួលបានប្រាក់ឈ្នួលប្រចាំខែដែលត្រូវធានាជូនកម្មករនយោជិតក្នុងពេលសាកល្បងការងារនេះ។ ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងនេះត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យការងាររៀងរាល់ឆ្នាំ។

### ខ.កូនជាង

កូនជាង គឺជាជនដែលចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជក ឬសិប្បករណាម្នាក់ដែលបានចុះកិច្ចសន្យានិងគ្នាថា និយោជកត្រូវបង្រៀន ឬ ប្រើឱ្យគេបង្រៀនវិជ្ជាជីវៈខ្លួនហើយកូនជាងត្រូវធ្វើការឱ្យនិយោជក តែតាមលក្ខខណ្ឌ និងក្នុងរយៈពេលនៃកិច្ចសន្យាការងារ[៥០] ដែលកិច្ចសន្យាការងារនេះមិនត្រូវឱ្យលើសរយៈពេលពីរឆ្នាំនោះទេ។ នៅក្នុងអំឡុងពេលនៃកិច្ចសន្យានេះកូនជាងក៏ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចជាការស្តាប់បង្គាប់និងគោរពគ្រូក្នុងក្របខណ្ឌនៃការហ្វឹកហ្វឺន និងត្រូវជួយគ្រូក្នុងការងារតាមសមត្ថភាព និងកម្លាំងរបស់ខ្លួន ព្រមទាំងរក្សាទុកនូវអាថ៌កំបាំងវិជ្ជាជីវៈផ្សេងៗផងដែរ។ សហគ្រាសទាំឡាយដែលមានប្រើប្រាស់កម្មករនិយោជិតច្រើនជាង៦០នាក់ត្រូវតែមានកូនជាងស្មើ១/១០នៃចំនួនកម្មករនិយោជិតដែលធ្វើការក្នុងសហគ្រាសនោះ។ ចំនួនអតិបរមានៃកូនជាងក្នុងសហគ្រាស ទោះមានកម្មករនិយោជិតប៉ុន្មានក៏ដោយត្រូវមានកំណត់ក្នុងប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ ដែលយោងទៅតាមលទ្ធភាពខាងបុគ្គលិក និងខាងសម្ភារៈ[៥១]។ សម្រាប់ការងារកូនជាង

[៤៧] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨,លេខ៣៩៦ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧។

[៤៨] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩,លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

[៤៩] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០,លេខ៣៨៩/១៩ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

[៥០] មាត្រា៨, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៥១] មាត្រា៥៧, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

ឬ ការហ្វឹកហ្វឺនកូនជាងនេះត្រូវមានប្រាក់ឈ្នួលដើម្បីធានាដល់កូនជាងដោយប្រាក់ឈ្នួលនេះនិយោជិតត្រូវផ្តល់ឱ្យកូនជាងចំនួន ៣០(សាមសិប)ដុល្លារក្នុងមួយខែ[៥២] ហើយប្រាក់ដែលផ្តល់ជូនកូនជាងនេះត្រូវបានរក្សារហូតមក តែប្រាក់ឈ្នួលសម្រាប់កូនជាងនេះអាចនឹងត្រូវវិវត្តន៍កើនឡើងនូវពេលអនាគត។

**គ.កម្មករពេញសិទ្ធិ**

បន្ទាប់ពីបានបញ្ចប់ការងារសាកល្បងតាមចិរវេលាដែលកំណត់រួចមក នោះបុគ្គលនោះនឹងក្លាយជាកម្មករពេញសិទ្ធិ។ ហើយកម្មករពេញសិទ្ធិនេះធ្វើការដោយត្រូវទទួលបានប្រាក់កម្រៃដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជារៀងរាល់ឆ្នាំ។ ហើយប្រាក់ឈ្នួលសម្រាប់កម្មករពេញសិទ្ធិនេះមានការវិវឌ្ឍជារៀងរាល់ឆ្នាំ។ ដោយឡែកនៅក្នុងឆ្នាំ២០២០នេះប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតពេញសិទ្ធិគឺទទួលបាន ១៩០(មួយរយកៅសិប)ដុល្លារ[៥៣]។

**ឃ.ការងារម៉ៅការ ឬតាមបរិមាណផលិតផល(ដេរស៊ីបុង)**

ការងារម៉ៅការ ឬការងារតាមបរិមាណផលិតផលទោះធ្វើនៅក្នុងរោងជាង ឬនៅលំនៅឋានក៏ដោយ ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិតតាមការខិតខំប្រឹងប្រែងរបស់ខ្លួន អត្រាប្រាក់ឈ្នួលដែលត្រូវទទួលបាននេះយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិតនោះ។ ទោះបីជាប្រាក់ឈ្នួលការងារម៉ៅការ ឬ តាមបរិមាណផលិតផលនេះកម្មករនិយោជិតទទួលបានតាមការប្រឹងប្រែងរបស់ខ្លួនក៏ដោយ តែកាលបើប្រាក់ឈ្នួលដែលត្រូវទទួលបាននោះទាបជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នោះនិយោជកត្រូវបន្ថែមបង្គ្រប់ជូនដល់កម្មករនិយោជិតឱ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា[៥៤]។ ប្រាក់ឈ្នួលការងារម៉ៅការ ឬតាមផលិតផល(ដេរស៊ីបុង)ទទួលបានលើសពីការកំណត់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវកំណត់នោះត្រូវទទួលតាមចំនួលលើសនោះ។ កម្មករដែលធ្វើការងារម៉ៅការ តាមបរិមាណផលិតផល(ដេស៊ីបុង)មានពីរគឺ ការងារម៉ៅការ ឬតាមបរិមាណផលិតផល(ដេរស៊ីបុង)សម្រាប់ការងារសាកល្បង និងការងារម៉ៅការ ឬតាមបរិមាណផលិតផល(ដេរស៊ីបុង)សម្រាប់ការងារពេញសិទ្ធិ។ ជាក់ស្តែងនៅក្នុងឆ្នា២០២០នេះ ប្រាក់ឈ្នួលការងារម៉ៅការ ឬតាមបរិមាណផលិត(ដេរស៊ីបុង)ត្រូវធានាជូនកម្មករនិយោជិតការងារសាកល្បងគឺ១៨៧ (មួយរយប៉ែតសិបប្រាំពីរ) ដុល្លារក្នុងមួយខែ និងការងារម៉ៅការ ឬ តាមបរិមាណផលិតផល(ដេស៊ីបុង)ជូនកម្មករពេញសិទ្ធិគឺ១៩០(មួយរយ

[៥២] សេចក្តីជូនដំណឹងលេខ០៦ សកអ,ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧។

[៥៣] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០,លេខ៣៨៩/១៩ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

[៥៤] មាត្រា៧, ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/០៧១៨/០១៥,០៩ កក្កដា ២០១៨។

កៅសិប)ដុល្លារក្នុងមួយខែ។ ដូចនេះប្រសិនបើកម្មករនិយោជិតសម្រាប់ការងារម៉ោការ ឬតាមបរិមាណផលិតផល (ដេរស៊ីបុង)ទាបជាងប្រាក់ឈ្នួលខាងលើនេះនិយោជកត្រូវបង្គ្រប់ឱ្យកម្មករនិយោជិតតាមការកំណត់នេះ[៥៥]។

### ២.២.២ ការកំណត់ប្រាក់ឈ្នួលអប្បបរមា

ក្នុងការងារកម្មករនិយោជិតចាំបាច់ណាស់គឺត្រូវឱ្យមានការកំណត់នូវប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតព្រោះថាបើមិនមានការកំណត់ទេកម្មករនិយោជិតអាចនឹងត្រូវបាត់បង់នូវប្រយោជន៍ការងារ និងធ្វើឱ្យនិយោជកមានការកំណត់ប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតតាមចិត្តរបស់ខ្លួន។

ការកំណត់ប្រាក់ឈ្នួលអប្បបរមានេះគឺមានគោលបំណង លើកកម្ពស់ជីវភាពរស់នៅសមរម្យ ថ្លៃថ្នូរ បង្កើតការងារ និងបង្កើនលទ្ធភាពរបស់កម្មករនិយោជិត។ មួយវិញទៀតជំរុញឱ្យមានបរិយាកាសវិនិយោគ និងធុរកិច្ចកាន់តែប្រសើរប្រកបដោយភាពទាក់ទាញ[៥៦]។ ប្រាក់ឈ្នួលរបស់កម្មករនិយោជិតយ៉ាងតិចណាស់ក៏ត្រូវស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលជាប្រាក់ឈ្នួលកម្រិតទាបបំផុត និងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ[៥៧]។ មានន័យថានិយោជកអាចផ្ដល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចាប់ត្រឹមពីប្រាក់ឈ្នួលអប្បរមាឡើងទៅ តែមិនអាចទាបជាងនេះបានទេ។ ប្រាក់ឈ្នួលអប្បបរមានត្រូវបានកំណត់ដោយអង្គភាពមានសមត្ថកិច្ចក្នុងការកំណត់នោះគឺ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួល។

#### ក.ប្រវត្តិសមត្ថកិច្ចកំណត់ប្រាក់ឈ្នួលអប្បបរមា

តាំងពីឆ្នាំ១៩៩៧ រហូតមកដល់ឆ្នាំ២០១៨ ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតត្រូវធ្វើឡើងដោយគណៈកម្មការប្រឹក្សាការងារដែលមានការចូលរួមពីស្ថាប័នត្រីភាគីដែលមានសមាជិក ២៨រូប។ ភាគីរាជរដ្ឋាភិបាលចំនួន១៤រូប ភាគីតំណាងកម្មករនិយោជក៧រូប និងតំណាងកម្មករនិយោជិត៧រូប។ ហើយសមាជិកនេះអាចមានការប្រែប្រួលផងដែរ។

ចាប់តាំងពីឆ្នាំ២០១៩ ការកំណត់ប្រាក់ឈ្នួលអប្បបរមានសម្រាប់កម្មករនិយោជិតគឺត្រូវធ្វើដោយក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលនៅអមដោយក្រសួងទទួលបន្ទុកវិស័យការងារដោយយោងតាមច្បាប់ស្ដីពីប្រាក់

[៥៥]ប្រកាសស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ ២០២០,លេខ៣៨៩/១៩ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

[៥៦]មាត្រា១, ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/0៧១៨/0១៥,0៩ កក្កដា ២0១៨។

[៥៧] មាត្រា៤, ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/0៧១៨/0១៥,0៩ កក្កដា ២0១៨។

ឈ្នួលអប្បបរមា និងមានសមាជិកពេញសិទ្ធិយ៉ាងតិច៤៨(សែសិបប្រាំបី)រូប ដែលមានសមាសភាពមកពីត្រីភាគីក្នុងចំនួនស្មើគ្នាគឺ៖

- ១/៣(មួយភាគបី) ជាតំណាងភាគីរាជរដ្ឋាភិបាល។
- ១/៣(មួយភាគបី) ជាតំណាងភាគីកម្មករនិយោជិត។
- ១/៣(មួយភាគបី) ជាតំណាងភាគីនិយោជក។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ឬអ្នកតំណាង១(មួយ)រូបនៃក្រសួងទទួលបន្ទុកវិស័យការងារជាប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។ អនុប្រធាន២(ពីរ)រូប ដែល១(មួយ)រូប ជ្រើសចេញពីតំណាងសមាសភាពកម្មករនិយោជិត និង១(មួយ)រូបទៀតជ្រើសចេញពីសមាសភាពតំណាងនិយោជក តាមការបោះឆ្នោតផ្ទៃក្នុងរបស់ភាគីនីមួយៗ។ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាក៏ត្រូវមានសមាជិកបម្រុងផងដែរ ក្នុងករណីដែលសមាជិកពេញសិទ្ធិណាមួយអវត្តមានមិនបានចូលរួមក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។ សមាជិកបម្រុងនេះត្រូវមានចំនួនស្មើនឹងសមាជិកពេញសិទ្ធិ។ ក្រសួងទទួលបន្ទុកវិស័យការងារក៏អាចធ្វើការស្នើសុំកែសម្រួលសមាជិកផងដែរតែមិនឱ្យតិចជាង៤៨(សែសិបប្រាំបី)រូប។ ប្រាក់បៀវត្សរបស់សមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលងប្បបរមាជាបន្ទុករបស់ស្ថាប័នសមី[៥៤]។ ចំពោះកាលវិភាគនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាគឺត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យ ការងារ បន្ទាប់ពីទទួលបានអនុសាសន៍ពីក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

ការពិភាក្សាកំណត់ប្រាក់ឈ្នួលត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ការពិភាក្សាកំណត់ប្រាក់ឈ្នួលត្រូវធ្វើឡើងតាមការកំណត់ដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ប្រាក់ឈ្នួលអប្បបរមាត្រូវតែជាតួលេខ ឬ អត្រាបម្រែបម្រួលដែលអាចព្យាករបានពោលគឺត្រូវកំណត់តាមលំដាប់បន្តបន្ទាប់(កើន)។
- ប្រកាន់យកនយោបាយ ឈ្នះ ឈ្នះ។
- ត្រូវប្រើទិន្នន័យផ្លូវការស្របច្បាប់របស់ស្ថាប័ន ឬអង្គភាពនានាដែលទទួលបន្ទុកផលិតស្ថិតិ និងយកវិនិច្ឆ័យតាមបែបសង្គម និងសេដ្ឋកិច្ច មកធ្វើជាមូលដ្ឋានក្នុងការពិភាក្សា[៥៥]។

---

[៥៤] មាត្រា១៧, ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/០៧១៨/០១៥,០៩ កក្កដា ២០១៨។
[៥៥] មាត្រា១០, ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/០៧១៨/០១៥,០៩ កក្កដា ២០១៨។

ធាតុផ្សំសម្រាប់យកមកពិចារណាក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាគឺត្រូវផ្តោតលើលក្ខខណ្ឌសេដ្ឋកិច្ច តម្លៃជីវភាពរស់នៅ និងស្ថានភាពជាក់ស្តែងនៃប្រទេស។ ធាតុផ្សំនោះមានពីរគឺៈ

១)ធាតុផ្សំសង្គមដែលរួមមាន ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយលើការរស់នៅ។

២)ធាតុផ្សំសេដ្ឋកិច្ចដែលរួមមាន ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ[៦០]។

**<u>ធាតុផ្សំសង្គម</u>**

ធាតុផ្សំសង្គម ជាធាតុចូលដែលសំខាន់នេះត្រូវយកទៅពិចារណាក្នុការកំណត់ប្រាក់ឈ្នួលដែលមានដូចជាៈ

- ស្ថានភាពគ្រួសារ គឺសិក្សាថាត្រូវផ្តល់ប្រាក់ឈ្នួលអប្បបរមាប៉ុន្មានដល់កម្មករនិយោជិតដើម្បីឱ្យបានចិញ្ចឹមគ្រួសារក្នុងបន្ទុកឱ្យមានជីវភាពល្អប្រសើរ និងថ្លៃផ្ទះ ហើយកម្មករនិយោជិតអាចប្រើប្រាក់នោះសម្រាប់ចាយវាយប្រចាំថ្ងៃជាមួយនឹងថ្លៃទំនិញ ចំណីអាហារ និងត្រូវការផ្សេងទៀតបានសមរម្យនិងគ្នាដែរឬទេ។
- អត្រាអតិផរណា ដោយត្រូវសិក្សាពី ថ្លៃទំនិញ ចំណីអាហារក្នុងស្ថានភាពបច្ចុប្បន្នថាការផ្តល់ប្រាក់ឈ្នួលក្នុងចំនួនណាដែលជួយលើកម្ពស់ជីវភាពកម្មករយោជិតឱ្យបានសមរម្យ និងអាចប្រើប្រាក់នោះទិញទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃបាន
- ការចំណាយលើការរស់នៅ សិក្សាលើការចំណាយជាមធ្យមប្រចាំថ្ងៃ និងផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតកម្រិតណាដើម្បីធានាកម្មករនិយោជិតចាកផុតពីភាពក្រីក្រ។

យ៉ាងណាមិញដូចនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានសង្កេតឃើញថាតម្រូវការរបស់របស់ប្រជាជនក្នុងជីវភាពរស់នៅប្រចាំថ្ងៃគឺមានតម្រូវការខ្ពស់ និងថ្លៃទំនិញមានការកើនឡើងជានិច្ច ទើបធ្វើឱ្យក្នុងក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា យកបញ្ហានេះទៅពិចារណាកំណត់ប្រាក់ឈ្នួលអប្បបរមាកម្មករនិយោជិត។

**<u>ធាតុផ្សំសេដ្ឋកិច្ច</u>**

សេដ្ឋកិច្ច គឺសំខាន់ណាស់សម្រាប់យកមកធ្វើការវិនិច្ឆ័យកំណត់ប្រាក់ឈ្នួលអប្បបរមាន ដែលក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលត្រូវសង្កេតលើៈ

[៦០] មាត្រា១៤, ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/០៧១៨/០១៥,០៩ កក្កដា ២០១៨។

- ផលិតភាព គឺការផលិតបានរបស់កម្មករនិយោជិត ធៀបនឹងកម្លាំងពលកម្មដែលកម្មករនិយោជិតធ្វើ តើប្រាក់ឈ្នួលដែលទទួលបានសមនឹងកម្លាំងពលកម្មដែរឬទេ?
- ការប្រកួតប្រជែងរបស់ប្រទេស ជាការប្រៀបធៀបនឹងប្រាក់ឈ្នួល សេដ្ឋកិច្ច ម៉ោងធ្វើការ អត្ថប្រយោជន៍ផ្សេងៗនៃប្រទេសជិតខាង ឬបណ្ដាប្រទេសប្រកួតប្រជែងសេដ្ឋកិច្ច។
- ស្ថានភាពទីផ្សារការងារ ដោយសង្កេតមើលទីផ្សារការងារក្នុងប្រទេសកម្ពុជាដូចជា ការអត់ការងារធ្វើ ការបង្កើតការងារថ្មីៗ នឹងការប្រកួតប្រជែងប្រាក់ឈ្នួល និងអត្ថប្រយោជន៍តាមកន្លែងធ្វើការនានា
- កម្រិតចំណេញក្នុងវិស័យ ដោយត្រូវសិក្សាលើការចំណេញរបស់គ្រឹះស្ថាន សហគ្រាស រោងចក្រ តើសមាមាត្រនិងការចំណាយសម្រាប់កម្លាំងពលកម្មកម្មករនិយោជិតដែរឬទេ?

ជាក់ស្ដែងពីឆ្នាំកន្លងមកនេះគឺឆ្នាំ ២០១៨ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ច ៧,៥% និងនៅក្នុងឆ្នាំ២០១៩ មានកំណើន៧% បើតាមរបាយការណ៍ធនាគាពិភពលោ(World Bank)។ ហើយទីផ្សារការងាររបស់កម្ពុជាមានច្រើន ដូចនេះទើបធ្វើឱ្យក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានកំណត់ប្រាក់ឈ្នួលអប្បរមាកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរក្នុងឆ្នាំ២០១៩ ចំនួន១៨២(មួយរយប៉ែតសិបពីរ)ដុល្លារ ក្នុងមួយខែ[៦១] និងក្នុងឆ្នាំ២០២០ ចំនួន១៩០(មួយរយកៅសិប)ដុល្លារក្នុងមួយខែ[62]។ ប៉ុន្តែនៅក្នុងឆ្នាំ២០២០នេះប្រទេសកម្ពុជាក៏ដូចជាពិភពមានរងការប៉ះពាល់ជាខ្លាំងជាមួយនិងវិបត្តិការឆ្លងរីករាលដាលនៃជម្ងឺកូវីត១៩ បញ្ហានេះក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានិងយកទៅពីចារណាសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមានកម្មករនិយោជិតក្នុងឆ្នាំ២០២១។

### ខ.បទដ្ឋានគតិយុត្តនៃការវិវឌ្ឍន៍ប្រាក់ឈ្នួលអប្បបរមា

ប្រាក់ឈ្នួលរបស់កម្មករនិយោជិតមានការវិវឌ្ឍជាច្រើនចាប់តាំងពីមានច្បាប់ការងារ១៩៩៧មក ហើយក្រសួងទទួលបន្ទុកវិស័យកាងារក៏បានចេញនូវបទដ្ឋានគិយុត្តជាច្រើនទាក់ទងនឹងការវិវឌ្ឍប្រាក់ឈ្នួលនេះមានដូចជា[63]៖

- ឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៩(សេចក្ដីជូនដំណឹងលេខ០៦ សកអ) ប្រាក់ឈ្នួលអប្បបរមាសម្រាប់កូនជាង ៣០ដុល្លារក្នុងមួយខែដែលបានរក្សារហូតមកដល់បច្ចុប្បន្ន និងសម្រាប់កម្មករការងារសាកល្បង និងពេញសិទ្ធិទទួលបាន៤០ដុល្លារក្នុងមួយខែ។

---

[៦១] ប្រកាសស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ ២០១៩,លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

[៦២] ប្រកាសស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ ២០២០,លេខ៣៨៩/១៩ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

[៦៣] មើលឧបសម្ព័ន្ធ២

- ឆ្នាំ២០០០ ដល់ឆ្នាំ២០០៦(សេចក្ដីជូនដំណឹងលេខ០១៧/00 សកបយ) ប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារសាកល្បងចំនួន ៤០ដុល្លារក្នុងមួយខែ ការងារពេញសិទ្ធិចំនួន ៤៥ដុល្លារក្នុងមួយខែរួមទាំងប្រាក់សម្រាប់បាយ១០០០រៀល និងប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់ចំនួន ៥ដុល្លារក្នុងមួយខែ។
- ឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩(សេចក្ដីជូនដំណឹងលេខ៧៤៥/០៦ កកបវ) ប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារសាកល្បងទទួលបាន ៤៥ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ៥០ដុល្លារក្នុងមួយខែ។ (សេចក្ដីជូនដំណឹងលេខ ០៣២/០៨ កប/សជណ) បន្ថែមប្រាក់ឧបត្ថមចំនួន៦ ដុល្លារដោយមិនគិតបញ្ចូលជាប្រាក់ឈ្នួល ប្រាក់ឧបត្ថមនេះអនុវត្តបានតែពីរឆ្នាំ គឺត្រឹមឆ្នាំ២០០៩ ហើយក៏បានគិតបញ្ចូលក្នុងប្រាក់ឈ្នួលឆ្នាំ២០១០។
- ឆ្នាំ២០១០ ដល់ឆ្នាំ២០១២(សេចក្ដីជូនដំណឹងលេខ០៤៩/១០ កអ/សជណ) ប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារសាកល្បងគឺ ៥៦ដុល្លារ និងសម្រាប់កម្មករពេញសិទ្ធិចនួន ៦០ដុល្លារ។ (សេចក្ដីជូនដំណឹង០៤១/១១ កប/សជណ) បានកំណត់ជាថ្មីនូវប្រាក់ប្រាក់សម្រាប់ការងារទៀងទាត់គឺកើនមក ៧ដុល្លារក្នុងមួយខែ និងប្រាក់បាយចំនួន២០០០រៀល។ (សេចក្ដីជូនដំណឹងលេខ២០៦ កប/សជណ) កម្មករនិយោជិតទទួលបានប្រាក់ថៃទាំសុខភាពចំនួន ៥ដុល្លារក្នុងមួយខែដោយមិនគិតបញ្ចូលក្នុងប្រាក់ឈ្នួល ហើយប្រាក់ថៃទាំសុខភាពនេះក៏ត្រូវបានបូកបញ្ចូលក្នុងប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៣។ (សេចក្ដីជូនដំណឹងលេខ២៣០ កប/សជណ) បានកណត់នូវប្រាក់សម្រាប់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ដុល្លារ រួមទាំងប្រាក់សម្រាប់ការងារទៀងទាត់ថ្មីគឺចំនួន ១០ដុល្លារក្នុងមួយខែ។
- ឆ្នាំ២០១៣(សេចក្ដីជូនដំណឹងលេខ១០៣ កប/សជណ) ប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងសារសាកល្បងទទួលបាន ៧៥ដុល្លារក្នុងមួយខែ និងសម្រាប់ការងារពេញសិទ្ធិទទួលបាន ៨០ដុល្លារក្នុងមួយខែ។
- ឆ្នាំ២០១៤ (ប្រកាសលេខ៣១៧ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ៩៥ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១០០ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែលមានដូចជា ប្រាក់សោហ៊ុយធ្វើដំណើរនិងប្រាក់ថ្លៃស្នាក់នៅ ចំនួន ៧ដុល្លារក្នុងមួយខែ ប្រាក់រង្វាន់សម្រាប់ការងារទៀតទាត់ចំនួន ១០ដុល្លារក្នុងមួយខែ ប្រាក់អតីតភាពការងារ និងថ្លៃអាហារចំនួន ២០០០រៀល។
- ឆ្នាំ២០១៥ (ប្រកាសលេខ២៨៣ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១២៣ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១២៨ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។

- ឆ្នាំ២០១៦ (ប្រកាសលេខ៤០៩/១៥ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១៣៥ ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១៤០ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។
- ឆ្នាំ២០១៧ (ប្រកាសលេខ៤២៤ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១៤៨ ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១៥៣ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។
- ឆ្នាំ២០១៨ (ប្រកាសលេខ៣៩៦ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១៦៥ ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១៧០ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។
- ឆ្នាំ២០១៩ (ប្រកាសលេខ៤៦៥ កប/ប្រកខល) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១៧៧ ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១៨២ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។
- ឆ្នាំ២០២០ (ប្រកាសលេខ៣១៧ កប/ប្រក) ប្រាក់ឈ្នួលសម្រាប់ការងារសាកល្បងទទួលបាន ១៨៥ ដុល្លារក្នុងមួយខែ និងសម្រាប់កម្មករពេញសិទ្ធិទទួលបាន ១៩០ដុល្លារក្នុងខែ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅរក្សាទុកដដែល។ បន្ទាប់ពីប្រាក់ឈ្នួលអប្បបរមាដែលកម្មករនិយោជិតទទួលបាន ដែលរួមទាំងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មកករនិយោជិតទទួលបានប្រាក់មួយប្រភេទទៀតគឺប្រាក់សម្រាប់ការទូទាត់ប្រាក់អតីតភាពការងារ។

# ជំពូកទី២៖ សិទ្ធិ និងភាតព្វកិច្ចពាក់ព័ន្ធនិងប្រាក់ឈ្នួល

## ផ្នែកទី១៖ វិធាននៃការបើកប្រាក់ឈ្នួល

### ១.១ ការជូនដំណឹងដល់កម្មករនិយោជិតអំពីប្រាក់ឈ្នួល

និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតឱ្យបានលម្អិតអំពីលក្ខខណ្ឌនៃប្រាក់ឈ្នួលដែលត្រូវអនុវត្តចំពោះកម្មករនិយោជិតព្រមទាំងពន្យល់ណែនាំទៅកម្មករនិយោជិតឱ្យបានច្បាស់អំពីរបៀបគណនាប្រាក់ឈ្នួលរបស់ពួកគេមុនពេលទទួលកម្មករនិយោជិតឱ្យចូលធ្វើការ និងមុនពេលផ្លាស់ប្តូរប្រាក់ឈ្នួលរបស់ពួកគេ(ដូចជាមុនពេលប្តូរទម្រង់ និងតម្លៃបុង)។ ត្រង់ចំណុចនេះនិយោជកគួរតែផ្តល់បុងបើកប្រាក់ឈ្នួលទៅកម្មករនិយោជិតនៅថ្ងៃបើកប្រាក់ឈ្នួលនីមួយៗ ហើយសម្រាប់បុងបើកប្រាក់ឈ្នួលទាំងអស់ត្រូវសរសេរជាភាសាខ្មែរ និងបង្ហាញពីរបៀបនៃការគណនាប្រាក់ឈ្នួល។ ប្រាក់ឈ្នួលដែលត្រូវបានកំណត់ដោយច្បាប់ត្រូវបិទ ឬព្យួរនៅក្នុងបន្ទប់ធ្វើការ ឬ នៅការិយាល័យបើកប្រាក់ឈ្នួល និងនៅកន្លែងដែលទទួលនិយោជិតឱ្យចូលបម្រើការងារនោះ[៦៤]។ រាល់ការបើកប្រាក់ឈ្នួលសុតតែមានការកំណត់អំពីលក្ខខណ្ឌនៃការបើកប្រាក់ឈ្នួល ទីកន្លែងបើកប្រាក់ឈ្នួល និងពេលវេលានៃការបើកប្រាក់ឈ្នួល។

### ១.២ វិធីបើកប្រាក់ឈ្នួល

និយោជកត្រូវតែបើកប្រាក់ឈ្នួលដូចខាងក្រោម៖

- ត្រូវបើកប្រាក់ឈ្នួលទៅកម្មករនិយោជិតដោយផ្ទាល់ដៃលើកលែងតែកម្មករនិយោជិតយល់ព្រមបើកប្រាក់ឈ្នួលទៅតាមវិធីផ្សេងៗទៀតអាស្រ័យលើការចរចារគ្នា
- ការបើកប្រាក់ឈ្នួលត្រូវធ្វើការបើកជាក្រដាសប្រាក់
- ការបើកប្រាក់ឈ្នួលត្រូវធ្វើការបើកនៅកន្លែងធ្វើការផ្ទាល់ ឬនៅជិតកន្លែងធ្វើការ ហើយត្រូវធ្វើការបើកនៅថ្ងៃដែលធ្វើការធម្មតា មិនមែនបើកនៅថ្ងៃឈប់សម្រាកនោះទេ។ ករណីបើថ្ងៃដែលត្រូវបើកប្រាក់ឈ្នួលនោះចំថ្ងៃឈប់ ឬថ្ងៃបុណ្យនានានិយោជកត្រូវតែបើកប្រាក់ឈ្នួលមុនថ្ងៃឈប់សម្រាកនោះមួយថ្ងៃ។
- ហើយការបើកប្រាក់ឈ្នួលត្រូវតែធ្វើនៅក្នុងម៉ោងធ្វើការតែប៉ុណ្ណោះ។
- ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត២ដងក្នុងមួយខែត្រូវបានអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៩មក ហើយការបើកលើកទី១ គឺធ្វើការបើកនៅក្នុងសប្តាហ៍ទី២ និងការបើកលើកទី២(ពីរ) ត្រូវធ្វើការបើកនៅក្នុងសប្តាហ៍ទី៤(បួន)នៃខែនីមួយៗតាមបែបបទដូចខាងក្រោម៖

  លើកទី១ គឺស្មើនឹងចំនួន៥០%(ហាសិបភាគរយ) នៃប្រាក់ឈ្នួលសុទ្ធសាធក្នុង១(មួយ)ខែ

[៦៤] មាត្រា១០៩, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

លើកទី២ គឺស្មើនឹងចំនួនប្រាក់ឈ្នួលសុទ្ធសាធដែលនៅសល់ ចំពោះប្រាក់ឈ្នួលបន្ទាប់បន្សំ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀត ដែលកម្មករនិយោជិតត្រូវទទួលបាននៅក្នុងខែនីមួយៗ។

### ១.៣ ពេលវេលាបើកប្រាក់ឈ្នួល

ដោយយោងទៅតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១១៦ បានកំណត់អំពីពេលវេលានៃការបើកប្រាក់ឈ្នួលត្រូវធ្វើតាមកាលបរិច្ឆេទដូចខាងក្រោម៖

- ចំពោះកម្មករ ប្រាក់ឈ្នួលត្រូវបើកយ៉ាងហោចណាស់ចំនួន២(ពីរ)ដងក្នុងមួយខែ។

- ចំពោះនិយោជិត ប្រាក់ឈ្នួលត្រូវបើកយ៉ាងហោចណាស់ចំនួន១(មួយ)ដងក្នុងមួយខែ។

-ចំពោះអ្នកដើរទាក់ទង និងអ្នកតំណាងពាណិជ្ជកម្ម ប្រាក់កម្រៃជើងសារត្រូវបើកយ៉ាងហោចណាស់៣(បី)ខែម្តង

- ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផលដែលត្រូវការពេលវេលាបំពេញការងារលើសពី១៥(ដប់ប្រាំថ្ងៃ) កម្មករត្រូវទទួលបានប្រាក់រំលស់១០(ដប់ថ្ងៃ)ម្តង និងបន្ទាប់ពីបញ្ចប់ការងារ ត្រូវទទួលបានប្រាក់គ្រប់ចំនួនក្នុងរយៈពេលមួយសប្តាហ៍។

- ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗទៀតដែលកម្មករនិយោជិតត្រូវទទួលបានក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោងបន្ទាប់ពីការបណ្តេញចេញពីការងារ។

### ១.៤ ទីកន្លែងបើកប្រាក់ឈ្នួល

ជាធម្មតាការបើកប្រាក់ឈ្នួលត្រូវធ្វើឡើងនៅកន្លែងធ្វើការ ឬនៅការិយាល័យនិយោជកកាលណាការិយាល័យនោះនៅជិតផ្ទាល់ លើកលែងតែករណីប្រធានស័ក្តិ។ ហាមដាច់ខាតចំពោះការបើកប្រាក់ឈ្នួលនៅក្នុងតៀមលក់គ្រឿងស្រវឹង ឬទីកន្លែងកំសាន្តនានា លើកលែងតែកម្មករនិយោជិតនោះកំពុងបម្រើការងារនៅទីកន្លែងនោះផ្ទាល់[៦៥]។

### ១.៥ វិវាទនៃការបើកប្រាក់ឈ្នួល

ក្នុងករណីមានការប្តឹងទាស់អំពីប្រាក់ឈ្នួលអ្នកដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ថាកម្មករនិយោជិតបានទទួលនូវប្រាក់ឈ្នួលរបស់ពួកគាត់រួចហើយនោះគឺជាកាតព្វកិច្ចរបស់និយោជក តាមរយៈការបង្ហាញហត្ថលេខានៃសាមីខ្លួនឬសាក្សីពីរនាក់ប្រសិនបើកម្មករនិយោជិតនោះមិនចេះអក្សរដែលមានចុះនៅក្នុងសៀវភៅបើកប្រាក់ដែលរក្សារទុកដោយនិយោជក។

[៦៥] មាត្រា១១៥, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

ករណីកើតមានវិវាទទាក់ទងនិងការបើកប្រាក់ឈ្នួលកើតឡើងដោយប្រការណាមួយនោះ អ្នកដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទនេះគឺ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល តែអ្នកដែលសម្រេចរឿងក្ដីនីមួយៗគឺ អាជ្ញាកណ្ដាលចំនួន០៣រូបដែលធ្វើការជ្រើសតាំងឡើងដើម្បីធ្វើការសម្រេចទៅលើរឿងក្ដីមួយនោះ។ ហើយអាជ្ញាកណ្ដាលទាំង០៣រូបនេះត្រូវបានហៅថា ក្រុមអាជ្ញាកណ្ដាល ដោយក្រុមអាជ្ញាកណ្ដាលនេះតំណាងឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលហើយទទួលខុសត្រូវធ្វើសេចក្ដីសម្រេច និងចេញសេចក្ដីបង្គាប់ដើម្បីដោះស្រាយវិវាទរវាងភាគីទាំងពីរ។

### ១.៥.១ ការមិនបាត់បង់សិទ្ធិចំពោះការតវ៉ាបើកប្រាក់ឈ្នួលកម្មករនិយោជិត

នៅពេលដែលកម្មករនិយោជិតទទួលបង្កាន់ដៃបើកប្រាក់ដោយគ្មានការតវ៉ា នោះមិនមែនមានន័យថាពួកគាត់បោះបង់ចោលនូវសិទ្ធិរបស់ខ្លួនក្នុងការបើកប្រាក់បំណាច់ ឬ ប្រាក់បន្ទាប់បន្សំទាំងអស់នោះទេ។ ជាក់ស្ដែងនៅក្នុងស្ថានភាពការងារកម្មករនិយោជិតគឺពុំមានសិទ្ធិដើម្បីចរចារស្មើភាពគ្នាជាមួយនិយោជកទេ ដោយសារតែការប្រកាន់ឋានៈបែបនេះហើយទើបមាត្រា១១៩ មិនជំទាស់នឹងកម្មករនិយោជិតចំពោះការបញ្ជាក់ថាការទូទាត់ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗរបស់កម្មករនិយោជិតទោះក្នុងពេលអនុវត្តកិច្ចសន្យាក្ដី ទោះក្រោយពេលរំលាយកិច្ចសន្យាក្ដីហើយតាមការបញ្ជាក់នេះកម្មករនិយោជិតសុខចិត្តបោះបង់ទាំងស្រុង ឬមួយផ្នែកនៃសិទ្ធិរបស់ខ្លួនដែលមានចែងក្នុងកិច្ចសន្យាការងារ។

### ១.៥.២ អាជ្ញាយុកាលនៃសិទ្ធិប្ដឹងសុំបើកប្រាក់ឈ្នួល

នៅតាមបណ្ដារោងចក្រ សហគ្រាស កម្មករនិយោជិតទាំងអស់មានសិទ្ធិទាមទារ ឬសិទ្ធិប្ដឹងទាមទារសុំបើកប្រាក់ឈ្នួលក្នុងរយៈពេល០៣(បី)ឆ្នាំរាប់ចាប់ពីថ្ងៃកំណត់បើកប្រាក់ឈ្នួលមក។ (យោងតាមមាត្រា១២០ នៃច្បាប់ការងារ) ក៏ប៉ុន្តែបើយោងតាមមាត្រា៤៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថាអាជ្ញាយុកាលនៃបណ្ដឹងគឺ០៥ឆ្នាំ។ តែមាត្រា៤៨២នៃក្រមនេះក៏បានចែងអំពីករណីថាបើមានបញ្ញត្តិផ្សេងនៃក្រមនេះអាចអនុវត្តបាន។ ដូចនេះមាត្រា១២០នៃច្បាប់ស្ដីពីការងារយើងអាចយកមកអនុវត្តបាន។

សិទ្ធិលើឥណទេយ្យនៃប្រាក់ឈ្នួលដែលមានអាជ្ញាយុកាលកំណត់០៣(បី)ឆ្នាំនេះ គ្របដណ្ដប់លើប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងឥណទេយ្យទាំងអស់របស់កម្មករនិយោជិតដែលមានប្រភពចេញពីកិច្ចសន្យាការងារព្រមទាំងប្រាក់បំណាច់ដែលត្រូវបានក្នុងករណីបណ្ដេញចេញពីការងារ។

## ផ្នែកទី២៖ ការធានាសិទ្ធិនៃប្រាក់ឈ្នួលចំពោះកម្មករនិយោជិត

សិទ្ធិ និងការធានាប្រាក់ឈ្នួល សំដៅដល់ការការពារសិទ្ធិសេរីភាពដូចមានចែងក្នុងច្បាប់ និងការធានាការពារដល់កម្មករនិយោជិតឱ្យរួចផុតពីការរំលោភបំពាននានាដែលប្រុងនឹងកើតមានឡើង ឬដែលកើតមានឡើងលើខ្លួនទាក់ទងនិងប្រាក់ឈ្នួលដូចជា ការកាត់ប្រាល់ឈ្នួល និងការទូទាត់ប្រាល់ឈ្នួល ការកាត់ប្រាក់ឈ្នួល និង

ភាគទានសហជីព ការរឹបអូស និងការផ្ទេរប្រាក់ឈ្នួល ឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់ និងសិទ្ធិទាមទារបើកប្រាក់ឈ្នួល។ នៅក្នុងនោះដែរការធានាដល់ការបើកប្រាក់ឈ្នួល គឺជាការធានាសុវត្ថិភាពកម្មករនិយោជិតបន្ទាប់ពីបានទទួលប្រាក់ឈ្នួលពីនិយោជក ដោយជៀសវាងការជ្រុះបាត់ ឬដោយការបាត់បង់ណាមួយដែលវាអាចនិងកើតឡើង ហើយនិយោជកក៏មិនមានសិទ្ធិក្នុងការហាមឃាត់កម្មករនិយោជិត ចំពោះការចំណាយប្រាក់ឈ្នួលតាមចិត្តរបស់ខ្លួនបានដែរ។

### ២.១ ឯកសិទ្ធិនៃប្រាក់ឈ្នួលរបស់កម្មករនិយោជិត

កម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ត្រូវបានការពារប្រឆាំងនឹងការរំលោភបំពានចំពោះប្រាក់ឈ្នួលពីសំណាក់ម្ចាស់បំណុលរបស់និយោជកមានន័យថានិយោជកត្រូវបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិត មុននឹងទូទាត់សំណងឱ្យម្ចាស់បំណុលរបស់ខ្លួន(អ្នកផ្គត់ផ្គង់សម្ភារៈសំណង់)។ ដើម្បីធានាការសងប្រាក់ឈ្នួលដែលនិយោជកនៅជំពាក់កម្មករនិយោជិតមានឯកសិទ្ធិទូទៅលើចលនទ្រព្យ ឬ អចលនទ្រព្យរបស់កម្មករនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស។ ឯកសិទ្ធិទូទៅមានអត្ថិភាពក្នុងរយៈពេល០៦(ប្រាំមួយ)ខែចុងក្រោយមុនការប្រកាសក្ស័យធន ឬ ការជម្រះបញ្ជីតាមផ្លូវតុលាការ។ ចំណែកអ្នកដើរទាក់ទង និងអ្នកតំណាងពាណិជ្ជកម្ម ប្រាក់កម្រៃជើងសា និងកម្រៃដែលត្រូវបានជាស្ថាពរត្រូវទទួលបានឯកសិទ្ធិក្នុងរយៈពេល០៦(ប្រាំមួយ)ខែចុងក្រោយមុនការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ។ ជាមួយគ្នានេះដែរឯកសិទ្ធិដូចបានរៀបរាប់ខាងលើនេះ ត្រូវបានយកមកអនុវត្តចំពោះឥណទេយ្យរបស់កម្មករនិយោជិតដែលត្រូវបានសម្រាប់ការឈប់សម្រាកដោយមានប្រាក់ឈ្នួល ប្រាក់បំណាច់ទូទាត់ការមិនជូនដំណឹងមុន និងប្រាក់បំណាច់បណ្តេញចេញដែរ[៦៦]។

### ២.២ ការកាត់ប្រាក់ឈ្នួលដោយនិយោជក

#### ២.២.១ ការកាត់ប្រាក់ឈ្នួលដែលជំពាក់

ការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឱ្យអ្នកទទួលរកការងារធ្វើទោះបីចំពោះ ឬមិនចំពោះក្តីឱ្យទៅនិយោជក ឬអ្នកតំណាងនិយោជក ឬ អន្តរការីណាម្នាក់ ក៏ដូចជាភ្នាក់ងារទទួលជ្រើសរើសហត្ថពលករ ត្រូវបានច្បាប់ហាមឃាត់[៦៧]។ក្នុងនោះដែរការទូទាត់ប្រាក់ឈ្នួលណាមួយមិនអនុញ្ញាតឱ្យធ្វើបានទេ ដើម្បីជាប្រយោជន៍ដល់និយោជករវាងប្រាក់ឈ្នួលដែលត្រូវបើកឱ្យកម្មករនិយោជិត និងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវសងឱ្យ

[៦៦] មាត្រា១២១ និងមាត្រា១២២, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៦៧] មាត្រា១២៦, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

និយោជកវិញ ចំពោះការផ្តល់សម្ភារៈផ្សេងៗទោះជាប្រភេទណាក៏ដោយ។ រាល់ការអនុញ្ញាតរួម ដែលអនុញ្ញាតឱ្យដកហូតប្រាក់ឈ្នួលត្រូវចាត់ទុកជាមោឃៈ។

ការទូទាត់ប្រាក់ឈ្នួល និងប្រាក់ជំពាក់ដោយកម្មករនិយោជិតអាចធ្វើបានក្នុង៤ករណីគឺ៖

- គ្រឿងប្រដាប់ប្រដា និងឧបករណ៍ចាំបាច់សម្រាប់ការងារដែលកម្មករនិយោជិតមិនបានយកមកប្រគល់ឱ្យវិញនៅពេលឈប់ធ្វើការ។
- វត្ថុធាតុ និងសម្ភារៈដែលកម្មករនិយោជិតទទួលបន្ទុក និងប្រើប្រាស់។
- ចំនួនប្រាក់ដែលបានបើកមុនដើម្បីទិញវត្ថុទាំងនោះ។
- ចំនួនប្រាក់ដែលនៅជំពាក់អាគារូដ្ឋាន។

ការកាត់ប្រាក់ឈ្នួលពុំអាចធ្វើឡើងលើប្រាក់ឈ្នួលទាំងស្រុងនោះទេ គឺនិយោជកអាចធ្វើការទូទាត់ប្រាក់ឈ្នួលនោះបន្តិចម្តងៗដើម្បីធានាបានថាកម្មករនិយោជិតដែលជំពាក់ ឬខ្ចីប្រាក់អាចធ្វើការចិញ្ចឹមជីវិត និងគ្រួសារបានជាប្រចាំខែ[៦៨]។

### ២.២.២ ការកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព

សហជីពដែលអាចស្នើសុំឱ្យនិយោជកកាត់ប្រាក់ភាគទានពីសមាជិករបស់ខ្លួនបាន លុះត្រាតែសហជីពនោះបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ស្តីពីសហជីព។

ក្រៅពីការកាត់ប្រាក់ឈ្នួលសងនិយោជកហើយ ចំពោះកម្មករនិយោជិតដែលជាសមាជិកសហជីពដែលបានអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន និងបានធ្វើជាលាយលក្ខណ៍អក្សរដើម្បីបង់ភាគទានសហជីពហើយនោះនិយោជកនិងធ្វើការបង់ភាគទាននោះចូលទៅក្នុងគណនីធនាគាររបស់សហជីពដែលកម្មករនិយោជិតនោះជាសមាជិក តែត្រូវបានហាមខាត់មិនឱ្យនិយោជកបង់ប្រាក់ភាគទានទាំងនោះជំនួសកម្មករនិយោជិតទេ។

ចំពោះកាលបរិច្ឆេទនៃការកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព ត្រូវធ្វើការកំណត់ឱ្យដូចនិងថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមីដែរ។

រាល់ការកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីពនេះ សហជីពត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជកឱ្យបានយ៉ាងតិច ១០(ដប់)ថ្ងៃមុនការកាត់ប្រាក់សម្រាប់បង់ភាគទាននេះដោយ

[៦៨] មាត្រា១២៧, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

ការជូនដំណឹងនេះត្រូវប្រាប់អំពីចំនួនប្រាក់ដែលត្រូវកាត់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់បង់ភាគទានសហជីពនោះ។ ប៉ុន្តែរាល់ការអនុញ្ញាតនេះក៏អាចធ្វើការបដិសេធបានគ្រប់ពេលវេលា[៦៩]។

### ២.៣ ការរឹបអូសឃាត់ទុកប្រាក់ឈ្នួល

ការរឹបអូស ឃាត់ទុកប្រាក់ឈ្នួលមិនអាច និងអាចធ្វើទៅបានក្នុងកម្រិតដូចជា៖

- ប្រាក់ឈ្នួលដែលទទួលបានតិចជាង ឬ ស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាមិនអាចធ្វើការរឹបអូស ឬ ផ្ទេរបានជាដាច់ខាត។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីមួយដង ដល់បីដងនៃប្រាក់ឈ្នួលអប្បបរមាដែរត្រូវបានធានាអាចធ្វើការរឹបអូស ឬ ផ្ទេរបាន២០%(ម្ភៃភាគរយ)នៃភាគប្រាក់ឈ្នួល។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីបីដង ដល់ដប់ដងនៃប្រាក់អប្បបរមាដែលត្រូវធានាអាចធ្វើការរឹបអូស ឬផ្ទេរបាន៣០%(សាមសិបភាគរយ)នៃភាគប្រាក់ឈ្នួល។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីដប់ដង នៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាអាចធ្វើការរឹបអូស ឬផ្ទេរបាន៥០%(ហាសិបភាគរយ)នៃភាគប្រាក់ឈ្នួល[៧០]។

### ២.៤ ការគិតភាគប្រាក់ឈ្នួលដែលអាចរឹបអូសបាន

ភាគប្រាក់ឈ្នួលដែលអាចរឹបអូសបានគឺមានន័យថា បរិមាណអតិបរមានៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតដែលអាចរឹបអូសបានគឺតម្រូវឱ្យគិតដូចខាងក្រោម៖

តារាងស្តីពី ការគណនានូវភាគប្រាក់ឈ្នួលដែលអាចរឹបអូសបាន

| ភាគប្រាក់ឈ្នួលធៀបនិងប្រាក់ឈ្នួល អប្បបរមាដែលត្រូវធានា | ភាគរយនៃភាគឈ្នួលដែលអាចរឹបអូសយកបាន | ឧទាហរណ៍: ប្រាក់ឈ្នួល២០០០ ដុល្លារអប្បបរមាដែលត្រូវធានា១៩០ ដុល្លារ។ | ចំនួនសរុបដែលអាចរឹបអូសបាន |
|---|---|---|---|
| ប្រាក់ឈ្នួលអប្បបរមា ឬតិចជាង | 0% | ១៩0-0=១៩0 X0/១00=0 | 0 |

[៦៩] មាត្រា១២៩ កថាខណ្ឌ២, ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧។

[៧០] ប៊ួយ ធីតា,នីតិការងារ(ភ្នំពេញ៖ឆ្នាំ២០១៧),៧៧។

| | | | |
|---|---|---|---|
| ច្រើនជាងប្រាក់ឈ្នួលអប្បបរមារហូតដល់ចំនួនប្រាក់ឈ្នួលអប្បបរមា០៣ដង | ២០% | (១៩០x៣)-១៩០=៣៨០x២០/១០០ =៧៦ | ៧៦ |
| ច្រើនជាងប្រាក់ឈ្នួលអប្បបរមា៣ដល់ប្រាក់ឈ្នួលអប្បបរមា១០ដង | ៣០% | (១៩០X១០)-(១៩០X៣) = ១៣៣០ X៣០/១០០=៣៩៩ | ៣៩៩ |
| ច្រើនជាងប្រាក់ឈ្នួលអប្បបរមា១០ដង | ៥០% | ២០០០-(១៩០X១០) =១០០x៥០/១០០=៥០ | ៥០ |
| | | សរុប=០+៧៦+៣៩៩+៥០=៥២៥ | ៥២៥ |

## ផ្នែកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធនិងប្រាក់ឈ្នួល

### ៣.១ បញ្ហាប្រឈមទូទៅ

យោងតាមសន្និបាតក្នុងរយៈពេលពីរថ្ងៃនេះ គឺរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យមើលអំពីវឌ្ឍន៍ភាពការងារប្រចាំឆ្នាំ២០១៩នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ដែលផ្តោតលើយុទ្ធសាស្ត្រអាទិភាពទាំង៥រួមមាន៖

ទី១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

ទី២-ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ទី៣-ការរក្សានិងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស

ទី៤-ការអភិវឌ្ឍរបបសន្តិសុខសង្គម

ទី៥-ការពង្រឹងសេវាគាំទ្រទូទៅ និងបញ្ហាប្រឈមមួយចំនួន ដើម្បីដាក់ចេញនូវទិសដៅអាទិភាពសម្រាប់អនុវត្តការងារបន្តនៅឆ្នាំ ២០២០[៧]។

តែទោះបីជាមានការជ្រោមជ្រែងពីថ្នាក់ដឹកនាំនានា ឬពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏ដោយក៏ប៉ុន្តែបញ្ហាប្រឈមមួយចំនួននៅតែបន្តកើតមានជាបន្តបន្ទាប់ដូចជាបញ្ហាទាក់ទងទៅនិងប្រាក់បំណាច់

[៧] CMAC, ថ្ងៃទី១៩ កុម្ភៈ ឆ្នាំ២០២០។

អតីតភាពការងារដែលកម្មករនិយោជិតម្នាក់ៗមានការតវ៉ាទាមទាព្រោះតែរោងចក្រ សហគ្រាសមួយចំនួនមិនបានធ្វើការបើកជូនកម្មករនិយោជិតឱ្យបានទៀងទាត់ និងត្រឹមត្រូវនោះទេ តែនៅពេលថ្មីៗនេះដោយសារប្រទេសកម្ពុជាជួបបញ្ហាប្រឈមថ្មីមួយទៀតគឺការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដែលធ្វើឱ្យរោងចក្រ សហគ្រាសបង្ខំចិត្តធ្វើការបិទទ្វា ដោយសង្កេតឃើញផលលំបាករបស់និយោជកដែលជាម្ចាស់រោងចក្រ សហគ្រាសទាំងនេះហើយទើបថ្មីៗនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសអនុញ្ញាតឱ្យម្ចាស់រោងចក្រ សហគ្រាស ពន្យាពេលបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ ទៅបើកឱ្យនៅឆ្នាំ២០២១វិញ។ ទាំងនេះជាការដោះស្រាយផលលំបាកជូននិយោជកដែលជាម្ចាស់រោងចក្រ សហគ្រាស តែបើយើងក្រឡេកមកមើលបញ្ហាប្រឈមរបស់កម្មករនិយោជិតវិញពួកគាត់ពិតជាជួបប្រទះនូវបញ្ហាខ្វះខាតផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងដោយសារការផ្អាកការបើកប្រាក់បំណាច់អតីតភាពការងារនេះ។

### ៣.២ បញ្ហាប្រឈមដោយខ្សែកន្លងឆ្នាំ២០២០

ករណីពិសេសមួយទៀតដោយសារតែបញ្ហាប្រឈមពីមេរោគរាតត្បាតនៃវីរុសកូវីដ១៩ នៅទូទាំងពិភពលោកបានជះឥទ្ធិពលយ៉ាងខ្លាំងស្ទើតែគ្រប់ប្រទេស ដោយក្នុងនោះក៏មានប្រទេសកម្ពុជាមួយផងដែរហើយបញ្ហានេះវាបានធ្វើឱ្យប៉ះពាល់ និងធ្វើឱ្យរាំងស្ទះនូវផែនការណ៍យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ជាពិសេសវិស័យកាត់ដេរនៅប្រទេសកម្ពុជាដែលធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចរបស់កម្មករនិយោជិត ។

### ៣.៣ ការបាត់បង់ការងាររបស់កម្មករនិយោជិតក្នុងអំឡុងពេលវិបត្តិកូវីដ១៩

យោងតាមការដកស្រង់តាមសម្តីរបស់លោក ហេង ស៊ួ អ្នកនាំពាក្យក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈបាននិយាយថា គិតមកត្រឹមខែ ឧសភា ឆ្នាំ២០២០នេះមានរោងចក្រប្រមាណជាង៣៣០រោងចក្រដែលបានព្យួរកិច្ចសន្យាការងារ ហើយក្នុងនោះផងដែរមានជាង១០០រោងចក្របានបញ្ចប់ការព្យួរកិច្ចសន្យាការងារ និងបានបើកដំណើរការផលិតកម្មរបស់ខ្លួនជាធម្មតាវិញ នៅសល់២៣៧រោងចក្រកំពុងបន្តព្យួរកិច្ចសន្យាការងារដដែលដោយការព្យួរនេះទៀតសោធបានធ្វើឱ្យប៉ះពាល់ដល់កម្មករ កម្មការិនីក្នុងវិស័យកាត់ដេរជាង១១ម៉ឺននាក់ ហើយរោងចក្រដែលបានបិទទ្វាត្រឹមត្រូវស្របច្បាប់មានចំនួនជាង២០រោងចក្រ និង៣០រោងចក្រទៀតកំពុងដំណើរការធម្មតាដោយមិនទាន់បានស្នើសុំបិទទ្វាត្រឹមត្រូវតាមនីតិវិធីច្បាប់នៅឡើយទេ[៧២]។

យោងតាមប្រសាសន៍របស់លោកស្រី អ៊ុង ចាន់ធឿន អតីតប្រធានសហជីពមូលដ្ឋានប្រចាំនៅរោងចក្រ

[៧២] Central Cambodia, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០។

វ៉ាយ អូលែត បានមានប្រសាសន៍ថា ស្ថានភាពទូទៅរបស់កម្មករក្នុងវិស័យកាត់ដេរជាដំបូងកម្មករទាំងអស់ត្រូវបានប្រឈមជាមួយនិងការព្យួរការងារដោយសារបញ្ហាកូវីដ១៩ ហើយរោងចក្រក៏បានសន្យាថានិងបើកប្រាក់ទៅលើ៤ចំណុចរួមមានប្រាក់ជូនដំណឹង ប្រាក់អតីតភាពការងារ ប្រាក់បំណាច់ឆ្នាំ និងប្រាក់ខែចុងក្រោយឱ្យកម្មករនិយោជិតតែក្រោយមក គឺបានបើកត្រឹមតែប្រាក់ជូនដំណឹងតែប៉ុណ្ណោះដូចនេះវាបានធ្វើឱ្យប៉ះពាល់ដល់កម្មករនិយោជិតដូចជា៖

- ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ជាខ្លាំង ដោយកម្មករ កម្មការិនីធ្វើការមួយខែសម្រាប់តែមួយខែដោយពួកគាត់ពុំបានសល់លុយសម្រាប់សន្សំទុកនោះទេ
- ត្រូវប្រឈមនិងការធ្វើការឱ្យគេដោយមិនទទួលបានប្រាក់ឈ្នួល ដោយមូលហេតុពួកគាត់ត្រូវបង្ខំចិត្តទៅធ្វើការនៅរោងចក្រស៊ីប្រាក់ថ្ងៃបើមានការដេរខុសនៅថ្ងៃចន្ទដល់សុក្រ នោះសៅរ៍ឬអាទិត្យពួកគាត់ត្រូវទៅដេរឱ្យគេទទេតែម្តង
- បាត់បង់លុយបាយ
- លុយធ្វើដំណើរ
- លុយស្នាក់នៅ
- ប.ស.ស
- ជាពិសេសស្ត្រីមានផ្ទៃពោះដែលត្រូវការប្រាក់សម្រាប់លំហែមាតុភាពជាដើម។ល។

### ៣.៤ ដំណោះស្រាយជួយដល់វិស័យឯកជន និងកម្មករនិយោជិតដែលទទួលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ១៩

យោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលស្តីពីវិធានការក្នុងការជួយដល់វិស័យឯកជន និងកម្មករនិយោជិតដែលទទួលរងផលប៉ះពាល់ដោយសារការរីករាលដាលជម្ងឺកូវីដ១៩ និងវិធានការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចក្រោយវិបត្តិនៃជម្ងឺនេះដោយវិធានការជុំទី៤ដែលត្រូវបានរៀបចំឡើងដោយស្មារតីបុរេសកម្ម និងដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយនោះរួមវិធានការដូចជា៖

#### ៣.៤.១ វិធានជួយរក្សាលំនឹងអាជីវកម្ម និងជីវភាពកម្មករនិយោជិត

<u>វិធានការជួយវិស័យទេសចរណ៍</u>

- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ សម្រាប់២ខែបន្ទាប់ទៀតចាប់ពីខែមិថុនា ដល់ខែ កក្កដាឆ្នាំ២០២០។

- អនុញ្ញាតមិនឱ្យបង់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និងថែទាំងសុខភាព(ប.ស.ស) ក្នុងអំឡុងពេលព្យួរអាជីវកម្ម
- លើកលែងការបង់ថ្លៃបន្តអាជ្ញាប័ណ្ណទេសចេណ៍គ្រប់ប្រភេទ នៅក្នុងវិស័យទេសចរណ៍ក្នុងឆ្នាំ ២០២១ ។

### ៣.៤.២ វិធានការផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្ម

<u>កែសម្រួលកម្មវិធីហិរញ្ញប្បទានពិសេស ៥០លានដុល្លារអាមេរិក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដោយកែសម្រួលលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖</u>

- បន្ថយអត្រាការប្រាក់សម្រាប់កម្ចីទុនបង្វិល
- កែសម្រួលរយៈពេលឥណទានអតិបរមាពី៥ឆ្នាំ ទៅ៧ឆ្នាំសម្រាប់ទុនវិនិយោគ និងរក្សារពេលខ្លីអតិបរមា២ឆ្នាំ សម្រាប់ទុនបង្វិល
- មិនអនុញ្ញាតឱ្យអតិថិជនយកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន
- ផ្តល់ភាពទន់ភ្លន់លើលក្ខខណ្ឌចុះបញ្ជី
- កែសម្រួលលក្ខខណ្ឌត្រូវឱ្យ(សហគ្រាសធុនតូច មធ្យម បង្កើតឱកាសការងារថ្មីចាប់ពី៥ នាក់ឡើងទៅ
- ពង្រើកវិសាលភាពក្នុងការផ្តល់ឥណទានក្នុងគម្រោងនេះដល់សហគ្រាសធន់តូច និង មធ្យម

<u>កែសម្រួលកម្មវិធីសហហិរញ្ញប្បទានពិសេស ១០០លានដុល្លារ រវាងធនាគារសហគ្រាសធនតូច និង មធ្យម ជាមួយនិងគ្រឹះស្ថានហិរញ្ញវត្ថុ និងកែសម្រួលលក្ខខណ្ឌឥណទានដូចខាងក្រោម៖</u>

- អនុញ្ញាតឱ្យមានការកែសម្រួលចំពោះឥណទានដែលកំពុងដំណើរការ
- មិនអនុញ្ញាតឱ្យអតិថិជនយកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន
- ប្តូរពីការតម្រូវឱ្យសងប្រចាំខែ មកសងប្រចាំត្រីមាស ឬឆមាសយ៉ាងយូបំផុតត្រឹម១២ខែ ចំពោះដើមទុន និងការប្រាក់
- កែសម្រួលរយៈពេលឥណទានពី៤ឆ្នាំ ទៅ៧ឆ្នាំដោយឱ្យគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកវាយតម្លៃលើរយៈពេលឥណទានដោយខ្លួនឯងសម្រាប់ទុនបង្វិល និងឥណទានទុនវិនិយោគ
- ពង្រឹងវិសាលភាពនៃការផ្គត់ផ្គង់ឥណទាន
- កែសម្រួលលក្ខខណ្ឌតម្រូវ

### ៣.៤.៣ ការបង្កើនហិរញ្ញប្បទានបន្ថែមដើម្បីស្តារ និងជំរុញកំណើនក្រោយវិបត្តិកូវីដ-១៩

**វិធានការបង្កើន និងសម្រួលសាច់ប្រាក់៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យ និងកែសម្រួលលក្ខខណ្ឌមួយចំនួនក្នុងការសម្រួលលំហូរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារថែមទៀត។

**ការបន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុកលើការប្រាក់សម្រាប់អ្នកផ្តល់កម្ចីក្នុងស្រុក និងក្រៅស្រុក**

**សម្រាប់កម្ចីថ្មី**

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារទាំងប្រភពខាងក្រៅ និងខាងក្នុងស្រុកមកនៅត្រឹម៥% (ទាំងការខ្ចីពីប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនិងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការជៀសវាងពន្ធ (DTA) និងការខ្ចីពីប្រទេសដែលមិនមាន)សម្រាប់ឆ្នាំ២០២០
- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារទាំងប្រភពខាងក្រៅ និងខាងក្នុងស្រុកមកនៅត្រឹម១០% (ទាំងការខ្ចីពីប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនិងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការជៀសវាងពន្ធ(DTA) និងការខ្ចីពីប្រទេសដែលមិនមាន)សម្រាប់ឆ្នាំ២០២១
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារទាំងប្រភពខាងក្រៅ និងខាងក្នុងស្រុក (ឱ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានវិញនៅឆ្នាំ២០២០

សម្រាប់កម្ចីចាស់:

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារទាំងប្រភពខាងក្រៅ និងខាងក្នុងស្រុកមកនៅត្រឹម១០% (ទាំងការខ្ចីពីប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនិងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការជៀសវាងពន្ធ(DTA) និងការខ្ចីពីប្រទេសដែលមិនមានDTA)សម្រាប់ឆ្នាំ២០២១
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារទាំងប្រភពខាងក្រៅ និងខាងក្នុងស្រុក(ឱ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានវិញនៅឆ្នាំ២០២១

**ប្រភពហិរញ្ញប្បទានសម្រាប់ទុនបង្វិល**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំ(មូលនិធិធានាឥណទាន)ដើម្បីជួយសម្រួលសម្ពាធលំហូសាច់ប្រាក់ និងទុនបង្វិលអាជីវកម្ម ធុរកិច្ចគ្រប់វិស័យ បានយ៉ាងតិចចំនួន ២.០០០លានដុល្លាររអាមេរិក។

<u>ការត្រៀមឧបករណ៍ផ្តល់ហិរញ្ញប្បទាន</u>

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងត្រៀមថវិការសម្រាប់ហិរញ្ញប្បទានបន្ថែមចំនួន៣០០លានដុល្លារ ដើម្បីគាំទ្រ និងជំរុញកំណើនតាមវិស័យសំខាន់ៗទាំងក្នុងអំឡុងពេលវិបត្តិ និងក្រោយពេលវិបត្តិ។

**៣.៤.៤ វិធានការជំនួយសង្គម**

- រាជរដ្ឋាភិបាលសម្រេចពង្រីកវិសាលភាពគ្របដណ្តប់ និងទំហំថវិការសម្រាប់ (កម្មវិធីសាច់ប្រាក់ពលកម្ម) ក្នុងឆ្នាំ២០២០ ឱ្យឡើងដល់១០០លានដុល្លារដើម្បីស្រូបយកកម្លាំងពលកម្មដែលបាត់បង់ការពីរោងចក្រសហគ្រាស និងជនដែលវិលត្រលប់ពីបរទេសមកស្រុកកំណើតវិញ
- នៅក្នុងខែមិថុនា ឆ្នាំ២០២០ នេះរាជរដ្ឋាភិបាលនិងដាក់នូវកម្មវិធីជំនួយសង្គមសំដៅជួយសម្រួលជីវភាពប្រចាំថ្ងៃនៅក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះ និងកុមារអាយុក្រោម៥ឆ្នាំ ជនពិការ ចាស់ជរាអាយុចាប់ពី៦០ឆ្នាំឡើងជាដើម ។

**៣.៤.៥ ការដាក់ឱ្យអនុវត្តចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច**

- រាជរដ្ឋាភិបាលនិងដាក់ឱ្យដំណើរការជំហានទី១នូវថ្នាលចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច នៅដើមខែមិថុនា ឆ្នាំ២០២០នេះ ដើម្បីសម្រួល និងជំរុញដល់ការចុះបញ្ជីក្រុមហ៊ុនទូទៅ និងជាពិសេសជួយសម្រួលដល់ក្រុមហ៊ុនដែលមានបំណងចុះបញ្ជីដើម្បីទទួលបានកម្ចីពីកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល។

ម្យ៉ាងវិញទៀតនោះដោយឃើញប្រជាពលរដ្ឋដែលជាកម្មករនិយោជិតជួបនូវបញ្ហាប្រឈមបែបនេះរាជរដ្ឋាភិបាលដែលជាថ្នាក់ដឹកនាំក្នុងប្រទេសកម្ពុជាក៏បានដោះស្រាយរាល់បញ្ហាទាំងនេះនិងដាក់ចេញនូវវិធានការណ៍ដើម្បីជួយសម្រួលបញ្ហាទាំងនេះផងដែរ។

យោងតាមប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានប្រកាសថាកម្មករកម្មការិនីនឹងទទួលបានប្រាក់ឈ្នួលក្នុងទំហំ៦០ភាគរយនៃប្រាក់ឈ្នួលគោលរបស់ពួកគេ ក្នុងករណីរោងចក្រព្យួរការងារ។

ក្នុងការថ្លែងសារពិសេសមួយជូនជនរួមជាតិខ្មែរពាក់ព័ន្ធស្ថានភាពថ្មីៗចុងក្រោយនៃជំងឺកូរ៉ូណាវីរុសថ្មី ឬ Covid19 នៅវិមានសន្តិភាពកាលពីថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០២០ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានប្រសាសន៍ថារដ្ឋាភិបាលកម្ពុជា និងភាគីរោងចក្របានសម្រេចផ្តល់ប្រាក់ឈ្នួលជូនកម្មករកម្មការិនី ៦០ភាគរយ អំឡុងពេលនៃការផ្អាកដំណើរការរយៈពេលខ្លីរបស់រោងចក្រដែលរងផលប៉ះពាល់ដោយសារបញ្ហាវីរុសកូរ៉ូណាថ្មី។

លោកនាយករដ្ឋមន្ត្រីបញ្ជាក់ទៀតថា ប្រាក់ឈ្នួល៦០ភាគរយដែលកម្មករទទួលបានអំឡុងពេលព្យួរការងារនោះគឺភាគីរោងចក្រចេញ ៤០ភាគរយ និងរដ្ឋាភិបាលចេញ ២០ភាគរយ នៃប្រាក់ឈ្នួលអប្បបរមារបស់កម្មករនៅឆ្នាំ២០២០នេះ ពោលគឺកម្មករត្រូវទទួលប្រាក់ឈ្នួល ១១៤ដុល្លារអំឡុងពេលរោងចក្រព្យួរការងារ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានឱ្យដឹងបន្ថែមទៀតថាក្នុងករណីរោងចក្របិទទ្វារវិញ គឺរដ្ឋាភិបាលសម្រេចបើកប្រាក់សំណងជូនកម្មករ១២០ដុល្លារជូនកម្មកររយៈពេល០៦ខែប៉ុន្តែសម្រាប់ប្រាក់សំណង ៤ខែគឺ រដ្ឋាភិបាលយកទៅប្រើប្រាស់លើការចំណាយសម្រាប់បើកវគ្គបណ្តុះបណ្តាល និងសល់២ខែទៀត កម្មករទទួលដោយផ្ទាល់។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានថ្លែងថា៖ សម្រាប់រោងចក្រសហគ្រាសដែលផ្អាកសកម្មភាពផលិតរយៈពេលខ្លីដោយសារខ្វះវត្ថុធាតុដើមត្រូវចេញប្រាក់ខែ៤០ភាគរយនៃប្រាក់ខែអប្បបរមារបស់កម្មករនិយោជិតដែលមានចំនួន ១៩០ដុល្លារនៅឆ្នាំ២០២០ ខណៈដែលរដ្ឋាភិបាលចូលរួមចំណែក ២០ភាគរយនៃប្រាក់ខែអប្បបរមានេះ។

# សេចក្តីសន្និដ្ឋាន

៙៙*៙៙

ឆ្លងតាមរយៈបទពិសោធន៍នៃការសិក្សាស្រាវជ្រាវ ការវិភាគស្វែងយល់ ការសរសេរបកស្រាយខាងលើនេះរួចមកឃើញថា ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ បានផ្តល់ផលប្រយោជន៍ និងគុណសម្បត្តិជាច្រើនដល់ភាគីដែលពាក់ព័ន្ធ ជាពិសេសភាគីនិយោជក និងកម្មករនិយោជិតដោយមានគោលដៅធានាដល់សិទ្ធិ និងការការពារផ្នែកសង្គមដល់កម្មករនិយោជិត ព្រមទាំងផ្តល់សុវត្ថិភាព គតិយុត្តដល់និយោជក ឬនិយោជិនក្នុងការផ្តល់អត្រាប្រាក់ឈ្នួលដល់កម្មករនិយោជិតរបស់ខ្លួន និងចំណុចដែលគួរឲ្យកត់សម្គាល់នោះគឺប្រាក់ឈ្នួលអប្បរមាដែលត្រូវធានាជូនកម្មករនិយោជិតមានការកើនឡើងជាលំដាប់។ ដែលកាលពីឆ្នាំ១៩៩៧ប្រាក់ឈ្នួលអប្បបរាដែលត្រូវធានាមានត្រឹមតែ ៤០ដុល្លារអាមេរិក ឆ្នាំ២០០០មានត្រឹម ៤៥ដុល្លារអាមេរិក ឆ្នាំ២០០៧មានត្រឹម៥០ដុល្លារអាមេរិក រហូតមកដល់ក្នុងឆ្នាំ២០២០នេះប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាមានរហូតដល់១៩០ដុល្លារអាមេរិក ដែលជាតួរលេខមួយយ៉ាងល្អ។

ក្នុងនោះផងដែរក៏មានការតាក់តែងបទដ្ឋានគតិយុត្តដើម្បីជួយសម្រួលបន្ថែមទៅលើច្បាប់ការងារផងដែរយ៉ាងណាមិញដូចជាប្រាក់បំណាច់អតីតាភាពការដែលមុនឆ្នាំ២០១៨មិនទាន់មាននោះទេ ដែលត្រូវបានអនុវត្តដោយប្រាក់បំណាច់បណ្តេញចេញវិញ។ ប្រាក់បំណាច់បណ្តេញចេញនេះកម្មករនិយោជិតទទួលបាននៅពេលដែលខ្លួនទទួលរងការបណ្តេញចេញដោយនិយោជកដោយគ្មានហេតុផលត្រឹមត្រូវ ដូចនេះទោះបីជាកម្មករនិយជិតធ្វើការយូរប៉ុណ្ណាមិនទទួលប្រាក់នេះដែរលុះត្រាតែមានការបណ្តេញចេញ វាជាការខាតបង់របស់កម្មករនិយោជិត ទើបមានការបង្កើតឲ្យមានប្រាក់បំណាច់អតីតភាព ដែលបានតាមរយៈពេលដែលកម្មករនិយោជិតធ្វើការនោះ។

ប៉ុន្តែជាមួយគ្នាដែរនេះបានសង្កេតឃើញថាប្រាក់វិភាជន៍សម្រាប់គ្រួសាររបស់កម្មករនិយោជិតមិនមានការកំណត់ច្បាស់លាស់ទេ ដែលធ្វើឲ្យកម្មករនិយោជិតភាគច្រើនបាត់នូវប្រាក់វិភាជន៍សម្រាប់គ្រួសារនេះ ហើយប្រាក់វិភាជន៍សម្រាប់គ្រួសារនេះមានកម្មករនិយោជិតភាគតិចណាស់ដែលទទួលបាន ជាពិសេសកម្មករនិយោជិតដែលបានធ្វើការក្នុងលក្ខខណ្ឌការងារល្អៗប៉ុណ្ណោះ។

មួយវិញទៀតសម្រាប់ការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិតដែលត្រូវទទួលបានការឈប់សម្រាកហើយត្រូវទទួលបានប្រាក់ឈ្នួលដែលមានរយៈពេលមួយថ្ងៃកន្លះក្នុងមួយខែ និងត្រូវជា១៨ថ្ងៃក្នុងមួយឆ្នាំនៅពេលដែលកម្មករនិយោជិតធ្វើការពេញមួយឆ្នាំអត់ឈប់ និងបានគោរពតាមលក្ខខណ្ឌមាត្រា១៦៦នៃច្បាប់ការងារ តាមការសិក្សាបានសង្កេតឃើញថាសហគ្រាស រោងចក្រមួយចំនួនមិនបានផ្តល់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ

នោះទេបែរជាព្រមព្រៀងជាមួយកម្មករនិយោជិតផ្តល់ប្រាក់ទទួទាត់ជំនួសការឈប់សម្រាកនោះទៅវិញ ដែលជាការផ្ទុយនិងច្បាប់ការងារមាត្រា១៦៧ គឺបានហាមឃាត់ការទូទាត់ប្រាក់ជួសឲ្យការឈប់សម្រាកប្រចាំឆ្នាំទៅវិញ តែចំណុចនេះផងដែរគួឲ្យកត់សម្គាល់គឺកម្មករនិយោជិតសុខចិត្តទទួលការទូទាត់ជួសនេះទៅវិញ។

ចំពោះសិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធនិងប្រាក់ឈ្នួលគឺនិយោជកបានអនុវត្តតាមវិធានដែលមានចែងនៅក្នុងច្បាប់ការងារបានល្អ ទាំងពេលវេលាបើកប្រាក់ឈ្នួល ទីកន្លែងបើកប្រាក់ឈ្នួល និងការជូនដំណឹងស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតជាដើម។ ហើយទោះបីជាមានវិវាទស្តីពីប្រាក់ឈ្នួលមួយចំនួនក៏ដោយ ក៏វិវាទនោះត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ប៉ុន្តែចំពោះការរឹបអូសប្រាក់ឈ្នួលដែលជំពាក់នៅតែជាបញ្ហាសម្រាប់កម្មករនិយោជិតព្រោះកម្មករនិយោជិតភាគច្រើនមិនបានដឹងអំពីការកម្រិតនៅប្រាក់ឈ្នួលដែលអាចរឹបអូសបាននោះទេ ពេលខ្លះការរឹបអូសនោះអាចច្រើនហួស និងមិនត្រូវតាមច្បាប់ធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់កម្មករនិយោជិត ដូចនេះកម្មករនិយោជិតត្រូវដឹងពីសិទ្ធិរបស់ខ្លួន។

ដោយឡែកប្រទេសកម្ពុជានាពេលបច្ចុប្បន្នកំពុងតែជួបវិបត្តកូវីដ១៩ ដែលបណ្តាលអោយកម្មករនិយោជិតបាត់បង់ការងារ និងប៉ះពាល់ដល់ប្រាក់ចំណូល ជាមួយគ្នានេះផងដែររាជរដ្ឋាភិបាលក៏បានចាត់វិធានការរក្សាលំនឹងអាជីវកម្ម និងជីវភាពកម្មករនិយោជិត វិធានការផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្ម និងវិធានការបង្កើនហិរញ្ញប្បទានបន្ថែមដើម្បីស្តារ និងជំរុញកំណើនក្រោយវិបត្តិកូវីដ១៩ជាដើម ដើម្បីជួយសម្រាលផលប៉ះពាល់ដែលបណ្តាលមកពីបញ្ហាកូវីដ១៩នេះ ក៏ប៉ុន្តែការបាត់បង់ការងារធ្វើនៅតែមានចំពោះកម្មករនិយោជិតដដែល កាលណាជម្ងឺកូវីដ១៩នៅមិនទាន់បញ្ចប់។

សរុបសេចក្តីមកប្រាក់ឈ្នួលកម្មករនិយោជិតដែលស្ថិតនៅក្រោមច្បាប់ការងារ១៩៩៧ មានភាពល្អប្រសើរព្រោះថាបានផ្តល់អត្ថប្រយោជន៍ជាច្រើនជូនដល់កម្មករនិយោជិតដែលមានដូចជា លក្ខខណ្ឌការងារល្អៗ ប្រាក់ឈ្នួលសមរម្យសម្រាប់ជីវភាព និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិត និងអត្ថប្រយោជន៍ជាច្រើនទៀត ទន្ទឹមគ្នាផងដែរក៏មានចំណុចខ្លះដែលមិនទាន់អនុវត្តបានល្អដូចជា ការមិនទាន់មានការកំណត់នូវប្រាក់វិភាជន៍គ្រួសារសម្រាប់កម្មករនិយោជិតឲ្យបានច្បាស់លាស់ ការអនុវត្តការឈប់សម្រាកប្រចាំឆ្នាំមិនពេញលេញសម្រាប់គ្រឹះស្ថាន រោងចក្រ សហគ្រាសមួយចំនួន និងវិធានការដោះស្រាយបញ្ហាប្រឈមរបស់កម្មករនិយោជិតចំពោះការបាត់បង់ការងារអំឡុងពេលវិបត្តកូវីដ១៩។

ដូចនេះប្រាក់ឈ្នួលរបស់កម្មករនិយោជិតពីមួយឆ្នាំទៅមួយឆ្នាំមានការរីវឌ្ឍជាបន្តបន្ទាប់ ដែលជាតួរលេខមួយយ៉ាងល្អសម្រាប់កម្មករនិយោជិត ហើយច្បាប់ការងារ១៩៩៧ រួមទាំងបទដ្ឋានគតិយុត្តដែលទាក់ទង និងប្រាក់ឈ្នួលបានផ្តល់នូវអត្ថប្រយោជន៍ការងារជាច្រើនទៀតដល់កម្មករនិយោជិត នេះជាភាពល្អប្រសើរមួយនៃវិស័យការងារក្នុងប្រទេសកម្ពុជា បើធៀបទៅនិងប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ ហើយក៏មានចំណុចមួយចំនួន

មិនទាន់អនុវត្តបានល្អនៅឡើយ ដែលទាមទារឲ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដូចជារាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជក និងតំណាងកម្មករនិយោជិតដើម្បីដោះស្រាយបញ្ហាដូចជាការមិនទាន់បានអនុវត្តតាមច្បាប់ការងារដែលបានចែងពេញលេញ និងបញ្ហាប្រឈមចំពោះមុខគឺការបាត់បង់ការងាររបស់កម្មករនិយោជិតក្នុងអំឡុងពេលវិបត្តកូវីដ១៩។

# អនុសាសន៍

ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង និងមិនទាន់កើតមានឡើងនៅក្នុងវិស័យការងារជាពិសេសទាក់ទង និងប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជាយើងខ្ញុំសូមសំណូមពរដល់៖

- ប្រមុខរាជរដ្ឋាភិបាលកម្ពុជាគួរតែពង្រឹងវិធានការណ៍ និងឃ្លាំមើលភាគីដែលពាក់ព័ន្ធក្នុងវិស័យការងារ អោយអនុវត្តគោរពតាមបទប្បញ្ញត្តិ ឬប្រកាសដែលបានចែងអោយបានខ្ជាប់ខ្ជួន។
- ប្រមុខរាជរដ្ឋាភិបាលបន្តគិតគូពីការវិវត្តនៃប្រាក់ឈ្នួលរបស់កម្មករនិយោជិតជាបន្តបន្ទាប់ ដើម្បីជំរុញជីវភាពកម្មករនិយោជិតនៅក្នុងប្រទេសរបស់ខ្លួនអោយមានភាពល្អប្រសើរឡើងជាលំដាប់។
- ក្រសួង ស្ថាប័នមានសមត្ថកិច្ចចុះត្រួតពិនិត្យស្តង់ដារគ្រឹះស្ថាន រោងចក្រ សហគ្រាសដើម្បីធានាសុវត្ថិភាពដល់កម្មករនិយោជិត និងបញ្ចៀសពីគ្រោះថ្នាក់ផ្សេងៗ ។
- រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តតាក់តែងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលផ្តល់អត្ថប្រយោជន៍ការងារបន្ថែម ព្រមទាំងលក្ខខណ្ឌការងារល្អៗដល់កម្មករនិយោជិត។
- ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោយពីការរីករាលដាលនៃជម្ងឺកូវីដ១៩បានបញ្ចប់ សូមធ្វើការស្វែងរកវិនិយោគិនមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាឡើងវិញ និងស្វែងរកអោយបានកាន់តែច្រើនជាងមុនទៅទៀតដើម្បីធានាដល់ការរស់នៅរបស់កម្មករនិយោជិតអោយសមាមាត្រនឹង សេដ្ឋកិច្ច តម្លៃទីផ្សារ និងជីវភាពរស់នៅរបស់ប្រជាជនដទៃទៀតក្នុងសង្គមកម្ពុជា។
- ស្ថាប័នរាជរដ្ឋាភិបាល និងភាគីនិយោជកត្រូវតែធានាដល់សិទ្ធិ និងធានាលើប្រាក់ឈ្នួលរបស់កម្មករនិយោជិត រួមទាំងធានាសុខសុវត្ថិភាព សុខុមាលភាពរបស់កម្មករនិយោជិតដើម្បីប្រការ និងការពារបញ្ហាដែលកើតមានជាយថាហេតុណាមួយ។
- អធិការការងារគួរតែចុះពង្រឹង និងត្រួតពិនិត្យឡើងវិញនូវបញ្ហាដែលកើតមានឡើងតាមរោងចក្រ សហគ្រាស គ្រឹះស្ថានជាពិសេសការដ្ឋានសំណង់ទាក់ទងនិងបរិយាកាសនៅកន្លែងធ្វើការងារ សមភាពប្រាក់ឈ្នួល និងម៉ោងធ្វើការជាដើម។
- អធិការការងារចាត់វិធានការយ៉ាងតឹងរឹងចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាននានាដែលមិនគោរពតាមច្បាប់ និងបទបញ្ញត្តិដែលបានចែង និងដាក់អោយអនុវត្តជាធរមាន។
- ម្ចាស់រោងចក្រ សហគ្រាស និងបណ្តាគ្រឹះស្ថានទាំងអស់ចូលរួមអនុវត្តតាមច្បាប់ការងារ និងបទដ្ឋានគតិយុត្តដែលបានចែង ដើម្បីបង្កភាពងាយស្រួលដល់កម្មករនិយោជិតដែលមិនសូវយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ។

- រោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងឡាយដែលមិនទាន់បានចុះបញ្ជី សូមធ្វើការចុះបញ្ជីរោងចក្រ សហគ្រាស និងគ្រឹះស្ថានរបស់ខ្លួន អោយបានត្រឹមត្រូវស្របច្បាប់ ដើម្បីចូលរួមអនុវត្តតាមច្បាប់ការងារ និងកាតព្វកិច្ចពន្ធដារជាដើម។

# ឯកសារយោង

**ច្បាប់និង លខិតបទដ្ឋានគតិយុត្ត**

**ក. ច្បាប់**

ច្បាប់ស្តីពីការងារ,ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧

ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា,លេខ នស/រកម/០៧១៨/០១៥,០៩ កក្កដា ២០១៨,

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ចំណងជើងចំណុច(គ) ផ្នែកទី៣នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១

មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៣៩៧ /០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ លេខ នស/រកម/០៦១៨/០១០,ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា១៤៤នៃច្បាប់ស្តីពីការងារ,នស/រកម/០៧០៧/២០,២០ កក្កដា

២០០៧។

**ខ.ប្រកាស និងសារាចរណ៍**

ប្រកាសលេខស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារលេខ៤៤៣ក.ប/ប្រ.ក.ខ,ចុះថ្ងៃ២១ខែកញ្ញាឆ្នាំ២០១៨។

ប្រកាសស្តីពី តាវកាលិថៃទាសុភាព,លេខ១០៩ ក.ប/ប្រ.ក,ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧,ប្រការ៦ និងប្រការ៧។

ប្រកាសស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០២០,លេខ៣៩៩/១៩ ក.ប/ប្រ.ក.អ.ធ.ក,ចុះថ្ងៃទី០៤ ខែតុលាឆ្នាំ២០១៩។

ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរនិងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៦,លេខ៤០៩/១៥ ក.ប/ប្រ.ក,ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥។

ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរនិងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧,លេខ៤១៥ ក.ប/ប្រ.ក,ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦។

ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរនិងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨,លេខ៣៩៦ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧។

ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរនិងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩,លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល,ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

ប្រកាសស្តីពីការឈប់សម្រាកពិសេស,លេខ២៦៧ សកបយ,ចុះថ្ងសទី១១ ខែតុលា ឆ្នា២០១១។

សារាចរណ៍ស្តីពីប្រាក់ឈ្នួលនៃការងារពេលយប់,លេខ១៨៥/កប រ.ស ,១៤ សីហា ២០០៧។

**គ. សេចក្តីជូនដំណឹង និងសេចក្តីណែនាំ**

សេចក្តីជូនដំណឹងស្តីពីការការងារបន្ថែមលេខ ០៣០/១៥ កប/ស.ជ.ណ,ចុះថ្ងៃ២៧ កុម្ភះ ២០១៥។

សេចក្តីជូនដំណឹងលេខ០៤១/១១កប/ស.ជ.ណ,ចុះថ្ងៃទី ០៧ មីនា ឆ្នាំ២០១១។

សេចក្តីណែនាំស្តីពីការទូទាត់ប្រាក់បំណាចអតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩លេខ០៥៨/១៩ ក.ប/ស.ណ.ន.ខ.ល,ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និអត្ថប្រយោជន៍ផ្សេងៗ លេខ០០១/១៤ ក.ប/ស.ជ.ណ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤។

សេចក្តីជូនដំណឹងស្តីពីការលើកថ្ងៃឈប់សម្រាកក្នុងបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០,លេខ០១២/២០ ក.ប/ស.ជ.ណ.ខ.ល,ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

សេចក្តីណែនាំស្តីពីការអនុវត្តការសងការឈប់សម្រាកពិសេស, លេខ០១០/២០ក.ប/ស.ណ.ន.ខ.ល,ចុះថ្ងៃ២១ ខែកុម្ភៈ ឆ្នាំ២០២០។

សេចក្តីជូនដំណឹងលេខ០៦ សកអ,ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧។

សេចក្តីជូនដំណឹងលេខ៧៤៥ ក.ក.ប.វ,ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

សេចក្តីជូនដំណឹងលេខ០៤៩កប/ស.ជ.ណ,ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០។

សេចក្តីជូនដំណឹងលេខ១០៣ ក.ប/ស.ជ.ណ,ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣។

**សៀវភៅ**

ប៊ួយ ធីតា.២០១៧,នីតិការងារ.ភ្នំពេញ។

ការិយាល័យពលកម្មអន្តរជាតិរោងចក្រកាន់តែប្រសើរនៅកម្ពុជា.២០១៣,សៀវភៅណែនាំអំពីច្បាប់ការងារនៃប្រទេសកម្ពុជាសម្រាប់វិស័យកាត់ដេរ.ភ្នំពេញ

**គេហទំព័រ**

CentralCambodia.ការបាត់បង់ការងាររបស់កម្មករកំឡុងពេលកូវីត១៩.ដកស្រង់ចេញផាននេលយូធូម https://www.youtube.com/watch?v=GihR1Fovm8U&feature=youtu.be&fbclid=IwAR1F8SDCS6kPuCjrG9AVb7qrc5X1U0qiFWpz_NpdvJd22Wht5Xq22KPtHng,ថ្ងៃទី១៦ កក្កដា ឆ្នាំ ២០២០។

# ឧបសម្ព័ន្ធ១

# ព្រះរាជក្រម

នស/រកម/០៧១៨/ ០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩៥/០០៣/២០១៨ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

# ប្រាក់ឈ្នួលអប្បបរមា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/១០

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ច្បាប់នេះមានគោលបំណង៖

- លើកកម្ពស់ជីវភាពរស់នៅសមរម្យ ថ្លៃថ្នូរ បង្កើតឱកាសការងារ និងបង្កើនផលិតភាពរបស់កម្មករនិយោជិត
- ជំរុញឲ្យមានបរិយាកាសវិនិយោគនិងធុរកិច្ចកាន់តែប្រសើរប្រកបដោយភាពទាក់ទាញ។

**មាត្រា២ .–**

ច្បាប់នេះមានគោលដៅដូចតទៅ៖

- ធានាការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បង្កើតនីតិវិធីកំណត់ប្រាក់ឈ្នួលអប្បបរមាតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច
- បង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដើម្បីជាយន្តការត្រីភាគីសម្រាប់សិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍អំពីប្រាក់ឈ្នួលអប្បបរមានិងអត្ថប្រយោជន៍ផ្សេងៗរបស់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា៣ .–**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើសហគ្រាសឬគ្រឹះស្ថាននិងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ជំពូកទី២
## ប្រាក់ឈ្នួលអប្បបរមា

**មាត្រា៤ .–**

ប្រាក់ឈ្នួល យ៉ាងតិចណាស់ក៏ត្រូវឲ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលជាប្រាក់ឈ្នួលកម្រិតទាបបំផុត និងត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា៥ .–**

ធាតុផ្សំសម្រាប់យកមកពិចារណាក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាគឺត្រូវផ្តោតទៅលើលក្ខខណ្ឌសេដ្ឋកិច្ច តម្លៃជីវភាពរស់នៅ និងស្ថានភាពជាក់ស្តែងរបស់ប្រទេស។

ធាតុផ្សំទាំងនោះគឺ៖

១- លក្ខណៈវិនិច្ឆ័យបែបសង្គមដែលរួមមានស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ។

២- លក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ចដែលរួមមាន ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាអាចកែសម្រួលលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាទៅតាមសកម្មភាពសេដ្ឋកិច្ច វិជ្ជាជីវៈ មុខរបរ ឬតំបន់ ដោយយោងទៅលើស្ថានភាពសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស។

**មាត្រា៦ .-**

ការព្រមព្រៀងជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់ណាដែលស្ថិតក្នុងវិសាលភាពអនុវត្តប្រាក់ឈ្នួលអប្បបរមា ហើយដែលតម្រូវឲ្យប្រាក់ឈ្នួលទៅកម្មករនិយោជិតទាបជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវអនុវត្តនោះ ត្រូវទុកជាមោឃៈ។

ការព្រមព្រៀងជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់ណាដែលស្ថិតក្នុងវិសាលភាពអនុវត្តប្រាក់ឈ្នួលអប្បបរមា ហើយដែលតម្រូវឲ្យប្រាក់ឈ្នួលទៅកម្មករនិយោជិតខ្ពស់ជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវអនុវត្តនោះ ត្រូវបន្តអនុវត្ត។

**មាត្រា៧ .-**

ចំពោះការងារម៉ៅការឬតាមបរិមាណផលិតផល ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឲ្យកម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតា បានទទួលក្នុងចិរវេលាធ្វើការដែលនូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិតនោះ។

កម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល ត្រូវទទួលបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួលអប្បបរមា កម្មករនិយោជិតនោះត្រូវទទួលបានតាមចំនួនលើសនោះ។ ប្រសិនបើទាបជាងប្រាក់ឈ្នួលអប្បបរមា និយោជកត្រូវបន្ថែមឲ្យគ្រប់ចំនួនស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា។

**មាត្រា៨ .-**

ចំពោះការងារដែលមានលក្ខខណ្ឌស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវឲ្យស្មើគ្នាដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតក្រោមវិសាលភាពនៃច្បាប់នេះ ដោយមិនគិតពីដើមកំណើត ភេទ ឬអាយុ ។

**មាត្រា៩ .-**

ប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវរៀបចំឡើងដោយមិនគិតថាវិជ្ជាជីវៈណាឬមុខរបរណាឡើយ។ ប្រាក់ឈ្នួលអប្បបរមានោះអាចប្រែប្រួលតាមតំបន់ តាមលក្ខខណ្ឌសេដ្ឋកិច្ចដែលសម្រាប់កំណត់លក្ខខណ្ឌជីវភាព។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចកំណត់អាទិភាពនៃវិសាលភាព ដែលត្រូវអនុវត្តប្រាក់ឈ្នួលអប្បបរមា ទៅតាមសកម្មភាពសេដ្ឋកិច្ច វិជ្ជាជីវៈ មុខរបរ ឬតំបន់ ដោយយោងទៅលើស្ថានភាពសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស បន្ទាប់ពីបានទទួលអនុសាសន៍ពីក្រុមប្រឹក្សាជាតិ[illegible]លអប្បបរមា។

## ជំពូកទី៣
## ការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា

**មាត្រា១០ .-**

ការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

១- ការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាត្រូវធ្វើឡើងតាមកាលកំណត់ដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

២- ប្រាក់ឈ្នួលអប្បបរមាត្រូវតែជាតួលេខឬអត្រាបម្រែបម្រួលដែលអាចព្យាករបានពោលគឺត្រូវកើនតាមលំដាប់បន្តបន្ទាប់។

៣- ប្រកាន់យកគោលការណ៍ឈ្នះ-ឈ្នះ។

៤- ត្រូវប្រើប្រាស់ទិន្នន័យផ្លូវការស្របច្បាប់របស់ស្ថាប័នជាតិឬអង្គភាពនានាដែលទទួលបន្ទុកផលិតស្ថិតិ និងយកលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ មកធ្វើជាមូលដ្ឋានក្នុងការពិភាក្សា។

**មាត្រា១១.-**

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវចេញប្រកាសកំណត់កាលវិភាគនៃការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា បន្ទាប់ពីទទួលបានអនុសាសន៍របស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

ក្នុងករណីប្រធានសក្តិឬករណីចាំបាច់ណាមួយ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចចេញប្រកាសផ្អាកឬកែសម្រួលកាលវិភាគនៃការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាបាន។ ក្នុងករណីនេះ ប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ចុងក្រោយនឹងមានសុពលភាពអនុវត្តបន្តរហូតមានការកំណត់ប្រាក់ឈ្នួលអប្បបរមាថ្មីមកជំនួស។

**មាត្រា១២ .-**

ដើម្បីចូលរួមពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា ភាគីនីមួយៗនៃក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវស្វែងរកឲ្យមានគោលជំហរផ្លូវការរបស់ខ្លួនមួយ ដោយប្រើប្រាស់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

ក្នុងករណីដែលមិនអាចស្វែងរកគោលជំហរផ្លូវការដោយការឯកភាពជាឯកច្ឆន្ទ ភាគីនីមួយៗត្រូវយកសំឡេងភាគច្រើនដោយការបោះឆ្នោតផ្ទៃក្នុង ដើម្បីកំណត់គោលជំហរផ្លូវការរបស់ខ្លួន និងមិនត្រូវបំពានគោលជំហរផ្លូវការដែលភាគីខ្លួនបានសម្រេចដើម្បីយកទៅពិភាក្សានោះឡើយ។

ការសម្រេចអំពីតួលេខឬអត្រាបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមាដោយក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវផ្អែកលើគោលការណ៍ឯកភាពជាឯកច្ឆន្ទនៃសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ។ ក្នុងករណីមិនមានការឯកភាពជាឯកច្ឆន្ទលើចំណុចណាមួយចំនួន២(ពីរ)ដងនៅក្នុងកិច្ចប្រជុំចំនួន២(ពីរ)ផ្សេងគ្នា ការសម្រេចត្រូវផ្អែកលើសំឡេងភាគច្រើនដោយការបោះឆ្នោតជាសម្ងាត់នាកិច្ចប្រជុំលើកទី២(ពីរ)នោះ។ ក្នុងករណីទទួលបានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមភាព។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

**មាត្រា១៣ .-**

ក្រោយពីសម្រេចបានតួលេខឬអត្រាបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមាតាមនីតិវិធីដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវយកលទ្ធផលនេះធ្វើជាអនុសាសន៍ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល មុននឹងចេញប្រកាសកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។

ប្រាក់ឈ្នួលអប្បបរមាថ្មី ត្រូវមានសុពលភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំបន្ទាប់។

**មាត្រា១៤ .-**

និយោជកត្រូវបិទជាអចិន្ត្រៃយ៍នូវប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា នៅកន្លែងធ្វើការ ក្នុងការិយាល័យបើកប្រាក់ និងនៅទីកន្លែងទទួលឲ្យធ្វើការ។

## ជំពូកទី៤
## ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា

**មាត្រា១៥ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានៅអមក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា១៦ .-**

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានភារកិច្ចជាអាទិ៍៖

- សិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រលើកិច្ចការទាំងឡាយដែលទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា

- សម្របសម្រួលនិងបង្កលក្ខណងាយស្រួលដល់ភាគីពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ ការប្រជុំពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមា

- ផ្តល់អនុសាសន៍អំពីប្រាក់ឈ្នួលអប្បបរមា អត្ថប្រយោជន៍ផ្សេងៗនិងវិសាលភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមាជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ

- ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងនិងការសន្ទនាសង្គមអំពីការកំណត់ប្រាក់ឈ្នួលអប្បបរមា

- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារពាក់ព័ន្ធនឹងប្រាក់ឈ្នួល។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាអាចបង្កើតក្រុមការងារបច្ចេកទេសដើម្បីជាជំនួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។

បុគ្គលទាំងឡាយណា ក្រៅពីក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលធ្វើការសិក្សាស្រាវជ្រាវអំពីប្រាក់ឈ្នួលអប្បបរមា ត្រូវផ្តល់លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងប្រភពទិន្នន័យពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ មកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា១៧ .-**

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានសមាជិកពេញសិទ្ធិយ៉ាងតិចចំនួន៤៨(សែសិបប្រាំបី)រូប ដែលមានសមាសភាពមកពីត្រីភាគី ក្នុងចំនួនស្មើគ្នាដូចខាងក្រោម៖

១- មួយភាគបីជាតំណាងភាគីរាជរដ្ឋាភិបាល។

២- មួយភាគបីជាតំណាងភាគីកម្មករនិយោជិត។

៣- មួយភាគបីជាតំណាងភាគីនិយោជក។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារឬតំណាង១(មួយ)រូបនៃក្រសួងទទួលបន្ទុកវិស័យការងារ ជាប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវមានអនុប្រធាន២(ពីរ)រូប ដែល១(មួយ)រូបជ្រើសរើសចេញពីសមាសភាពតំណាងភាគីកម្មករនិយោជិត និង១(មួយ)រូបទៀតជ្រើសរើសចេញពីសមាសភាពតំណាងភាគីនិយោជក តាមរយៈការបោះឆ្នោតផ្ទៃក្នុងរបស់ភាគីនីមួយៗ។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវមានសមាជិកបម្រុងដែលមានចំនួនស្មើនឹងចំនួនសមាជិកពេញសិទ្ធិ ដើម្បីបំពេញជំនួសសមាជិកពេញសិទ្ធិណាមួយដែលអវត្តមាន។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ អាចស្នើសុំកែសម្រួលចំនួនសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាទៅរាជរដ្ឋាភិបាល ទៅតាមភាពចាំបាច់ តែមិនអាចតិចជាង៤៨(សែសិបប្រាំបី)រូបឡើយ។

ប្រាក់បៀវត្សនៃសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ជាបន្ទុករបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈសាមី។

**មាត្រា១៨ .-**

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវកំណត់ដោយអនុក្រឹត្យ។

សមាជិកពេញសិទ្ធិនិងសមាជិកបម្រុងរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា១៩ .-**

និយោជកដែលមានកម្មករនិយោជិតជាសមាជិកពេញសិទ្ធិឬសមាជិកបម្រុងនៃក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ត្រូវទុកពេលវេលាចាំបាច់ឲ្យជននេះបានទៅចូលរួមក្នុងកិច្ចប្រជុំផ្លូវការផ្សេងៗពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

រាល់ពេលកិច្ចប្រជុំ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវគិតប្រាក់ឈ្នួលឲ្យដូចពេលធ្វើការធម្មតា ហើយត្រូវទុកជាបានធ្វើការធម្មតាក្នុងការគិតគូរអំពីអតីតភាពនិងសិទ្ធិឈប់សម្រាកផ្សេងៗ។

កម្មករនិយោជិតដែលទទួលតំណែងជាសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ត្រូវទទួលបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដូចមានចែងក្នុងច្បាប់ជាធរមាន។

**មាត្រា២០ .-**

ក្រៅពីកិច្ចប្រជុំដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារដូចមានចែងក្នុងមាត្រា១១នៃច្បាប់នេះ ប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាអាចកោះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រជុំក្រុមប្រឹក្សានេះបានគ្រប់ពេលទៅតាមការចាំបាច់ ឬទៅតាមសំណើរបស់អនុប្រធានណាមួយ។ សំណើនេះត្រូវបញ្ជាក់ពីហេតុផលសមស្របនិងការចាំបាច់។

សមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវចូលរួមប្រជុំតាមការកំណត់និងអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

កូរ៉ុមសម្រាប់ដំណើរការរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ត្រូវមានយ៉ាងហោចណាស់ ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកទាំងអស់របស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវរៀបចំលិខិតអញ្ជើញចូលរួមប្រជុំ ដោយភ្ជាប់ឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំនេះជូនសមាជិកពេញសិទ្ធិនិងសមាជិកបម្រុង ឲ្យបានយ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃមុនសម័យប្រជុំ។ ក្នុងករណីចាំបាច់និងបន្ទាន់ រយៈពេលនៃការអញ្ជើញនេះគឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែង។

ក្នុងករណីដែលមានសំណើពីប្រធានឬអនុប្រធានណាមួយ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាអាចអញ្ជើញបុគ្គលណាម្នាក់ដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្រៅពីសមាជិក ដើម្បីចូលរួមប្រជុំផ្តល់យោបល់លើបញ្ហាដែលត្រូវពិភាក្សា ប៉ុន្តែបុគ្គលនោះមិនមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំទេ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដោយភ្ជាប់មកជាមួយនូវបញ្ជីវត្តមានអ្នកចូលរួមកិច្ចប្រជុំនិងត្រូវផ្ញើជូនសមាជិកពេញសិទ្ធិនិងសមាជិកបម្រុងទាំងអស់ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃប្រជុំ។

**មាត្រា២១ .-**

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលស្ថិតនៅក្រោមក្រសួងទទួលបន្ទុកវិស័យការងារ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវកំណត់ដោយអនុក្រឹត្យ។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ត្រូវមានថវិកាផ្ទាល់ខ្លួន ជាកញ្ចប់ដាច់ដោយឡែក ដែលជាផ្នែកមួយនៃថវិការបស់ក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីដំណើរការការងាររបស់ខ្លួន ។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ទិទានការរដ្ឋបាលនិងទោសប្បញ្ញត្តិ

**មាត្រា២២ .-**

ទណ្ឌកម្មក្នុងជំពូកនេះរួមមានការព្រមានជាលាយលក្ខណ៍អក្សរនិងពិន័យអន្តរការណ៍។

ការព្រមានជាលាយលក្ខណ៍អក្សរនិងការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងត្រូវបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

បែបបទនិងនីតិវិធីក្នុងការដាក់ទណ្ឌកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា២៣ ._**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលទាំងឡាយណាដែលបំពានបញ្ញត្តិនៃមាត្រា៥នៃច្បាប់នេះ។

ក្នុងករណីមិនគោរពតាមការព្រមានខាងលើ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥ ០០០ ០០០(ប្រាំលាន)រៀល។

**មាត្រា២៤ ._**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៤០ ០០០ ០០០(សែសិបលាន)រៀលចំពោះនិយោជកដែលបំពានបញ្ញត្តិនៃមាត្រា៤ មាត្រា៦ មាត្រា៧ ឬមាត្រា៨នៃច្បាប់នេះ។

បន្ថែមលើទណ្ឌកម្មខាងលើ និយោជកដែលបានបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតតិចជាងប្រាក់ឈ្នួលអប្បបរមា ត្រូវសងត្រឡប់ទៅកម្មករនិយោជិតវិញនូវចំនួនទឹកប្រាក់ដែលបានបំពាន ដោយគិតបញ្ចូលទាំងការប្រាក់ដែលត្រូវទទួលបាន ក្នុងអត្រាដែលកំណត់ដោយច្បាប់។

**មាត្រា២៥ ._**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរចំពោះនិយោជកដែលបំពានបញ្ញត្តិនៃមាត្រា១៨នៃច្បាប់នេះ។

ក្នុងករណីមិនគោរពតាមការព្រមានខាងលើ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥ ០០០ ០០០(ប្រាំលាន)រៀល។

**មាត្រា២៦ ._**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលទាំងឡាយណាដែលបំពានលើបញ្ញត្តិនៃកថាខណ្ឌទី៣ នៃមាត្រា១៦នៃច្បាប់នេះ។

ក្នុងករណីមិនគោរពតាមការព្រមានខាងលើ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា២៧ ._**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរចំពោះនិយោជកដែលបំពានលើបញ្ញត្តិនៃមាត្រា១៩នៃច្បាប់នេះ។

ក្នុងករណីមិនគោរពតាមការព្រមានខាងលើ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា២៨ ._**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៥(វិធានការរដ្ឋបាលនិងទោសប្បញ្ញត្តិ)នៃច្បាប់នេះមិនរារាំងការអនុវត្តច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការងារ ឬច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ទាំងនោះ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ប្រធានរដ្ឋមន្ត្រី

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៩ .-**

មាត្រា១០៤ មាត្រា១០៥ មាត្រា១០៦ មាត្រា១០៧ មាត្រា១០៨ មាត្រា១០៩នៃច្បាប់ស្តីពីការងារដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣០.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ សុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.០៧១៨.០០៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខ:៧៣២ស.ណ
**សំណៅដែលមានតម្លៃជាការថែកផ្សាយ**
ថ្ងៃចន្ទ ១២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រម

នស/រកម/០៧០៧/០២០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ក្រៅពីការងារបន្តបន្ទាប់ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការជូនថ្ងៃ ជូនយប់ ការងារនៃសហគ្រាសអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច ។ ការងារពេលយប់ ត្រូវឱ្យប្រាក់ឈ្នួលតាមអត្រា ១៣០ ៖ (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ។

**មាត្រា ពីរ.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២០* ខែ*កក្កដា* ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ព.រ.ក. ០៧០៧.៣១៣*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ហត្ថលេខា**

**វង សូត**

លេខ: ៣០៧ ច.ល

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៤៤៣ ក.ប/ប្រ.ក.ខ.ល

# ប្រកាស
## ស្តីពី
## ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៥

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានវិសាលភាពគ្របដណ្ដប់លើសហគ្រាស គ្រឹះស្ថាន និងជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

ប្រាក់បំណាច់អតីតភាពការងារ ដូចមានចែងក្នុងមាត្រា៨៩ថ្មីនៃច្បាប់ស្ដីពីការងារ ត្រូវអនុវត្តទៅលើតែកម្មករនិយោជិតមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់តែប៉ុណ្ណោះ។

ចំពោះកម្មករនិយោជិត ដែលមានកិច្ចសន្យាការងារមានកំណត់ថិរវេលា និយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាផង ហើយដែលចំនួនប្រាក់បំណាច់នេះ មានកំណត់ក្នុងអនុសញ្ញារួម។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើ៥%(ប្រាំភាគរយ)នៃប្រាក់ឈ្នួល ដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា។

**ប្រការ២ .-**

ការផ្ដល់ប្រាក់បំណាច់អតីតភាពការងារ២(ពីរ)ដងក្នុងមួយឆ្នាំ ត្រូវអនុវត្តចាប់ពីឆ្នាំ២០១៩តទៅស្របតាមបែបបទដូចខាងក្រោម៖

១-និយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិត ដែលកំពុងបម្រើការងារនូវប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន១៥(ដប់ប្រាំ)ថ្ងៃ ក្នុង១(មួយ)ឆ្នាំ។ ប្រាក់បំណាច់នេះ ត្រូវបើកជូនកម្មករនិយោជិត៖

- ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។

២-ចំពោះកម្មករនិយោជិត ដែលចូលធ្វើការនៅក្នុងឆ្នាំដំបូង ហើយដែលបានបំពេញការងារជាប់ជានិច្ចចាប់ពី១(មួយ)ខែ ទៅដល់៦(ប្រាំមួយ)ខែ និយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ។

**ប្រការ៣ .-**

ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ របស់កម្មករនិយោជិត ដែលបាននិងកំពុងបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម៖

១-ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និយោជកត្រូវបើករំលឹកចំនួន ៣០(សាមសិប)ថ្ងៃ នៃប្រាក់បំណាច់អតីតភាពការងារសរុប រៀងរាល់១(មួយ)ឆ្នាំម្ដង ដោយ៖

- ចំនួន១៥ (ដប់ប្រាំ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន១៥ (ដប់ប្រាំ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។

២-ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកផ្សេងទៀត ក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និយោជកត្រូវបើករំលឹកចំនួន១៥(ដប់ប្រាំ)ថ្ងៃ នៃប្រាក់បំណាច់អតីតភាពការងារសរុប រៀងរាល់១(មួយ)ឆ្នាំម្ដង ដោយ៖

- ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។

ប្រាក់បំណាច់អតីតភាពការងារអតិបរមា ដែលត្រូវបើកវំលឹក មិនអាចលើសពី៦(ប្រាំមួយ)ខែ នៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលត្រូវរំលឹកនោះ។

ចំពោះឆ្នាំការងារដំបូង ដែលជាមូលដ្ឋានត្រូវរំលឹកអតីតភាពការងារ កម្មករនិយោជិត ដែលបានបំពេញការងារជាប់ជានិច្ចចាប់ពី ១(មួយ)ខែ ទៅដល់៦(ប្រាំមួយ)ខែ និយោជកត្រូវបើករំលឹកឲ្យកម្មករនិយោជិតនោះនូវប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ។ បើថិរវេលាធ្វើការលើសពី៦(ប្រាំមួយ)ខែ ត្រូវគិតស្មើនឹង១(មួយ)ឆ្នាំពេញ ហើយនិយោជកត្រូវបើករំលឹកឲ្យកម្មករនិយោជិតនូវប្រាក់បំណាច់អតីតភាពការងារចំនួន១៥(ដប់ប្រាំ)ថ្ងៃ។

កម្មករនិយោជិត ដែលមានអតីតភាពការងារមុនឆ្នាំ២០១៩ ចាប់ពី១(មួយ)ខែឡើង នឹងទទួលបាននូវប្រាក់បំណាច់អតីតភាពការងារ២(ពីរ)ប្រភេទផ្សេងគ្នា គឺប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំនីមួយៗ។

ចំពោះកម្មករនិយោជិត ដែលបានលាឈប់ពីការងារ នឹងមិនត្រូវទទួលបាននូវប្រាក់រំលឹកអតីតភាពការងារដែលនៅសល់នោះទេ។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានអង្គភាពក្រោមឱវាទនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៥
  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០៥៤៨/១៩ ក.ប/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## ការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិត ដែលស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសលេខ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ សូមលោក លោកស្រីជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតត្រូវអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

### I - របៀបគិតអតីតភាពការងារ

ចាប់ពីឆ្នាំ២០១៩តទៅ អតីតភាពការងាររបស់កម្មករនិយោជិតសម្រាប់ទទួលបានប្រាក់បំណាច់អតីតភាពការងារត្រូវគិតក្នុងរយៈពេល ១ឆមាស (៦ខែ) ម្តង គឺឆមាសទី១ ពីខែមករា ដល់ ខែមិថុនា និងឆមាសទី២ ពីខែកក្កដា ដល់ ខែធ្នូ។

កម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារ ចាប់ពី១ខែ ទៅ៦ខែ នៅក្នុងឆមាសនីមួយៗ ហើយបានបំពេញការងាររហូតដល់ដំណាច់ខែចុងក្រោយនៃឆមាសនីមួយៗគឺ ខែមិថុនា និងខែធ្នូ នោះទើបកម្មករនិយោជិតអាចទទួលបាននូវប្រាក់បំណាច់អតីតភាពការងារ ដែលស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមចំនួន ៧,៥ថ្ងៃ នៅក្នុងឆមាសនីមួយៗ។

ក្នុងករណីដែលកម្មករនិយោជិតបានលាឈប់ពីការងារមុនដំណាច់ខែមិថុនា ឬខែធ្នូនោះនឹងមិនត្រូវបានទទួលនូវប្រាក់បំណាច់អតីតភាពការងារនៅក្នុងឆមាសនីមួយៗនោះទេ។

### II - របៀបគណនាប្រាក់បំណាច់អតីតភាពការងារ

ចាប់ពីឆ្នាំ២០១៩ តទៅ កម្មករនិយោជិតពេញសិទ្ធិទាំងឡាយណាដែលបានបំពេញការងារ ហើយមានអតីតភាពការងារដូចក្នុងលក្ខខណ្ឌកំណត់នៅក្នុងចំណុច "I" ខាងលើ ការគណនាប្រាក់បំណាច់អតីតភាពការងារត្រូវអនុវត្តដូចខាងក្រោម៖

❖ ទី១ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំសរុបក្នុងឆមាស}}{\text{៦ខែ ឬតាមចំនួនខែបានធ្វើការងារជាក់ស្តែង}}$$



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៥

❖ ទី២ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ

| | |
|---|---|
| ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ = | ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ខែ<br>─────────────<br>២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ<br>(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃសហគ្រាស គ្រឹះស្ថាននីមួយៗ) |

ដូច្នេះ ប្រាក់បំណាច់អតីតភាពការងារដែលទទួលបាននៅក្នុងឆមាសនីមួយៗ គឺ៖

| |
|---|
| ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសនីមួយៗ = ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ថ្ងៃ x ៧,៥ |

## III - របៀបបើកប្រាក់បំណាច់អតីតភាពការងារ

ប្រាក់បំណាច់អតីតភាពការងារនេះ: ត្រូវបើកជាមួយនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលបានលើកទី២ (១ខែ បើក ២ដង) សម្រាប់ខែមិថុនា និងខែធ្នូ។

និយោជកត្រូវញែកឱ្យដាច់ពីគ្នារវាងចំនួនប្រាក់ឈ្នួលប្រចាំខែ និងប្រាក់បំណាច់អតីតភាពការងារ ដើម្បីងាយស្រួលក្នុងការអនុវត្តកាតព្វកិច្ចពន្ធដារ។

## IV - ការបញ្ឈប់កម្មករនិយោជិតពីការងារ

**ក**. ក្នុងករណីនិយោជកបញ្ឈប់កម្មករនិយោជិតដោយគ្មានហេតុផលត្រឹមត្រូវ កម្មករនិយោជិតត្រូវទទួលបាន៖

១- ប្រាក់ឈ្នួលដែលមិនទាន់បានបើក។

២- ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមការកំណត់របស់ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

៣- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

៤- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ៧ថ្ងៃ បើកម្មករនិយោជិតនៅសល់អតីតភាពការងារចាប់ពី ១ខែ ដល់ក្រោម ៦ខែ។

៥- ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩សរុប ដែលនិយោជកមិនទាន់បានបើកផ្តល់។

ក្រៅពីចំណុចទាំង៤ខាងលើ កម្មករនិយោជិតក៏អាចទាមទារសោហ៊ុយជំងឺចិត្ត ដែលស្មើនឹងប្រាក់បំណាច់អតីតភាពការងារ ដែលកម្មករនិយោជិតត្រូវទទួលបាន ប៉ុន្តែមិនត្រូវលើសពីប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ៦ខែនោះឡើយ។ ក្នុងករណីនេះ កម្មករនិយោជិតត្រូវបានរួចផុតពីកាតព្វកិច្ចដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន។ ដោយឡែក និយោជកក៏មិនមានកាតព្វកិច្ចត្រូវតែទូទាត់តាមសំណើសុំរបស់កម្មករនិយោជិតនោះទេ។ ក្នុងករណីមិនមានការព្រមព្រៀង កម្មករនិយោជិតអាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

**ខ**. ក្នុងករណីនិយោជកបញ្ឈប់កម្មករនិយោជិតដោយកំហុសធ្ងន់ កម្មករនិយោជិតអាចទទួលបាន៖

១- ប្រាក់ឈ្នួលដែលមិនទាន់បានបើក។

២- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

## V - គោលការណ៍រួម

១- អតីតភាពការងារកម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់អតីតភាពការងារ ត្រូវគិតចាប់ពីពេលបានចុះកិច្ចសន្យាការងារជាកម្មករនិយោជិតពេញសិទ្ធិ ដោយមិនរាប់បញ្ចូលថិរវេលាសាកល្បងទេ។

២- កម្មករនិយោជិតពេញសិទ្ធិដែលបានបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន២១ថ្ងៃ ត្រូវចាត់ទុកថាបំពេញការងារបាន១ខែពេញ ដែលអាចទទួលបានប្រាក់បំណាច់អតីតភាពការងារ។

៣- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ដែលយកមកធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់បំណាច់អតីតភាពការងារដែលមានចាប់ពីឆ្នាំ២០១៩ គឺជាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំដែលមិនទាន់កាត់ពន្ធ។

៤- ចំពោះកម្មករនិយោជិត ដែលចូលនិវត្តន៍ឬទទួលមរណៈភាព ចាប់ពីឆ្នាំ២០១៩ តរៀងមក និយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិត ឬទាយាទរបស់កម្មករនិយោជិតដែលបានទទួលមរណៈភាពនូវ៖

- ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ ដែលនៅសល់
- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយដែលកម្មករនិយោជិតត្រូវចូលនិវត្តន៍ឬទទួលមរណៈភាព ស្មើនឹងប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំចំនួន ៧ថ្ងៃ បើកម្មករនិយោជិតនៅសល់អតីតភាពការងារចាប់ពី ១ខែ ដល់ក្រោម ៦ខែ។

៥- ថិរវេលានៃការឈប់សម្រាកលំហែមាតុភាព គ្រោះថ្នាក់ការងារ និងការឈប់សម្រាកដោយជំងឺ ត្រូវរាប់បញ្ចូលជាអតីតភាពការងារដើម្បីគិតប្រាក់បំណាច់អតីតភាពការងារ។ ដោយឡែកប្រាក់បន្ទាប់បន្សំ ជាអាទិ៍តាវកាលិកហានិភ័យការងារ និងតាវកាលិកថែទាំសុខភាព ដែលទទួលបានក្នុងអំឡុងពេលឈប់សម្រាកខាងលើនេះនឹងមិនត្រូវរាប់បញ្ចូលក្នុងការគណនាប្រាក់បំណាច់អតីតភាពការងារទេ។

៦- ចាប់ពីឆ្នាំ២០១៩តទៅ នៅរៀងរាល់ពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗ កម្មករនិយោជិតត្រូវទទួលបាន៖

- ប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងខែធ្នូ
- ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆមាសចំនួន ៧,៥ថ្ងៃ
- ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ ប្រសិនជាមាន។

៧- រាល់ការទូទាត់ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសនីមួយៗ និយោជក និងកម្មករនិយោជិតត្រូវរក្សាទុកនូវឯកសារជាភស្តុតាងដែលមានចុះហត្ថលេខា ឬស្នាមម្រាមដៃយល់ព្រមរបស់ភាគីទាំងពីរ ឬឯកសារដែលមានតម្លៃស្មើ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ ព្រមទាំងកម្មករនិយោជិត ដែលស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារនឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះបានត្រឹមត្រូវ និងធានាបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ *"ដើម្បីជូនជ្រាប"*
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

*"ដើម្បីអនុវត្ត"*

- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ២

# ប្រវត្តិប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជា

Tuesday, 27 June 2017 20:49 | Written by MLVT | 16790 times | Print | Email

| | | | |
|---|---|---|---|
| ១ មករា ២០១៧ | ១៧០ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ១៥៣ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ) |
| ១ មករា ២០១៦ | ១៥៧ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ១៤០ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ) |
| ១ មករា ២០១៥ | ១៤៥ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ១២៨ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ) |
| ១ កុម្ភៈ ២០១៤ | ១១៧ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ១០០ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ) |
| ១ ឧសភា ២០១៣ | ៩៧ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៨០ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ) |
| ១ កញ្ញា ២០១២ | ៨៣ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៦១ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១០ដុល្លារ + ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ៧ដុល្លារ + ប្រាក់ថែទាំសុខភាព ៥ដុល្លារ) |
| ១ មករា ២០១២ | ៧៣ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៦១ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៧ដុល្លារ + ប្រាក់ថែទាំសុខភាព ៥ដុល្លារ) |
| ១ មីនា ២០១១ | ៦៨ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៦១ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៧ដុល្លារ) |
| ១ តុលា ២០១០ | ៦៦ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៦១ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ដុល្លារ) |
| ១ មេសា ២០០៨ | ៦១ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៥០ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ដុល្លារ + ប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ) |
| ១ មករា ២០០៧ | ៥៥ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៥០ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ដុល្លារ) |
| ១ សីហា ២០០០ | ៥០ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៤៥ដុល្លារ | + ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ដុល្លារ) |
| ១៩៩៧ | ៤០ដុល្លារ | (ប្រាក់ឈ្នួលអប្បបរមា ៤០ដុល្លារ | |

